ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន
# ករណីសិក្សានៅខេត្តស្វាយរៀង

An Evaluation of the Implementation of Upper Secondary School Managemment

(A case study in Svay Rieng Province)

ដោយ/by

**គុជ សំអ៊ែល**

KUCH SAM EL

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន
# ករណីសិក្សានៅខេត្តស្វាយរៀង

An Evaluation of the Implementation of Upper Secondary School Management

(A case study in Svay Rieng Province)


**ដោយ**/by

**គូច សំអ៊ែល**

KUCH SAM EL


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖ បណ្ឌិត ជ័យ សារិន**

**សាស្ត្រាចារ្យដឹកនាំរង៖ ម៉ៅ សារឿន**


**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦២៩ **អយក.** ប្រក

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង** ៖ -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំៈ

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុធន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**វិធានការអនុវត្តការគ្រប់គ្រងតាមសាលារៀន**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំគឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បាន ប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

ហត្ថលេខាបេក្ខជន

គុជ សំអើល

# លិខិតបញ្ជាក់

ឯកឧត្តមបណ្ឌិត ជ័យ សារិន ជាសាស្ត្រាចារ្យដឹកនាំ

លោក ម៉ៅ សារឿន ជាសាស្ត្រាចារ្យដឹកនាំរង

សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក គុជ សំអ៊ែល ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនករណីសិក្សានៅខេត្តស្វាយរៀង**»ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

.......................................

**បណ្ឌិត ជ័យ សារិន**

ប្រធានអគ្គាធិការដ្ឋាន

.......................................

**លោក ម៉ៅ សារឿន**

ប្រធាននាយកដ្ឋាន

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) Cambodia International Education Support Foundation ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ ដល់ខ្ញុំបាទបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រង ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា ដោយមិនគិតពីការនឿយហត់នោះឡើយ។ ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកសាស្ត្រាចារ្យ **បណ្ឌិត ជ័យ សារិន** ដែលលោកតែងតែចំណាយពេលវេលាដ៏មានតម្លៃមកពន្យល់ខ្ញុំបាទគ្រប់ជំហាន ទើបធ្វើឲ្យការស្រាវជ្រាវរបស់ខ្ញុំនាពេលនេះទទួលបានជោគជ័យ និងភាពរលូន។ ជាមួយគ្នានេះដែរខ្ញុំក៏សូមអរគុណដល់លោកសាស្ត្រាចារ្យរង **ម៉ៅ សារឿន** និងមិត្តរួមជំនាន់ទី៦ទាំងអស់ដែលតែងតែផ្តល់ជាគំនិតល្អៗ និងកម្លាំងចិត្ត តាមរយៈការចែករំលែក ចំណេះដឹង បទពិសោធ ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទ ដើម្បីឲ្យការស្រាវជ្រាវនេះមានភាពងាយស្រួល។

បន្ថែមពីនេះទៀតខ្ញុំក៏សូមថ្លែងអំណរគុណដល់ លោកឪពុក អ្នកម្តាយ បងប្អូន និងភរិយារបស់ខ្ញុំបាទ ព្រមទាំងកូនៗដែលបានផ្តល់នូវពេលវេលា ប្រាក់កាស និងតែងតែជំរុញ និងលើកទឹកចិត្តដើម្បីឲ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវការសរសេរនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជូនចំពោះ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងក្រុមគ្រួសារ និងភរិយា ព្រមទាំងកូនៗខ្ញុំបាទឲ្យជួបតែពុទ្ធទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ

# មូលន័យសង្ខេប

ក្នុងការសិក្សាស្រាវជ្រាវពី វង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន នៅមធ្យមសិក្សាទុតិយភូមិមានគោលបំណងចង់ដឹងពីៈ ( ១) រកឱ្យឃើញនូវស្ថានភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុង ខេត្តស្វាយរៀង និង (២) រកឱ្យឃើញពីបញ្ហាប្រឈមនានាដែលរាំងស្ទះដល់ដំណើរការនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ។ ភាគសំណាកនៃការសិក្សានេះធ្វើទៅលើគ្រូបង្រៀនចំនួន១១៤ នាក់ លោកនាយកចំនួន ១៥នាក់ សិស្សានុសិស្ស១៩៤នាក់ គណៈគ្រប់គ្រងសាលារៀនចំនួន ០៥នាក់ដែលស្ថិតនៅក្នុងវិទ្យាល័យចំនួន០៥ក្នុងខេត្តស្វាយរៀង។ ឧបករណ៍ប្រើសម្រាប់ការស្រាវជ្រាវនេះគឺកម្រងសំណួរដែលចែកពីរប្រភេទគឺ កម្រងសំណួរសម្រាប់បំពេញ និង សំណួរបញ្ចេញមតិយោបល់។ សម្រាប់កម្រងសំណួរសម្រាប់បំពេញចែកចេញជា០៩ផ្នែក គឺ ( ១) ការគ្រប់គ្រងរដ្ឋបាលសាលារៀន (២) ការគ្រប់គ្រងបច្ចេកទេស ការបង្រៀន និងរៀន (៣) មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស (៤ ) សិស្ស និងសេវាជួយសិស្ស (៥) ការដឹកនាំ ការគ្រប់គ្រងសាលារៀន (៦) ធនធានមនុស្ស (៧) សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន (៨) ហេដ្ឋារចនា សម្ព័ន្ធ និងបរិស្ថាន និង (៩) ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ទិន្នន័យដែលប្រមូលបានត្រូវបានវិភាគ ជាស្ថិតិដូចជា តម្លៃភាគរយ ( %) តម្លៃមធ្យម ( Mean)

គម្លាតស្តង់ដា ( Standard deviation)។

លទ្ធផលសំខាន់នៃការស្រាវជ្រាវសរុបបានដូចជា ៖

១. តាមរយៈការបំពេញកម្រងសំណួររបស់លោកនាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងគណៈគ្រប់គ្រងសាលារៀនទៅលើវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនរួចមកបង្ហាញបង្ហាញឱ្យឃើញថាការអនុវត្តការគ្រប់គ្រងសាលារៀនមានមធ្យមកម្រិតខ្ពស់ទៅលើផ្នែកមួយចំនួនដូចជាៈ ផ្នែកការគ្រប់គ្រងរដ្ឋបាលសាលារៀនមានមធ្យមកម្រិតខ្ពស់នៅលំដាប់ទី១ ផ្នែកការគ្រប់គ្រងការបង្រៀន និងរៀនមានកម្រិតមធ្យមខ្ពស់នៅលំដាប់ទី២ ផ្នែកការដឹកនាំ និងការគ្រប់គ្រងសាលារៀនមានមធ្យមកម្រិតខ្ពស់នៅលំដាប់ទី៣។ ចំណែកឯផ្នែកដែលមានកម្រិតមធ្យមក្រោមគេគឺផ្នែក សិស្ស និងសេវាជួយសិស្សដែលស្ថិតនៅលំដាប់មធ្យមទាបជាងគេ បន្ទាប់មកទៀតគឺ ផ្នែកហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងផ្នែកទាបបន្ទាប់មកទៀតគឺផ្នែកសៀវភៅសិស្សាគោល និងសម្ភារៈបង្រៀន និងបង្រៀន។

២. លទ្ធផលនៃការស្រាវជ្រាវនេះក៏បង្ហាញឱ្យឃើញផងដែរពីបញ្ហាប្រឈមចំពោះដំណើរការ នៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន មានដូចជា ផ្នែកសិស្ស និងសេវាជួយសិស្ស ៖ មានការខ្វះខាតបន្ទប់ពិសោធន៍ សម្ភារៈបង្រៀន និងរៀន ( សៀវភៅសិក្សាគោល ) បណ្ណាល័យមួយចំនួនមិនរៀបចំតាមស្តង់ដា ខ្វះបន្ទប់កុំព្យូទ័រ និងកុំព្យូទ័រសម្រាប់បង្រៀនសិស្សផ្នែកព័ត៌មានវិទ្យា( ICT) ការបង្កើតក្លឹបសិក្សានៅមានកម្រិតទាបបំផុត ហើយមានការខ្វះខាតថវិកាក្នុងការធ្វើស្វ័យភាពបើកវគ្គសិក្ខាសាលាក្នុងសាលារៀន ដើម្បីពង្រឹងសមត្ថភាពចំណេះដឹង វិធីសាស្រ្តបង្រៀនថ្មីៗនិងការធ្វើទស្សនកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធជាមួយសាលាផ្សេងទៀតទាំងនៅក្នុងប្រទេស ក៏ដូចជានៅក្នុងតំបន់។

## Abstract

In studying the evaluation of school management practices in high school, the purpose of the study was to find out: (1) find out the status of school management practices at the high school level in Svay Rieng; and (2) Identify challenges that hinder the process of school-based management practices. The sample consisted of 114 teachers, 15 principals, 194 students and 5 school management teams located in 5 high schools in Svay Rieng province. The research instrument used was a two-part questionnaire: fill-in questionnaire and feedback questionnaire. For the questionnaire, the questionnaire was divided into nine sections: (1) school administration, (2) technical management, teaching and learning, (3) parents and community, student support, (4) students, and student support services (5). Leadership in school management, (6) human resources, (7) benchmarks, teaching and learning materials, (8) infrastructure and environment, and (9) finance and financial management. The collected data were analyzed statistically as a percentage value (%), mean value (Mean), standard deviation (Standard deviation)

The main findings of the study were:

1. By completing the Principal's questionnaire, teachers, students and school management on the evaluation of school management practices, it was shown that school management practices had a high average of Some such as: The school administration has the highest average of Tier 1, the teaching and learning management are the second highest, and the school administration and management have the highest average in the third. The lower middle class is the student and student services subordinates the rest is the school infrastructure and the lower part, the textbooks and the teaching and teaching materials.

2. The findings also highlight the challenges to the implementation of school-based management practices, such as student and student services: lack of labs, teaching and learning materials (textbooks), some libraries Following the standardization of lack of computer and computer labs for teaching ICT (ICT) students, the establishment of the Cambodian Club was still underway Low levels and lack of funding for autonomous seminars enable schools to enhance their knowledge, new teaching methods, and study visits to exchange experiences with other schools both nationally and locally.

# មាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន ..........1
លិខិតបញ្ជាក់ .......... 2
សេចក្តីថ្លែងអំណរគុណ ..........i
មូលន័យសង្ខេប ..........ii
Abstract.......... iii
មាតិកា ..........iv
បញ្ជីតារាង .......... vii
បញ្ជីអក្សរកាត់ ..........viii
ជំពូកទី១ ៖ សេចក្តីផ្តើម .......... 2
១.១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ .......... 2
១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..........4
១.៣. គោលបំណងនៃការស្រាវជ្រាវ.......... 5
១.៤. សំណួរស្រាវជ្រាវ.......... 5
១.៥. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.......... 5
១.៦. សារៈសំខាន់នៃការស្រាវជ្រាវ .......... 5
១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ ..........6
ជំពូកទី២ ៖ រំលឹកទ្រឹស្តី ..........8
២.១. និយមន័យពាក្យគន្លឹះ ..........8
២.២. សកម្មភាពទូទៅនៃការវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ..........8
២.២.១ .ការគ្រប់គ្រងការ បង្រៀន និងរៀន ..........9
២.២.២. ការគ្រប់គ្រងរដ្ឋបាលសាលារៀន .......... 12
២.២.៣ .ការងារទំនាក់ទំនង..........14
២.២.៤ .ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន )ស្តង់ដាទី ៣ របស់នាយក( ..........16

២.២.៥ . ការគ្រប់គ្រងធនធានមនុស្សរបស់សាលារៀន ........................................................ 18

២.២.៦. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការធ្វើផែនការសាលារៀន ............................................ 21

ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ ........................................................................ 24

៣.១. ព័ត៌មានទូទៅស្តីពីការស្រាវជ្រាវ ........................................................................ 24

៣.២. ទីតាំងនៃការស្រាវជ្រាវ ........................................................................ 24

៣.៣- ការជ្រើសរើសសំណាក ........................................................................ 25

៣.៤- ឧបករណ៍ស្រាវជ្រាវ ........................................................................ 25

៣.៥- ដំណើរការប្រមូលទិន្នន័យ ........................................................................ 25

៣.៦. ការវិភាគទិន្នន័យ ........................................................................ 26

៣.៧- ក្រមសីលធម៌នៃការស្រាវជ្រាវ ........................................................................ 27

ជំពូកទី៤ ៖ លទ្ធផលការស្រាវជ្រាវ និងការពិភាក្សា ........................................................ 28

៤.១- លទ្ធផលការស្រាវជ្រាវ ........................................................................ 29

ក.កម្រងសំណួរសម្រាប់សួរទៅលើលោកគ្រូ អ្នកគ្រូ ........................................................ 29

ខ.កម្រងសំណួរសម្រាប់សួរទៅលើសិស្សានុសិស្សនៅមធ្យមសិក្សាទុតិយភូមិ ........................ 39

គ.កម្រងសំណួរសម្រាប់សួរទៅលើគណៈនាយក ........................................................ 45

ឃ .តារាងបង្ហាញពី តម្លៃមធ្យម គម្លាតស្តង់ដា លំដាប់តាមផ្នែកនីមួយៗរបស់គណៈកម្មការគ្រប់គ្រងសាលារៀនលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន(N=05) ........................ 55

៤.២. ស្ថានភាពជាក់ស្តែង តាមរយៈការបញ្ចេញគំនិត ........................................................ 57

៤.៣. បញ្ហាប្រឈម ........................................................................ 60

ជំពូកទី៥ ៖ សន្និដ្ឋាន និងសំណូមពរ ........................................................................ 62

៥.១. សេចក្តីសង្ខេបលទ្ធផលស្រាវជ្រាវ ........................................................................ 62

៥.២សេចក្តីសន្និដ្ឋាន ........................................................................ 63

៥.៣. ការពិភាក្សាលទ្ធផល ........................................................................ 64

៥.៤. សំណូមពរ ........................................................................ 67

៥.៥. អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត ....................................................68

ឯកសារយោង ....................................................................................................69

ឧបសម្ព័ន្ធ ........................................................................................................72

ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ..................................72

ឧបសម្ព័ន្ធទី២៖ កម្រងសំណួរ............................................................................ 75

ឧបសម្ព័ន្ធទី៣ ..................................................................................................96

១-គណៈកម្មការមេប្រយោគ ............................................................................ 96

២-គណៈកម្មការការពារនិក្ខេបបទ.................................................................... 98

៣-គណៈកម្មការកណ្ដាល .................................................................................. 99

# បញ្ជីតារាង

តារាងទី១៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃរដ្ឋបាលសិក្សារបស់លោកនាយក លោកគ្រូ អ្នកគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១១៤)......................................២៩
តារាងទី២៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃការបង្រៀន និងរៀនរបស់លោកគ្រូ អ្នកគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១១៤)..................................................៣០
តារាងទី៣៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក មាតាបិតា និងសហគមន៍ជួយសិស្ស (N= ១១៤).....................................................................................................៣១
តារាងទី៤៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក សិស្ស និងសេវាជួយសិស្ស (N= ១១៤).............................................................................................................៣២
តារាងទី៥៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ការដឹកនាំ និងការគ្រប់គ្រងសាលារៀន (N=១១៤).........................................................................................៣៣
តារាងទី៦៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិត នៃផ្នែកធនធមនុស្ស (N=១១៤)...............................................................................................................៣៤
តារាងទី៧៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃផ្នែក សៀវភៅសិក្សាគោល សម្ភារៈបង្រៀន និងបង្រៀន(N= ១១៤)..........................................................................៣៥
តារាងទី៨៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន (N= ១១៤)..............................................................................៣៦
តារាងទី៩៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ (N= ១១៤).................................................................................៣៧
តារាងទី១០៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់តាមផ្នែកនីមួយៗរបស់លោកគ្រូ អ្នកគ្រូទៅលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន (N= ១១៤)..............................................៣៨
តារាងទី១១៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់តាមផ្នែកនីមួយៗរបស់សិស្សានុសិស្សទៅលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន (N= ១៩៤)............................................៤៤
តារាងទី១២៖ តម្លៃ មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតតាមផ្នែកនីមួយៗរបស់គណៈនាយកលើការគ្រប់គ្រងការបង្រៀន និងរៀន (N= ១៥)។....................................៥៤
តារាងទី១៣ ៖តម្លៃ មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិតតាមផ្នែកនីមួយៗរបស់គណៈគ្រប់គ្រងសាលារៀន.........................................................................................៥៥

# <u>បញ្ជីអក្សរកាត់</u>

| | | |
|---|---|---|
| ១. វិ.ហាសប្រសូតិ | ៖ | វិទ្យាល័យ ហ៊ុនសែន ប្រសូតិ |
| ២. វិ.ហាស កំពង់ពោធិ៍ | ៖ | វិទ្យាល័យ ហ៊ុនសែន កំពង់ពោធិ៍ |
| ៣. វិ.ហាសក្រោលគោ | ៖ | វិទ្យាល័យ ហ៊ុនសែន ក្រោលគោ |
| ៤. វិ. ហាសស្វាយរំពារ | ៖ | វិទ្យាល័យ ហ៊ុនសែន ស្វាយរំពារ |
| ៥. វិ. ជ.អ | ៖ | វិទ្យាស្ថានជាតិ អប់រំ |
| ៦. CIESF | ៖ | Cambodia International Education Sport Fundation |

# ជំពូកទី ១
# សេចក្តីផ្តើម

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

នៅក្នុងដំណើរការកសាង និងអភិវឌ្ឍប្រទេសជាតិមួយឱ្យរីកចម្រើនប្រកបដោយសុខសុវត្ថិភាព ប្រទេសនីមួយៗមិនអាចកាត់ផ្តាច់ចេញពីការបណ្តុះបណ្តាល ការអប់រំដើម្បីបង្កើតធនធានមនុស្សបាននោះទេ។ ដោយមើលឃើញពីការអភិវឌ្ឍ រីកចម្រើនរបស់ពិភពលោក ក៏ដូចជាបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់តាមរយៈការយកចិត្តទុកដាក់ខ្ពស់ក្នុងវិស័យអប់រំដែលជាកត្តាសំខាន់មួយជំរុញឱ្យប្រទេសជាតិយើងមានការអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័ស ប្រទេសកម្ពុជាយើងក៏បានអនុម័តតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពក្នុងឆ្នាំ ២០១៥ និងអនុវត្តការធ្វើមូលដ្ឋានីយកម្មដើម្បីឆ្លើយតបទៅនឹងស្ថានភាព និងតម្រូវការជាក់ស្តែងរបស់ប្រទេស។ គោលដៅទី៤នៃការអភិវឌ្ឍប្រកបដោយចីរភាព បានផ្តោតលើការអប់រំដោយធានាការអប់រំបរិយាប័ន្ន សមធម៌ គុណធម៌ គុណភាព និង លើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា(UNESCO,2015) ។ ការអប់រំបែបបរិយាបន្នបានផ្តោតសំខាន់ទៅលើការលើកកម្ពស់តាមរយៈការលើកទឹកចិត្តឱ្យមានការចូលរួមទូលំទូលាយ ពីអ្នកពាក់ព័ន្ធទាំងអស់ក្នុងការអភិវឌ្ឍ ដោយមិនប្រកាន់និន្នាការនយោបាយ ជាតិសាសន៍ វប្បធម៌ សាសនា វណ្ណៈសង្គមនោះឡើយ។ ជាមួយគ្នានេះដែរ និន្នាការថ្មីក្នុងតំបន់ដែលបានរួមគ្នាបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ( AEU) ក្នុងឆ្នាំ២០១៥បានអនុញ្ញាតឱ្យមានលំហូរចូលពលករជំនាញដោយសេរី ក្នុងចំណោមប្រទេសជាសមាជិកទាំងអស់ដែលជាកត្តាជំរុញឱ្យមានការប្រកួតប្រជែងមូលធនមនុស្ស និងការផ្តោតយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យអប់រំ( The ACE blueprint 2008-2015) ។ សម្រាប់ប្រទេសកម្ពុជារដ្ឋាភិបាលក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទៅលើការអភិវឌ្ឍវិស័យអប់រំតាមរយៈ ការធ្វើកំណែទម្រង់អប់រំនានា សំដៅដល់ការអប់រំធនធានមនុស្សប្រកបដោយសក្តានុពលក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិក្នុងគោលដៅអភិវឌ្ឍប្រទេសក្លាយជា ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ ។( ផែនការយុទ្ធសាស្រ្តជាតិឆ្នាំ២០១៤-២០១៨) ដើម្បីលើកកម្ពស់វិស័យអប់រំ រាជរដ្ឋាភិបាលបានបង្កើនថវិកាជាតិសម្រាប់ក្រសួងអប់រំជាបន្តបន្ទាប់ពី១៥.៥២% ក្នុងឆ្នាំ២០១៣ ដល់១៨.៣០%ក្នុងឆ្នាំ២០១៧ ( ក្រសួងអប់រំយុវជន និងកីឡាស្ថិតិ និងសូចនាករឆ្នាំ២០១៧) ។ ស្របគ្នានេះដែរក្រសួងអប់រំបានរៀបចំ និងកសាងនូវគោលនយោបាយ ផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាព និងបានអនុវត្ត នូវសកម្មភាព និងកម្មវិធីជាច្រើន ដោយផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើការលើកកម្ពស់សិទ្ធិកុមារ ការថែទាំសុខភាព និងសុវត្ថិភាព បង្កឱកាសគ្រប់បែបយ៉ាងដើម្បីជួយឱ្យកុមារ គ្រប់រូបបានចូលរៀន ប្រកបដោយសមធម៌ និងគុណភាព។ ក្នុងន័យនេះដែរក្រសួងបានបន្តនូវយុទ្ធសាស្រ្ត នៃការអភិវឌ្ឍកម្មវិធីសាលាកុមារមេត្រីដើម្បីធានាបាននូវការគ្រប់គ្រង សាលារៀន ការរៀន និងបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព។

នាពេលបច្ចុប្បន្នបរិបទ នៃការអប់រំនៅក្នុងពិភពលោកត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការជំរុញឱ្យមានការបណ្តុះបណ្តាល នូវធានធានមនុស្សប្រកបដោយ គុណភាព សមធម៌ បរិយាបន្ន ការអប់រំពេញមួយជីវិត និងការអប់រំសម្រាប់ទាំងអស់គ្នា។ ក្នុងបរិបទនេះដែរ វិទ្យាស្ថានសិក្សាពេញមួយជីវិតរបស់អង្គការយូណេស្កូដែលជា វិទ្យាស្ថានមួយមិនគិតប្រាក់ចំណេញក៏បានបង្ហាញពីការសិក្សាពេញមួយជីវិត

សម្រាប់ប្រែក្លាយឱ្យកាន់តែល្អ «អនុវត្តល្អប្រកបដោយសក្តានុពលនៅអាស៊ីអាគ្នេយ៍» (EFA) បាននិយាយទាក់ទងទៅនឹងការសិក្សាពេញមួយសម្រាប់គ្រូបង្រៀន សម្រាប់ប្រជាពលរដ្ឋទូទៅដើម្បីបង្កើនធនធានមនុស្សសម្រាប់អភិវឌ្ឍប្រទេសជាតិ។ រីឯគោលដៅអភិវឌ្ឍសហសវត្សរ៍ (MDG) វិញដែលបានរៀបចំឡើងដោយកិច្ចប្រជុំកំពូលសហស្សវត្សរ៍ របស់អង្គការសហប្រជាជាតិដោយមានវត្តមានចូលរួមពីប្រទេសចំនួន ១៩១ប្រទេស ដែលមានគោលការណ៍ចំនួន៨ ដែលនៅក្នុងនោះក៏មានគោលការណ៍មួយនិយាយពីការលើកម្ពស់គុណភាពនៃការអប់រំផងដែរ។ ទាំងនេះសបញ្ជាក់ឱ្យឃើញថាពិភពលោកមានការយកចិត្តទុកដាក់ខ្លាំងទៅលើការអប់រំ ការបណ្តុះបណ្តាលធនធានមនុស្ស។

រីឯនៅក្នុងបរិបទប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលក៏បានដាក់ចេញនូវទស្សនវិស័យសម្រាប់ពេលខាងមុខគឺ តម្រូវឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ (សេចក្តីពព្រាងលើកទី១ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០៣០) ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ បច្ចុប្បន្ននេះក្រសួងអប់រំយុវជន និងកីឡា កំពុងដាក់ចេញនូវគោលនយោបាយអប់រំធំចំនួនពីរគឺទី១ ធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន សមធម៌ និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ទី២ ធានាភាពស័ក្តិសិទ្ធិ ភាពជាអ្នកដឹកនាំរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ម្យ៉ាងទៀតនៅក្នុងគោលបំណងរួមចំណែកក្នុងការសម្រេចយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រសួងបានដាក់ចេញនូវចក្ខុវិស័យ បេសកកម្ម និងវត្ថុបំណងក្នុងរយៈពេលវែងគឺការកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយ គុណភាព និងគុណធម៌ដ៏ល្អប្រសើរលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាក្លាយជាសង្គម រីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ រីបេសកកម្មរបស់ក្រសួងអប់រំយុវជន និងកីឡាគឺដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំនៃព្រះរាជាណាចក្រកម្ពុជាឱ្យឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ របស់កម្ពុជា និងការរីចម្រើនក្នុងតំបន់ និងសាកលលោក។ ចំណែកវត្ថុបំណងរយៈពេលវែង របស់ក្រសួងអប់រំយុវជន និងកីឡាគឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាឱ្យមានស្មារតីស្នេហាជាតិ មោទនភាពជាតិសីលធម៌ និងគុណធម៌ខ្ពស់ព្រមទាំងមានសុទិដ្ឋិនិយម ចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋខ្លួន។

ដូចនេះហើយដើម្បីឆ្លើយតបទៅនឹងបរិបទនៃការអប់រំនៅលើពិភពលោក និងការរីកចម្រើននៃពិភពលោក ក៏ដូចជាកម្រិតជឿនលឿននៃបណ្តាប្រទេសមួយចំនួនក្នុងតំបន់ ព្រមទាំងដើម្បីសម្រេចតាមទស្សនវិស័យរបស់រដ្ឋាភិបាល និងចក្ខុវិស័យ គោលនយោបាយរបស់សាម៉ីក្រសួងខ្លួនឯង ក្រសួងអប់រំយុវជន និងកីឡាបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវង្វាយតម្លៃការអនុវត្ត ការគ្រប់គ្រងតាមសាលារៀនស្របតាមកំណែទម្រង់ស៊ីជម្រៅរបស់រដ្ឋាភិបាលដើម្បីធ្វើឱ្យការអប់រំមានគុណភាព និងប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្សសម្រាប់អភិវឌ្ឍប្រទេសជាតិ។ ការអនុវត្តការគ្រប់គ្រងតាមសាលារៀនគឺជាយន្តការមួយដ៏ល្អប្រសើរ ដែលអាចរៀបចំឱ្យសាលារៀនសម្រេចបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព សម្រាប់

ការបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយចំណេះដឹង ចំណេះធ្វើ ឥរិយាបថល្អ និង ការចេះរួមរស់នៅជាមួយគ្នាដោយសុខសន្តិភាព និងការរីកចម្រើន។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បើយើងពិនិត្យ និងសង្កេតឱ្យបានស៊ីជម្រៅទៅលើប្រព័ន្ធនៃការអនុវត្តការគ្រប់គ្រងនៅតាមសាលារៀន យើងឃើញថាវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល( SBM) គឺជាប្រព័ន្ធនៃការគ្រប់គ្រងមួយដ៏ល្អប្រសើរដែលធ្វើឱ្យសាលារៀនក្លាយជាកន្លែងផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាប័ន្ន ប្រសិទ្ធភាព និងការលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ការគ្រប់គ្រងសាលារៀន មានគោលបំណងពីរគឺ(១) រៀបចំសាលារៀនឱ្យបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដោយកសាងសមត្ថភាពអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់សាលារៀន ដើម្បីធានាថាការគាំទ្រត្រូវបានផ្តល់ឱ្យសាលារៀនទាន់ពេលវេលា និង(២) កសាងសមត្ថភាពគ្រូបង្រៀនដើម្បីអនុវត្តកម្មវិធីសិក្សារបស់ជាតិ (សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន)។

ប្រព័ន្ធនៃការអនុវត្តការគ្រប់គ្រងតាម សាលារៀនេះក៏មានប្រទេសជាច្រើនបានធ្វើការសាកល្បង ឬណែនាំពីកំណែទម្រង់ការគ្រប់គ្រងតាមសាលារៀនដែលមានដូចជាប្រទេស កាណាដា ប្រទេសអូស្ត្រាលី សហរដ្ឋអាមេរិក ប្រទេសប្រេស៊ីល អេស្បាញ ចក្រភពអង់គ្លេស និងណូវែលសេឡង់ (World Bank, 2007) ។ ក្នុងនោះដែរប្រទេសកម្ពុជាយើងក៏បានចាប់ផ្តើមអនុវត្តគម្រោងកែលម្អការគ្រប់គ្រងសាលារៀន( Education Quality Improvement Project) ដូចបណ្តាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ចាប់តាំងពីឆ្នាំ ១៩៩៤-២០០៤បានផ្តល់មូនិធិដល់សាលារៀន ដោយប្រើប្រាស់អភិក្រម ការគ្រប់គ្រងតាមសាលារៀន ។ ជាលទ្ធផលបង្ហាញថា(១) មានការពិភាក្សាការងារជាប្រចាំ នៅថ្នាក់សាលារៀន ការរៀន និងបង្រៀន បរិស្ថានសាលារៀន ការចូលរៀន អត្រាឡើងថ្នាក់ ការចូលរួមរបស់សិស្សស្រី គណនេយ្យភាពក្នុងការគ្រប់គ្រងសាលារៀន ការដឹកនាំការឆ្លើយតបតម្រូវការមូលដ្ឋាន។ ប្រការនេះធ្វើឱ្យគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន បានទទួលការបំប៉នសមត្ថភាពជាប្រចាំ គោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនបានប្រសើរ និងធ្វើឱ្យសហគមន៍មានទំនុកចិត្តលើសាលារៀន។ ការផ្លាស់ប្តូរជាវិជ្ជមាន នៅសាលារៀនត្រូវបានបង្ហាញ តាមរយៈការរៀបចំឱ្យមាន ការប្រើប្រាស់បណ្ណាល័យ អប់រំយុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ បានជួយគាំទ្រដល់សាលារៀនផ្ទាល់ បានអនុវត្តគោលនយោបាយអប់រំប្រកបដោយភាពបត់បែន បានបង្កើតបណ្តាញគាំទ្រយ៉ាងរឹងមាំ រវាងថ្នាក់កណ្តាល អ្នកជំនាញការក្នុងក្រុង ស្រុក ខណ្ឌ អ្នកជំនាញការមកពីអង្គការសង្គមស៊ីវិល និងមានគំនិតផ្តួចផ្តើម លើការកសាងសមត្ថភាព ដែលនាំទៅរកភាពខ្លាំងនៃបំណិនគ្រប់គ្រង។

ទន្ទឹមនឹងភាពខ្លាំងទាំងនេះ ការគ្រប់គ្រងសាលារៀនក៏នៅជួបបញ្ហាប្រឈមមួយចំនួនដូចជាត្រូវការធនធាន និងជំនួយបច្ចេកទេសជាច្រើន ធនធានអាចមិនបានផ្តល់តាមតម្រូវការជាក់ស្តែង នៃសាលារៀនដែលជួបការលំបាក និន្តរភាពនៃការពិនិត្យតាមដាន និង ការធ្វើអធិការកិច្ចពីថ្នាក់ខេត្ត រាជធានី និងក្រុង

ស្រុក សង្កាត់ ខណ្ឌ ដោយ  កសាង ក្រុមការងារដាក់លាក់ មិនសូវបានទទួលលទ្ធផល និងសូវចុះពិនិត្យតាមដាន។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើការស្រាវជ្រាវមានគោលបំណងពិនិត្យទៅលើះ

ក. វង្វាយតម្លៃទៅលើស្ថានភាពទូទៅនៃការគ្រប់គ្រងតាមសាលារៀន។

ខ. ពិនិត្យតាមដានការអនុវត្ត ការគ្រប់គ្រងតាមសាលារៀន។

## ១.៤. សំណួរស្រាវជ្រាវ

ក. តើការអនុវត្តការគ្រប់គ្រងតាមសាលារៀនមានស្ថានភាពដូចម្តេចខ្លះ ?

ខ. ហេតុអ្វីបានជាត្រូវពិនិត្យតាមដានការអនុវត្តការគ្រប់គ្រងតាមសាលារៀន ?

## ១.៥. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៥.១. វិសាលភាព

ដើម្បីឱ្យការសិក្សាស្រាវជ្រាវវិភាគបានគ្រប់ជ្រុងជ្រោយ  វិសាលភាពនៃការស្រាវជ្រាវលើប្រធានបទ « វង្វាយតម្លៃការអនុវត្ត ការគ្រប់គ្រងតាមសាលារៀន » បានលើកយកវិទ្យាល័យចំនួន៥ នៅក្នុងខេត្តស្វាយរៀង  មកធ្វើការសិក្សាស្រាវជ្រាវតាមការ កំណត់របស់អ្នកស្រាវជ្រាវដែលផ្តោតទៅលើ ចំណុចសំខាន់មួយចំនួនដូចជាការគ្រប់គ្រងរដ្ឋបាលសិក្សាតាមសាលារៀន ការគ្រប់គ្រងធនធានមនុស្ស ការបង្រៀន និងរៀន និងការដឹកនាំ ការគ្រប់គ្រងសាលារៀន សិស្ស និងសេវាជួយសិស្ស  ហេដ្ឋារចនាសម្ព័ន្ធសាលារៀន មាតាបិតា និងសហគមន៍ជួយសិស្ស ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ។ វិទ្យាល័យទាំងនោះរួមមាន វិទ្យាល័យ ហ៊ុន សែនប្រសូតិ និងវិទ្យាល័យ ហ៊ុន សែន ស្វាយរំពារ ស្ថិតនៅក្នុងស្រុកស្វាយទាប វិទ្យាល័យ ហ៊ុន សែនក្រោលគោ ស្ថិតនៅក្នុងស្រុក ស្វាយជ្រុំ វិទ្យាល័យ ហ៊ុន សែន កំពង់រោទិ៍ និងវិទ្យាល័យ មិត្តភាពកម្ពុជាវៀតណាម ស្ថិតនៅក្នុងស្រុក កំពង់រោទិ៍។

### ១.៥.២. ដែនកំណត់

ដោយសារពេលវេលា និងឯកសារមិនគ្រប់គ្រាន់ការសិក្សាស្រាវជ្រាវប្រធានបទនេះបានរៀបចំកម្រងសំណួរសួរចំនួនបួនប្រភេទ សម្រាប់សួរទៅក្រុមគោលដៅចំនួនបួនគឺ គ្រូបង្រៀន នាយក សិស្សនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ និងគណៈគ្រប់គ្រងសាលារៀន ហើយបានចែកជូនលើសំណាកគំរូចំនួន៣២៨ នាក់ ក្នុងនោះមានលោកគ្រូចំនួន១១៤នាក់ សិស្សចំនួន១៩៤ គណៈនាយកចំនួន១៥នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន០៥នាក់។

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវបានចូលរួមមួយចំណែកក្នុងជ្រុងណាមួយក្នុងចូលរួមលើកកម្ពស់ការគ្រប់គ្រងតាមសាលារៀន និងសម្រាប់អង្គភាពពាក់ព័ន្ធយកទៅពិចារណា និងអ្នកស្រាវជ្រាវជំនាន់ក្រោយយកទៅស្រាវជ្រាវបន្តទៀត។

## ១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូកធំៗ៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង និងដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវ ជ្រាវមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទនេះដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូ និងប្រភេទគំរូ ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម ។

**ជំពូកទី៤៖** លទ្ធផល និងការពិភាក្សា នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងយក ទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អនិងចំណុចដែលត្រូវធ្វើការកែលម្អនៅក្នុងស្ថានភាពជាក់ស្តែងរបស់សាលារៀននីមួយៗ ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ ជាផ្នែកមួយទៀតដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនក្នុងបំណងចូលរួមចំណែក ធ្វើឱ្យស្ថានភាពបង្រៀននិងរៀនប្រសើរឡើងថែមទៀត។

# ជំពូកទី ២
# រំលឹកទ្រឹស្តី

# ជំពូកទី២ ៖ រំលឹកទ្រឹស្តី

## ២.១. និយមន័យពាក្យគន្លឹះ

តើវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនមានន័យដូចម្តេច?

ជាដំបូងមុននឹងឈានដល់ការបកស្រាយន័យទូទៅ នៃវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនឱ្យបានច្បាស់លាស់ និងស៊ីជម្រៅយើងត្រូវដឹងនូវពាក្យគន្លឹះក្នុងចំណងជើងប្រធានបទជាមុនសិន។ ពាក្យ« **វង្វាយតម្លៃការអនុវត្ត** » មានន័យថាការរៀបចំឱ្យមានការពិនិត្យតាមដាននូវរាល់សកម្មភាព ការប្រតិបត្តិការ និងផ្ទៀងផ្ទាត់លទ្ធ ផល។ រីពាក្យ « **ការគ្រប់គ្រងតាមសាលារៀន** » មានន័យថាគឺជាការធ្វើវិមជ្ឈការសិទ្ធិអំណាចពីថ្នាក់កណ្តាល ទៅថ្នាក់សាលារៀន (Caldwell, 2005) ។ ចំណែកឯលោក Wongs (2003,ទំព័រ 243) បានឱ្យនិយមន័យ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) ថាគឺជាការធ្វើវិមជ្ឈការនៃការសម្រេចចិត្តពីថ្នាក់នាយកដ្ឋានអប់រំទៅថ្នាក់សាលារៀន ទាក់ទងនឹងនិតិវិធីគ្រប់គ្រងបុគ្គលិក ការធ្វើផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុ និងបំណែងចែកកម្មវិធីសិក្សា។ បើតាមការលើកឡើងរបស់លោកHerman(1991,ទំព័រVi)។ ការគ្រប់គ្រងសាលារៀន គឺជារចនាសម្ព័ន្ធ និងជាដំណើរការមួយដែលអនុញ្ញាតឱ្យមានការសម្រេចចិត្តកម្រិតសាលារៀន ដែលទាក់ទងនឹងការគ្រប់គ្រងមន្រ្តី ការគ្រប់គ្រងថវិកា គោលនយោបាយ និងបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអភិបាលកិច្ចមូលដ្ឋានសាលារៀន។ ហើយវាក៏ជាដំណើរការមួយដែលមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងការសម្រេចចិត្តទាក់ទងនឹងការងារសាលារៀន នីមួយៗ។ ហើយតាមរយៈសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា **ការគ្រប់គ្រងសាលារៀន** គឺមានន័យថាការផ្តល់ស្វ័យភាពក្នុងការសម្រេចចិត្តទៅដល់ថ្នាក់កម្រិតមូលដ្ឋាន ដោយផ្អែកលើលទ្ធផលនៃការអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។

## ២.២. សកម្មភាពទូទៅនៃការវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន

ការធ្វើវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (ការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល) បានក្លាយជាគោលដៅមួយយ៉ាងសំខាន់របស់គោលនយោបាយអប់រំជាតិតាមរយៈកំណែទម្រង់ចុងក្រោយរបស់ក្រសួងអប់រំយុវជន និង កីឡា។ ការធ្វើវិមជ្ឈការមានលក្ខណៈជាប្រព័ន្ធផ្អែកលើស្វ័យភាពសាលារៀន សំដៅជំរុញការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ សេចក្តីណែនាំ និងគោលការណ៍ឱ្យសម្រេចបានតាមចំណុចដៅនៃផែនការយុទ្ធសាស្រ្តវិស័យអប់រំ។ ដើម្បីសម្រេចបានតាមផែនការនេះ ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយអង្គការសង្គ្រោះកុមារ បានរៀបចំចងក្រងឯកសារជំនួយស្មារតី នៃ **ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល** (SBM) នៅបឋមសិក្សាដោយផ្តោតលើចំណុចសំខាន់ៗចំនួន៤គឺ ៖ ១.ការគ្រប់គ្រង រដ្ឋ បាលសាលារៀន ២.ការងាររៀន-បង្រៀន និងអនុវត្តកម្មវិធីសិក្សា, ៣.ការគ្រប់គ្រងធនធានមនុស្ស ( ការអភិវឌ្ឍសមត្ថភាពគ្រូ និងការងារអធិការកិច្ច ) និង ៤.ការគ្រប់គ្រងថវិកា

សាលារៀន (សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលសម្រាប់បឋមសិក្សា ឆ្នាំ ២០១៧)។ ម្យ៉ាងទៀតនៅក្នុងបទបង្ហាញមួយរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានធ្វើឡើងក្នុងថ្ងៃទិវាគ្រូបង្រៀន ០៥តុលា ២០១៨ ក៏បានលើកយកកំណែទម្រង់ការគ្រប់គ្រងអប់រំ ទាំង៤ ចំណុចខាងលើនេះមកបង្ហាញរួមមាន៖

## ២.២.១ .ការគ្រប់គ្រងការ បង្រៀន និងរៀន

- **ការបង្រៀន**

ការបង្រៀនគឺជាការញ៉ាំងអ្នកដទៃឱ្យរៀន ប្រៀនឱ្យចេះ ឱ្យមានចំណេះដោយការបង្ហាត់បង្ហាញឱ្យចេះ។ ឧទាហរណ៍ បង្រៀនលេខ បង្រៀន អក្សរ ( ជួន ណាត )។ បើតាមផ្សេងទៀតការបង្រៀន ៖ ពាក្យថាការបង្រៀន (teaching) ក្លាយមកពីពាក្យបង្រៀន (teach) គឺសំដៅលើ ដំណើរការក្នុងថ្នាក់រៀនមួយដែលមានការចូលរួមពីគ្រូ ហើយមានអន្តរកម្មជាមួយសិស្ស ដែលក្នុង នោះសិស្សគឺជាអ្នកទទួលបាននូវឥទ្ធិពលពីដំណើរការនេះ។ បើតាមលោក Calfee,1986 បានលើក ឡើងថា ការបង្រៀនគឺជាការពន្យល់ (teaching is explanation) គឺមានន័យថាគ្រូមាននាទីក្នុងការ បង្ហាញផ្លូវដល់សិស្ស គ្រូជាអ្នកណែនាំ។ ក្នុងសេចក្តីពន្យល់របស់គាត់បានកំណត់ថា ការពន្យល់ល្អ គឺពិតជាមាន សារៈសំខាន់ណាស់ក្នុងដំណើរការបង្រៀន ព្រមជាមួយនឹងវិធីសាស្ត្របង្រៀនដែលល្អផងដែរ ដែលគ្រូត្រូវអនុវត្ត (Using Explanation as a Teaching Method: How Prepared Are High School Technology Teachers in Free State Province, South Africa?, Kamla-Raj 2014)។ បន្ថែមលើសនេះទៀតការបង្រៀនគឺជាគឺជាការផ្តល់នូវចំណេះដឹង (វិជ្ជាសម្បទា) ចំណេះធ្វើ( បំណិនសម្បទា) និង មានឥរិយាបថល្អក្នុងការរស់នៅ ( ចរិយាសម្បទា)( ការបង្ហាញវត្ថុបំណងនៅក្នុងមេរៀននីមួយៗ)

- **រៀន**

ពាក្យថា « រៀន»បើតាមវចនាក្រមរបស់សម្តេចសង្ឃរាជ ជួន ណាត មានន័យថា សិក្សា ខំសង្កេតឱ្យចេះទទួលយកចំណេះដឹង ហ្វឹកហាត់ រៀនឱ្យចេះ រៀនសូត្រ រៀនធ្វើការ រៀនដោយស្វាធ្យាយ រៀនដោយទន្ទេញចាំមាត់ ជាដើម។ ការរៀនផ្តោតសំខាន់ទៅលើសម្បទា ឬបញ្ញានិងការយល់ដឹងពីរបៀបដែលបុគ្គលិកលក្ខណៈ របស់មនុស្សមានឥទ្ធិពលទៅលើរបៀបដែលពួកគេមានប្រតិកម្មដោយខ្លួនឯងផ្ទាល់ ហើយឆ្លើយតបគ្នាក្នុងមជ្ឈដ្ឋានរៀនសូត្រ។ ការរៀនមានច្រើនរបៀប ប៉ុន្តែកំរូនៃការរៀនសូត្រគឺផ្អែកទៅលើ ការងារ និងបទពិសោធន៍ នៃសកម្មភាពផ្ទាល់ខ្លួន។ តាមរយៈការរៀនរបស់សិស្ស ត្រូវបានអង្គារយូណេស្កូ (UNESCO, Jacques Delor, 1996, Unesco) ពណ៌នាអំពីមុខនាទីនៃការរៀនមានដូចជា ៖

-រៀនដើម្បីដឹង (learn to know)

-រៀនដើម្បីចេះទទួលខុសត្រូវ (learn to response)

-រៀនដើម្បីចេះរស់នៅជាមួយគ្នា (learn to live together)

-រៀនដើម្បីចេះអនុវត្ត (learn to do)។

ជាពិសេសជាងនេះទៅទៀតដើម្បីឱ្យការងារបង្រៀន និងរៀនមានដំណើរការល្អគេត្រូវពិនិត្យទៅលើចំណុចដូចខាងក្រោម៖

- ការកែលម្អវិធីសាស្រ្តបង្រៀន និងការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល។
- ការកែលម្អការរៀន និងបង្រៀនជាពិសេសគឺវិធីសាស្រ្តបង្រៀន
- ការធ្វើវង្វាយតម្លៃសិស្សជាប្រចាំ (ការធ្វើតេស្ត)

ការងារបច្ចេកទេសលើការបង្រៀន និងរៀន៖

- **ការងារបច្ចេកទេសលើ ការបង្រៀន និងរៀន**

ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សា ការបង្រៀន និងរៀន មិនអាចកាត់ផ្តាច់ពីតួនាទីរបស់អ្នកដឹកនាំសាលារៀនដែលជាកត្តាជំរុញដ៏សំខាន់ ជានាដល់គុណភាពក្នុងការអនុវត្តការងាររបស់គ្រូបង្រៀន។ ស្តង់ដានេះជួយនាយក នាយិកាសាលារៀនឱ្យទទួលបានជោគជ័យក្នុងការធ្វើឱ្យសម្រេចចក្ខុវិស័យ បេសកកម្ម និង គោលដៅ។ នាយក នាយិកាសាលារៀនចាំបាច់ ត្រូវដឹកនាំការអនុវត្ត និងការកែលម្អកម្មវិធីសិក្សា ការបង្កើត បរិស្ថាន និងបរិយាកាសសិក្សា ការធ្វើអធិការកិច្ច និងការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងការ ផ្តល់លទ្ធផលសិក្សា។ សូចនាករសំខាន់ៗ ដែលស្តែងចេញអំពីគុណផលនៃស្តង់ដាទី៤ នេះមានដូចខាងក្រោម៖

- ពិនិត្យកែលម្អកម្មវិធីសិក្សា និងធនធានសិក្សាឱ្យបានទៀងទាត់
- ដឹកនាំអភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា
- រៀបចំប្រជុំបុគ្គលិក និងសហគមន៍ក្នុងការកែលម្អកម្មវិធីសិក្សា និងការបង្រៀន និងរៀន
- រិះរកវិធីសាស្រ្តល្អៗ ដើម្បីឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព
- ធានាថាគ្រូបង្រៀនអាចបង្រៀនដល់ សិស្សគ្រប់ប្រភេទ (ពិការជនជាតិភាគតិច..........)
- ធានាថាគ្រូបង្រៀនផ្តល់ការបង្រៀនឱ្យចប់កម្មវិធីសិក្សា និងស្របតាមតម្រូវការរបស់សិស្ស
- ជំរុញគ្រូបង្រៀនឱ្យលើកទឹកចិត្តសិស្សឱ្យធ្វើស្វ័យសិក្សា ជាប្រចាំដោយខ្លួនឯង
- ធានានូវបរិយាកាសរៀនសូត្រល្អប្រសើរ ប្រកបដោយភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់
- បង្កើតឱ្យមានបរិស្ថានសិក្សាល្អ មានអនាម័យ សណ្តាប់ធ្នាប់ របៀបរៀបរយ និងគ្មានគ្រោះថ្នាក់
- រក្សាបាននូវវប្បធម៌សាមគ្គីភាព សន្តិភាព និងការគោរពគ្នាទៅវិញទៅមកតាមឋានានុក្រម
- ធានាថាគ្រូប្រើចិត្ត-គរុកោសល្យច្បាស់លាស់ក្នុងការផ្ទេរចំណេះដឹងឱ្យសិស្ស
- ធានាថាគ្រូ សិស្សមានសិទ្ធិប្រើប្រាស់សម្ភារ និងធនធានសិក្សាទាំងឡាយដោយឈរលើស្មារតីជួយថែរក្សាឱ្យបានគង់វង្ស
- បែងចែកភារកិច្ច និងការទទួលខុសត្រូវដល់បុគ្គលិក សិស្សតាមសមត្ថភាព និងជំនាញ

- ធានាការប្រជុំបច្ចេកទេសឲ្យបានទៀងទាត់ និងមានប្រសិទ្ធភាព
- រៀបចំ ធ្វើគម្រោងផែនការអធិការកិច្ចដើម្បីជួយគ្រូ និងអនុវត្តផែនការនេះឱ្យបានទៀងទាត់
- ធានាថាគ្រូបង្រៀនមានផែនការបង្រៀន និងអនុវត្តផែនការនោះបានត្រឹមត្រូវជាប្រចាំ
- សង្កេតការបង្រៀនរបស់គ្រូ និងផ្តល់ព័ត៌មានត្រឡប់ប្រកបដោយការយោគយល់និងការលើកទឹកចិត្ត
- វាយតម្លៃប្រសិទ្ធភាពមេរៀនដោយសង្កត់ធ្ងន់លើការសម្រេចវត្ថុបំណងមេរៀន
- លើកទឹកចិត្តដល់គ្រូបង្រៀនដែលបំពេញការងារបានល្អ
- ផ្តល់ឱកាសឱ្យគ្រូបង្រៀនចែករំលែកបទពិសោធល្អៗដល់គ្រូដទៃទៀត
- ផ្តល់ឱកាសឱ្យគ្រូបង្រៀនបានទស្សនកិច្ចសិក្សានៅសាលាដែលល្អ
- សហការជាមួយគ្រូបង្រៀនក្នុងការវាយតម្លៃការសិក្សារបស់សិស្ស
- ធានាការវាយតម្លៃប្រកបដោយស្មើភាព តម្លាភាព យុត្តិធម៌ និងទៀងទាត់
- ធានាថាលទ្ធផលនៃការវាយតម្លៃត្រូវបានដាក់ឱ្យភាគីពាក់ព័ន្ធប្រើប្រាស់
- ធានាថាលទ្ធផល នៃការវាយតម្លៃត្រូវបានប្រើប្រាស់ជាប្រយោជន៍ដល់ការកែលម្អកិច្ចតែងការបង្រៀនសម្រាប់ឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាព
- អនុវត្តការប្រើប្រាស់កម្មវិធីសិក្សា ខ្លឹមសារមេរៀន និងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន
- រៀបចំផែនការអនុវត្តសកម្មភាពបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព
- តាមដានសកម្មភាពផែនការអនុវត្តសកម្មភាពបង្រៀន និងរៀន
- រៀបចំក្រុមបច្ចេកទេស និងប្រជុំបច្ចេកទេស
- កសាងខ្លឹមសារមេរៀនឱ្យស្របតាមកម្មវិធីសិក្សាគោល
- ការសង្កេតការបង្រៀន និងផ្តល់ព័ត៌មានត្រឡប់បានទៀងទាត់
- រៀបចំថ្នាក់និទស្សន៍ និងការសិក្សាស្រាវជ្រាវមេរៀន
- ប្រើប្រាស់ចំណេះដឹង និងបំណិនក្នុងការរៀបចំកិច្ចតែងការបង្រៀន
- រៀបចំសម្ភារៈសម្រាប់ដំណើរការបង្រៀន និងរៀន
- ផលិតសម្ភារបង្រៀនឱ្យឆ្លើយតបនឹងកម្មវិធីសិក្សា
- វាយតម្លៃលទ្ធផលសិក្សា និងសរសេររបាយការណ៍អំពីវឌ្ឍភាពនៃការបង្រៀន និងរៀន
- ពិនិត្យតាមដាន និងវាយតម្លៃសកម្មភាព ដើម្បីកែលម្អលទ្ធផលសិក្សា
- ស្វែងរកចំណុចខ្លាំង និងចំណុចខ្វះខាត ដើម្បីកែលម្អលើវិធីសាស្ត្របង្រៀន
- សម្របសម្រួល និងជំរុញសកម្មភាពចែករំលែកចំណេះដឹង និងបទពិសោធទៅវិញទៅមក (បង្កើតកម្មវិធីអ្នកមានបទពិសោធច្រើនឱ្យជួយអ្នកមានបទពិសោធន៍តិច)

## ២.២.២. ការគ្រប់គ្រងរដ្ឋបាលសាលារៀន

នៅក្នុងផ្នែកការគ្រប់គ្រងរដ្ឋបាលសាលារៀនយើងផ្តោតយកចិត្តទុកដាក់សំខាន់ទៅលើការគ្រប់គ្រងរបស់នាយកសាលារៀន ទៅលើការគ្រប់គ្រងរដ្ឋបាលទូទៅរបស់សាលារៀន ដែលជាតួនាទីដ៏សំខាន់បំផុត ដែលនាយកសាលាត្រូវតែបំពេញឱ្យបានល្អបំផុតនៅក្នុងដំណើរការសាលារៀនមួយ។ ក្នុងផ្នែកនេះដែរយើងក៏ត្រូវស្វែងយល់ពី តួនាទី ភារកិច្ចរបស់នាយកសាលាផងដែរ។

- **ការដឹកនាំគ្រប់គ្រងរបស់នាយក**

ការស្វែងយល់ពីអត្ថន័យនៃការដឹកនាំនិងគ្រប់គ្រង គឺ ជារឿងសំខាន់មុនឈានដល់ការស្វែងយល់ពីការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា។ ដូចដែល បានលើកឡើងខាងលើស្រាប់នាយកសាលាត្រូវមានគុណសម្បត្តិដឹកនាំ និងគ្រប់គ្រងសាលា ដើម្បីជានានូវលទ្ធផលរៀន និងបង្រៀនប្រសើរ។ ក្នុងក្របខណ្ឌជាក់លាក់ មួយជាតុសំខាន់នៃការដឹកនាំគឺ ធ្វើឲ្យមានឥទ្ធិពលលើដំណើរការអ្វីមួយក្នុង ស្ថាប័ន និងក្រុម (OECD,2001)។ បន្ថែមលើនេះលោក( yukl1989) ឲ្យនិយមន័យថា ការដឹកនាំគឺជាដំណើរការធ្វើយ៉ាងណាឱ្យស្ថាប័នមួយនិងក្រុមមួយអាចមានលទ្ធភាព ដើម្បីសម្រេចបាននូវលទ្ធផលដែលរំពឹងទុក តាមសកម្មភាពនានាដែលបានកំណត់ ។

មិនខុសឆ្ងាយពីអ្វីដែលអស់លោកផ្សេងៗបានលើកឡើងលោក (Zaleznik2004) បានពន្យល់ថា អ្នកដឹកនាំនិងគ្រប់គ្រងគឺជាក្រុមមនុស្សផ្សេងៗគ្នាដែលមានការគិត និងធ្វើអ្វីដោយឡែកពីគ្នាហើយពួកគេផ្តោតលើការធ្វើកិច្ចការដើម្បីឱ្យមានការផ្លាស់ប្តូរដោយមានការប្តេជ្ញាចិត្តខ្ពស់។ លើសពីនេះទៅទៀតពួកគេព្យាយាមរកដំណោះស្រាយនានាធ្វើឱ្យមានកិច្ចដំណើរការការងាររលូនដើម្បីសម្រេចគោលដៅរបស់អង្គភាព (Zaleznik2004)។

ក្នុងបរិបទផ្សេងៗពាក្យថា ការដឹកនាំសាលារៀនតែងតែអាចជំនួសបាននូវពាក្យការគ្រប់គ្រង សាលារៀន និងរដ្ឋបាលសាលារៀន។ ទោះបីជាគោលគំនិតទាំងបីអាចជាន់គ្នាគេតែងតែប្រើប្រាស់ វាដើម្បីសង្កត់ន័យផ្សេងៗគ្នាដូចជា៖ អ្នកគ្រប់គ្រងធ្វើកិច្ចការឱ្យត្រូវ រីឯអ្នកដឹកនាំធ្វើកិច្ចការដែលត្រូវ (Bennis&Nanus,1997)។ ក្នុងន័យនេះពេលដែលការដឹកនាំជំរុញលទ្ធភាពការលើកទឹកចិត្ត និងឥរិយាបថរបស់សមាជិកក្រុមក្នុងការប្រតិបត្តិការងារឲ្យបានសម្រេចនោះ ការគ្រប់គ្រងជាកត្តាមួយដែលអាចជំរុញឲ្យដំណើរការនេះ រលូននិងបានផលប្រកបដោយប្រសិទ្ធភាព (Bush andGlover,2003)។ លោក (Dimmock and walker1999)ទទួលស្គាល់ថាការដឹកនាំសាលារៀន ការគ្រប់គ្រង សាលា រៀន និងរដ្ឋបាលសាលារៀនមានសភាពលក្ខណៈ និងគោលគំនិតខុសគ្នា តែលោក ក៏ទទួលស្គាល់ផងដែរថា នាយកសាលារៀនមួយត្រូវមាន ការទទួលខុសត្រូវរាល់កិច្ចការទាំងបីនេះ។

លោក (Sindhvad2009) ធ្វើការពន្យល់ថា ជាលក្ខណៈទ្រឹស្តី នាយកសាលារៀន មានតួនាទីបួន សំខាន់។ ទីមួយគឺការគ្រប់គ្រងសាលា ដែលរួមមានការគ្រប់គ្រងសម្ភារនានា បុគ្គលិក ការចងក្រងនិងប្រមូលព័ត៌មាន ព្រមទាំងការកត់ត្រានូវការចំណាយផ្សេងៗរបស់សាលា។ ទីពីរគឺការទំនាក់ទំនងទាំងជាមួយថ្នាក់លើនិងស្ថាប័នផ្សេងៗទៀត។ ទីបីគឺទំនាក់ទំនងជាមួយសហគមន៍ និងដៃគូអភិវឌ្ឍនានា ។ ទីបួនគឺ ការគ្រប់គ្រងការបង្រៀន និងរៀនដើម្បីធានាឲ្យមានគុណភាពល្អប្រសើរ ។

- **ភារកិច្ចតួនាទីឥទ្ធិពលនៃការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលារៀន**

ដើម្បីដំណើរការ ការងាររបស់ខ្លួនបានល្អ នាយកសាលាមានភារកិច្ចទទួលខុសត្រូវលើការងារ រដ្ឋបាល ការងារបច្ចេកទេសគរុកោសល្យ និងការងារទំនាក់ទំនង ។

**១.ការងារគ្រប់គ្រងរដ្ឋបាល**

- ធានាដំណើរការល្អរបស់សាលារៀន
- អនុវត្តបទបញ្ញាសិក្សា និងអត្ថបទណែនាំផ្លូវការរបស់ក្រសួង
- ចែកសិស្សតាមថ្នាក់
- ចាត់តាំងបែងចែកភារកិច្ចដល់បុគ្គលិកក្រោមឱវាទតាមសំណើរបស់ក្រុមប្រឹក្សារបស់គ្រូបង្រៀន
- ធ្វើការដោយយកចិត្តទុកដាក់លើតួនាទីរដ្ឋបាលរបស់ខ្លួន
- ធានានិយ័តភាពក្នុងការសិក្សា
- ត្រៀមការងារ ការពារបរិស្ថាន សោភណភាព និងអនាម័យ ក្នុងសាលារៀន ទីធ្លាថ្នាក់រៀន តុប លក់នំចំណី ដើមឈើធ្វើម្លប់ សួនផ្កា
- ធានាឱ្យសាលារៀន អាចបំពេញបាននូវសេវា សាធារណៈ ទទួលកុមារ និងការពារកុមារ
- រក្សាសណ្តាប់ធ្នាប់ និងវិន័យក្នុងគ្រឹះស្ថានសិក្សា
- ចូលរួមបង្កើតក្រុមប្រឹក្សានានា
- ចាត់តាំងប្រជុំ និងដឹកនាំការប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មការនានា
- ចាត់ចែងការចូលរួមក្នុងសកម្មភាពសង្គម
- រៀបចំចាត់ចែង ការបណ្តុះបណ្តាលនៅនឹងកន្លែង ឬបញ្ជូនទៅបណ្តុះបណ្តាលនៅថ្នាក់លើ
- រៀបចំទីចាត់ការសាលារៀន
- រៀបចំការងារលិខិតស្នាម និងរក្សាទុកលិខិតស្នាម
- បែងចែកមធ្យោបាយសម្រាប់ធ្វើការងារផ្សេងៗសមស្របទៅតាមការងារ និងកម្រិតថ្នាក់នីមួយៗ
- ធ្វើរបាយការណ៍ជូនថ្នាក់លើអំពីសកម្មភាពនានារបស់សាលារៀន
- ធ្វើជាអាជ្ញាកណ្តាលផ្សះផ្សាទំនាស់ផ្សេងៗដែលកើតមានឡើងនៅក្នុងសាលារៀន
- កសាងផែនការសាលារៀននិងបែងចែកកម្មវិធីការងារប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ
- ធ្វើតារាងស្ថិតិនានា
- គ្រប់គ្រងមូលដ្ឋានសម្ភារៈ ម៉ត់ចត់ដោយចៀសវាងការខ្ជះខ្ជាយ បញ្ជីសារពើភណ្ឌ បញ្ជីចែក ចាយ បញ្ជីបញ្ចូលឃ្លាំង
- ត្រួតពិនិត្យអគារសិក្សា
- ចាត់តាំងការប្រើប្រាស់ និងថែរក្សាអគារសិក្សា
- ទទួលខុសត្រូវជាមួយគណៈកម្មការ ទ្រទ្រង់សាលារៀន នូវចំណូលចំណាយថវិកា របស់ សាលារៀន

**២. ការងារគ្រប់គ្រងបច្ចេកទេសគរុកោសល្យ៖ ជាការគ្រប់គ្រងសកម្មភាពបង្រៀន និងរៀន**

- រក្សាឲ្យបានខ្ជាប់ខ្ជួននូវតួនាទីជាទីប្រឹក្សាគរុកោសល្យ
- ជាអ្នកជីវចលនា គរុកោសល្យ
- ផ្សព្វផ្សាយនិងណែនាំអនុវត្តនូវសៀវភៅសិក្សាថ្មី សារាចរណែនាំនានាឲ្យបាន ទូលំទូលាយ
- ត្រួតពិនិត្យ ការអនុវត្តកម្មវិធីសិក្សាគ្រប់ថ្នាក់ ខ្លឹមសារត្រូវតាមមុខវិជ្ជា ការប្រើវិធីសាស្ត្រ ថ្មីដែល គ្រូណែនាំ និងជួយសិស្សឲ្យធ្វើសកម្មភាពច្រើន
- រៀបចំកាលវិភាគប្រចាំសប្តាហ៍ទៅតាមថ្នាក់នីមួយៗ
- ចូលរួមបំប៉នគ្រូតាមរយៈទស្សនៈកិច្ចសិក្សាសាលារៀនត្រួតពិនិត្យកិច្ចតែងការបង្រៀន ការដឹកនាំការបង្រៀន ការប្រើប្រាស់សៀវភៅសិស្ស សៀវភៅគ្រូ បញ្ជីពិន្ទុ បញ្ជីហៅឈ្មោះសិស្ស ការងាររដ្ឋបាលថ្នាក់រៀន
- ជានាការសហការចាំបាច់រវាងគ្រូទាំងអស់ក្នុងសាលារៀនដើម្បី ជាគុណប្រយោជន៍ដល់ការ ពង្រឹងគុណភាពបង្រៀន និងរៀន
- ណែនាំឲ្យគ្រូបង្រៀនគ្រប់មុខវិជ្ជាទាំងអស់ ចៀសវាងការរំលងមុខវិជ្ជាណាមួយដែលខ្លួនមិន ពេញចិត្ត ឬមិនមានបំណិនប្រសប់
- ផ្គត់ផ្គង់សៀវភៅសិក្សា និងឯកសារ
- ជំរុញការប្រជុំក្រុមបច្ចេកទេសតាមចង្កោមថ្នាក់ដោយមានរបៀបវារៈច្បាស់លាស់
- ត្រួតពិនិត្យកិច្ចតែងការបង្រៀនរបស់បុគ្គលិក
- ចូលរួមបណ្តុះបណ្តាលអនាគតនាយកសាលារៀន
- លើកទឹកចិត្តគ្រូឲ្យស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗ និងប្រើប្រាស់សម្ភារឧបទេសថ្មីៗដើម្បីជួយសម្រួលដល់ការបង្រៀន និងរៀន
- ផ្តល់យោបល់ និងជួយគ្រូក្នុងការអនុវត្តវិជ្ជាជីវៈ
- រក្សាឲ្យបាននូវបរិយាកាសគរុកោសល្យក្នុងសាលារៀននិងក្នុងថ្នាក់រៀន
- បន្តអនុវត្តមតិណែនាំរបស់អធិការអប់រំ
- ចាត់តាំងកសាងសម្ភារៈឧបទេសសម្រាប់ការបង្រៀន និងរៀន
- ចូលបង្រៀនជំនួសនៅពេលមានអវត្តមានគ្រូ
- គ្រប់គ្រងថែរក្សារាល់លិខិតបច្ចេកទេស
- ចាត់តាំងរាល់សកម្មភាពក្រៅម៉ោងសិក្សាដូចជា ទស្សនៈកិច្ចសិក្សាសារៈមន្ទីរ ពិនិត្យដកពិសោធន៍នៅតាមអង្គភាពផលិតនានា ចូលរួមក្នុងចលនាភូមិស្អាត ហូបស្អាត ផឹកស្អាត និង ការរស់នៅស្អាត
- ជំរុញណែនាំសិស្សានុសិស្សឱ្យរៀននៅផ្ទះ និងនៅក្លឹបសិក្សា« រៀនថ្ងៃមិនគ្រប់រៀនយប់បន្ថែម » ។
- ជានាជំរុញការបញ្ចប់កម្មវិធីសិក្សាគ្រប់ថ្នាក់ និងគ្រប់មុខវិជ្ជាប្រកបដោយ គុណភាព ។

## ២.២.៣ .ការងារទំនាក់ទំនង

ដើម្បីមានប្រសិទ្ធភាពនៃការងារគ្រប់គ្រងអង្គភាពសាលារៀន ការងាររដ្ឋបាល និងការងារបច្ចេកទេសគរុកោសល្យនោះ ទោះបីមានដំណើរការល្អយ៉ាងណាក៏ដោយ ក៏នាយកសាលារៀន មិនអាចដឹកនាំសាលារៀនប្រកបដោយប្រសិទ្ធភាពបានដែរប្រសិនបើខ្វះទំនាក់ទំនងផ្ទៃក្នុង ក្នុងសាលារៀនមាន នាយករង គ្រូបង្រៀន បុគ្គលិកផ្សេងៗនិងសិស្សានុសិស្ស។ ទំនាក់ទំនងខាងក្រៅសាលាមាន មាតាបិតា

សិស្ស សហគមន៍ អាជ្ញាធរដែនដី ព្រះចៅគ្រូអធិការ ព្រះសង្ឃ លោកតាអាចារ្យ គណៈកម្មការវត្ត និង សប្បុរសជនជាតិនិងអន្តរជាតិ ។

គាត់បានរីកចម្រើនទាក់ទងទៅនឹងការដឹកនាំ អភិបាលកិច្ចនិងការគ្រប់គ្រងទូទៅនៅក្នុងសាលា (USAID,2010)។

នៅប្រទេសហ្វីលីពីន តួនាទីរបស់នាយកសាលាក្នុងការដឹកនាំ និងគ្រប់គ្រងមានដែនកំណត់ជាពិសេសការធ្វើសេចក្តីសម្រេចចិត្តណាមួយ ក្នុងកិច្ចដំណើរការសាលារៀនរបស់ខ្លួន។ ប៉ុន្តែចាប់ពីឆ្នាំ ២០០១ រដ្ឋាភិបាលហ្វីលីពីនបានបង្កើតច្បាប់ថ្មីដើម្បីកំណត់តួនាទីរបស់នាយកសាលាដើម្បីឲ្យពួកគាត់ មានសិទ្ធិសម្រេចចិត្តច្រើនទាក់ទងនឹងកិច្ចការដឹកនាំនិងគ្រប់គ្រងសាលា ក្នុងគោលបំណងធានាឱ្យមាន តម្លាភាព ការទទួលខុសត្រូវ និងគណនេយ្យភាពដល់សហគមន៍ (Sindhad,2009)។ តាមរយៈនេះនាយកសាលាត្រូវបានគេផ្តល់អំណាច និងមានឱកាសបណ្តុះបណ្តាលកម្រិតវិជ្ជាជីវៈក្នុងការដឹកនាំ និងគ្រប់គ្រងបានល្អប្រសើរជាងមុន។

នៅប្រទេសថៃក៏មិនខុសពីប្រទេសដទៃ ប្រទេសនេះបានទទួលស្គាល់និងបានធ្វើកំណែទម្រង់ឲ្យសមស្របនឹងបច្ចុប្បន្នភាពនៃការវិវត្តវិស័យអប់រំសកល ជាពិសេសការដឹកនាំ និងគ្រប់គ្រងកម្រិតសាលារៀន។ ក្នុងបរិបទនេះ ការផ្តល់អំណាចឲ្យនាយកសាលា ធ្វើការសម្រេចចិត្តទាក់ទងនឹងការអភិវឌ្ឍ និងគ្រប់គ្រងដំណើរការសាលារៀន ជារឿងសំខាន់ហើយជាចំណុចកំណែទម្រង់ដំបូង សម្រាប់ធានាឲ្យការបង្រៀននិងរៀន កាន់តែមានភាពល្អប្រសើរ (Nenyod,2002)។ ក្នុងន័យនេះ នាយកសាលា ដើរតួនាទីយ៉ាងសំខាន់ជាងអ្នកណាទាំងអស់ក្នុងការសម្របសម្រួល និងគ្រប់គ្រងកិច្ចការនានាទាក់ទងនឹងសាលា គ្រូបង្រៀនដំណើរការរៀនរបស់សិស្ស និងការធ្វើទំនាក់ទំនងជាមួយសហគមន៍ (Shoraku,2009)។ ក្នុងស្ថានភាពនេះផងដែរនាយកសាលារៀនតោងតែចៀសវាងមិនរួចចំណាយ ពេលច្រើនដើម្បីរៀបចំ ចាត់ចែង និងបំពេញកិច្ចការរដ្ឋបាលរបស់សាលា (Sakulsumpoapol, 2010)។

ការសិក្សាមួយនៅប្រទេសតួកគី បានបង្ហាញលទ្ធផលថានាយកសាលាពីមុនមួយចំនួនតែងតែយកលំនាំការគ្រប់គ្រងបែបចាស់មកអនុវត្តន៍ ជាជាងយករបៀបដឹកនាំថ្មីក្នុងកិច្ចដំណើរការអភិវឌ្ឍរបស់សាលារៀន។ ប៉ុន្តែទម្លាប់ទាំងនេះត្រូវបានកែប្រែជា បណ្តើរៗ ដើម្បីធានានូវការទទួលខុសត្រូវយ៉ាង មានប្រសិទ្ធភាព (Gumuseli,2009) ។

ការសិក្សាមួយនៅប្រទេសអូស្ត្រាលី ស្តីពីតួនាទីរបស់នាយកសាលា ទាក់ទងនឹង ការដឹកនាំដំណើរការបង្រៀននិងរៀន ការអភិវឌ្ឍសមត្ថភាពបុគ្គលិកសិក្សា ការជ្រើសរើសគ្រូ ការគ្រប់គ្រងបុគ្គលិកនិងសិស្ស ការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំផែនការថវិកានិងហិរញ្ញវត្ថុរបស់សាលារៀន បានបង្ហាញថា តួនាទីរបស់នាយកសាលាមិនមានការប្រែប្រួលឡើយពេលដែលអំណាចនៃការគ្រប់គ្រង នៅមូលដ្ឋានមានការកើនឡើង។ ប៉ុន្តែតួនាទីរបស់ពួកគាត់មានទំនាក់ទំនងនឹងការងារជាមួយក្រុមប្រឹក្សាភិបាល សហគមន៍ ដើម្បីសម្រេចចិត្ត ព្រមទាំងរៀបចំផែនការថវិកាសាលានិងកិច្ចការទំនាក់ទំនង នានាជាមួយអាណាព្យាបាលសិស្ស (Sahid,2004)។

ទាក់ទងនឹងតួនាទី ក៏ដូចជាការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលានៅប្រទេសអាហ្វ្រិកខាងត្បូងវិញ ការរៀបចំផែនការថវិកានិងគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពជារឿងសំខាន់បំផុតហើយវាកំណត់ឱ្យមានប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រទាំងមូល ក៏ដូចជាគោលដៅនៃការសិក្សារៀនសូត្ររបស់សិស្សទាំងមូល ( Hansraj,2007 )។

ជារួមតួនាទីក្នុងការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាតាមបណ្តាប្រទេសនានាក្នុងតំបន់និង ពិភពលោកមានការប្រែប្រួលទៅតាមបរិបទសង្គមនិងគោលនយោបាយជាពិសេស ការវិវត្តសកលក្នុង វិស័យអប់រំក្នុងក្របខណ្ឌពង្រឹងគុណភាព និងការវិវត្តប្រកបដោយនិរន្តភាព។

ម្យ៉ាងទៀតការផ្សារភ្ជាប់សាលារៀន និងសហគមន៍ គឺ ជាការរំពឹងទុកដ៏ជាក់លាក់របស់គណៈគ្រប់គ្រងសាលាក្នុងការធ្វើឱ្យមាន គុណភាពនៃការបង្រៀន និងរៀនបានប្រព្រឹត្តទៅកាន់តែល្អប្រសើរ វាជាថាមពល ជាប្រភពមិនចេះរីងស្ងួត និងមិនអាចខ្វះបានរបស់សាលារៀនក្នុងដំណើរការអភិវឌ្ឍវិស័យអប់រំឱ្យមានជីវិតស្រស់បំព្រង ប្រកបដោយភាពសុខដុម។

ដើម្បីសម្រេចបានតាមគោលដៅនៃស្តង់ដានេះ នាយក នាយិកាសាលារៀន ត្រូវបំពេញនូវសមត្ថភាព និងសូចនាករដូចខាងក្រោម៖

- បង្កើតគោលការណ៍ក្នុងការទំនាក់ទំនងជិតស្និទ្ធ និងយូរអង្វែងជាមួយសហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធនានា ដើម្បីអភិវឌ្ឍន៍សាលារៀន
- កសាងបណ្តាញទំនាក់ទំនងជាមួយអ្នកឯកទេស និងអ្នកជំនាញលើគ្រប់វិស័យដើម្បីចូលរួមអភិវឌ្ឍការអប់រំ ក្នុងនោះមានវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យសុខាភិបាល វិស័យកសិកម្ម វិស័យឧស្សាហកម្ម សិប្បកម្ម សុវត្ថិភាពចរាចរណ៍ វិស័យវប្បធម៌ ទេសចរណ៍ ព័ត៌មាន សាសនា...។
- កសាងទំនុកចិត្ត ដោយខិតខំបង្កើនសមិទ្ធផល លទ្ធផលសិក្សាល្អ គោរពឆន្ទៈរួម មានការលះបង់ មានចក្ខុវិស័យ បេសកកម្ម រចនាសម្ព័ន្ធ
- ផ្សព្វផ្សាយរាល់សមិទ្ធផលការងាររបស់សាលាដែលសហគមន៍បានចូលរួមអភិវឌ្ឍន៍
- ពង្រឹងការគ្រប់គ្រង និងដឹកនាំ ដោយបង្ហាញឱ្យឃើញច្បាស់អំពីផែនការ ការទទួលខុសត្រូវខ្ពស់ តម្លាភាព និងមិនប្រកាន់បក្សពួក
- បង្កលក្ខណៈងាយស្រួលដល់អ្នកពាក់ព័ន្ធចូលរួម ដោយផ្តល់ការគាំទ្រ ការផ្តល់កិត្តិយស និងការផ្តល់ឱកាសចូលរួមក្នុងសកម្មភាពនានា
- ស្តាប់ និងទទួលយកនូវគំនិត ឬ យោបល់រិះគន់ ស្ថាបនាពីសហគមន៍ និងភាគីពាក់ព័ន្ធ។

## ២.២.៤ .តួនាទីជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន ស្តង់ដាទី )៣ របស់នាយក(

ការគ្រប់គ្រងរដ្ឋបាលសាលារៀន ជាភារកិច្ចសំខាន់មួយរបស់អ្នកដឹកនាំក្នុងការធ្វើឱ្យប្រសើរឡើងផ្នែកគុណភាព និងប្រសិទ្ធភាពដើម្បីធ្វើការវាស់ស្ទង់ និងដោះស្រាយបញ្ហាចំពោះមុខលើការរៀបចំអង្គភាពមួយដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានា សំដៅធ្វើឲ្យមានការអភិវឌ្ឍលើគ្រប់ផ្នែក ដូចជា បរិស្ថាន វិន័យការងារ ការផ្តល់សេវា ការគ្រប់គ្រងស្ថិតិបុគ្គលិក ថ្នាក់ សិស្ស ការរៀបចំផែនការថវិកា និងនិយតភាពការងារ

ការប្រមូលទិន្នន័យទៅតាមគោលការណ៍ច្បាប់ ដើម្បីបង្ហាញភស្តុតាងជាក់លាក់ក្នុងការអនុវត្តអ្វីដែលថ្មីរបស់នាយក នាយិកាសាលារៀន ។ សូចនាករសំខាន់ៗ ដែលស្តែងចេញអំពីគុណផលនៃស្តង់ដាទី៣ នេះមានដូចខាងក្រោម៖

- ស្វែងយល់អំពីសុខទុក្ខរបស់គ្រូ និងបុគ្គលិកក្នុងសាលា ដោយសិក្សាអំពីស្ថានភាពជីវភាពរបស់គ្រូ ព័ត៌មាននានាពាក់ព័ន្ធនឹងគ្រូបង្រៀន (ប្រវត្តិ ទីកន្លែង ស្នាក់នៅ ឈ្មោះ លេខទូរស័ព្ទ ចំណង់ចំណូលចិត្ត និងថ្ងៃ ខែ ឆ្នាំចូលនិវត្តន៍)
- ណែនាំដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ
- វាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយ តម្លាភាព
- បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀននិងបុគ្គលិកអប់រំទាំងអស់នៅក្នុងសាលាឱ្យទទួលបានការសិក្សាបន្ថែម(ជំរុញឱ្យធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជាបង្រៀន និង គរុកោសល្យ)
- លើកទឹកចិត្តអ្នកដែលមានស្នាដៃល្អ ដោយស្នើដំឡើងថ្នាក់ ឋានន្តរស័ក្តិ ផ្តល់ប័ណ្ណសរសើរ
- លើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព
- រៀបចំរចនាសម្ព័ន្ធបែងចែងតួនាទី និងភារកិច្ចដល់បុគ្គលិកតាមជំនាញប្រកបដោយប្រសិទ្ធភាព
- រៀបចំ និងបង្កើតគណៈកម្មការ និងក្រុមប្រឹក្សានានា
- រៀបចំទុកដាក់លិខិតស្នាមស្របតាមគោលការណ៍រដ្ឋបាល
- ចាត់ចែងការប្រើប្រាស់ធនធាននានាឱ្យមានប្រសិទ្ធភាព និងចំគោលដៅ
- ធ្វើប្រតិភូកម្មឱ្យមានប្រសិទ្ធភាព ដើម្បីសម្រេចគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ
- បង្កើតវប្បធម៌ ទំនាក់ទំនងរវាង គ្រូបង្រៀន និងថ្នាក់ដឹកនាំ
- បង្កើនការទទួលខុសត្រូវប្រកបដោយគណនេយ្យភាព
- រៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងគណនេយ្យភាព
- រៀបចំប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាលារៀន
- លើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈ គ្រូបង្រៀន
- ពិនិត្យតាមដាន និងវាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន
- ប្រើប្រាស់បច្ចេកវិទ្យាសម្រាប់គ្រប់គ្រងសាលារៀន និងបណ្តាញការងារប្រកបដោយប្រសិទ្ធភាព
- បង្ហាញសមត្ថភាពក្នុងការគិតប្រកបដោយការច្នៃប្រឌិត ការឆ្លុះបញ្ចាំង ការត្រិះរិះពិចារណា និងការដោះស្រាយបញ្ហា
- ដឹកនាំអង្គប្រជុំប្រកបដោយប្រសិទ្ធភាព ដោយប្រើប្រាស់រយៈពេលខ្លី មានចំណុចពិភាក្សាច្បាស់លាស់ និងសម្រេចលទ្ធផលបានតាមការរំពឹងទុកពេលបញ្ចប់ការប្រជុំ
- ចែករំលែកចំណេះដឹងថ្មីៗដល់សហការីអំពីបទពិសោធល្អៗរបស់សាលាដទៃ
- ដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍ រួមមានការងារបរិស្ថាន អនាម័យ ចរាចរណ៍ ប្រយុទ្ធប្រឆាំងគ្រឿងញៀន កសិកម្ម បុណ្យជាតិ អន្តរជាតិ ការ ផ្តល់ឈាម ការងារវប្បធម៌ សិល្បៈ ព័ត៌មាន ទេសចរណ៍ ការងារយុវជន កាយរឹទ្ធិ
- ប្រមូល និងវិភាគទិន្នន័យ ដើម្បីរៀបចំវាយតម្លៃគម្រោងផែនការឱ្យមានប្រសិទ្ធភាព។

### ខ. ការស្រាវជ្រាវមេរៀន

នៅក្នុងផ្នែកនេះនាយកសាលាត្រូវរៀបចំឱ្យមានការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍសមត្ថភាពគ្រូ តាមរយៈការរៀបចំឱ្យមានក្រុមបច្ចេកទេស និងប្រជុំបច្ចេកទេសឱ្យបានទេសឱ្យបានទៀងទាត់ ការចូលរួម និងការសិក្សាស្រាវជ្រាវមេរៀន ( LS) និងការស្រាវជ្រាវរកវិធីសាស្ត្រល្អៗ ដូចវិធីសាស្ត្រុករក ( IBL) ដើម្បីការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។

## ២ .៥.២. ការគ្រប់គ្រងធនធានមនុស្សរបស់សាលារៀន

ការគ្រប់គ្រងធនជានមនុស្សក្នុងសាលារៀនគឺជាការចាំបាច់បំផុតសម្រាប់ដំណើរក្នុងអង្គភាពមួយប្រកបដោយភាពជោគជ័យនាយកសាលានីមួយៗ ត្រូវដឹងឱ្យច្បាស់ពីគ្រូបង្រៀនរបស់ខ្លួនមានចំនួនប៉ុន្មាននាក់ មានមុខវិជ្ជាអ្វីខ្លះ គ្រូណាចូលធ្វើការឆ្នាំណា កាំប្រាក់ប៉ុន្មាន ស្ថានភាពរស់នៅគ្រូម្នាក់យ៉ាងណាខ្លះ ។ លើសពីនេះទៀតនាយក ឬ នាយិកាសាលារៀនត្រូវរៀបចំផែនការពិនិត្យតាមដាន និងពង្រឹងគុណភាពនៃការបង្រៀន និងរៀន តាមរយៈ ការរៀបចំបំណែងចែកតួនាទី និងភារកិច្ចបុគ្គលិកអប់រំ ការគ្រប់គ្រង បែងចែកសេវាបង្រៀនឱ្យបានសមស្របតាមមុខវិជ្ជានីមួយៗ ការគ្រប់ការបំពេញការងាររបស់បុគ្គលិក ក្នុងអង្គភាព។

### ក. ការគ្រប់គ្រងវត្តមានបុគ្គលិកជាប្រចាំ

ការបង្កើតឱ្យមានការគ្រប់គ្រងវត្តមានបុគ្គលិកជាប្រចាំគឺ ជាកត្តាមួយដែលអ្នកគ្រប់គ្រងត្រូវតែធ្វើឱ្យខានតែបានតាមរយៈ ការបង្កើតឱ្យសៀវភៅចុះអវត្តមានបុគ្គលិកជាប្រចាំ រៀងរាល់ថ្ងៃបំពេញការងារក៏ដូចជាពេលប្រជុំ ត្រូវមានរបាយការណ៍អវត្តមានបុគ្គលិកច្បាស់លាស់តាមថ្ងៃនីមួយៗ រៀងរាល់សប្តាហ៍ក៏ដូចជា របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

### ខ. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនក្នុងសាលារៀន

ការរៀបចំឱ្យមានកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន សម្រាប់សាលារៀនមានប្រយោជន៍ក្នុងការជួយជ្រោមជ្រែងគ្រូឱ្យបានរៀនសូត្រជាប្រចាំ ក្នុងការបំពេញការងារ ដែលជាការទទួលខុសត្រូវ និងជាការរៀបចំឡើងដោយភាពម្ចាស់ការរបស់នាយកសាលារៀន និងប្រធានក្រុមបច្ចេកទេសរបស់សាលារៀន។

**កម្មវិធីបំប៉នសមត្ថភាពគ្រូបង្រៀន ឬបុគ្គលិកក្នុងសាលារៀន**

កម្មវិធីបំប៉នសមត្ថភាពមានផ្សេងៗគ្នាដូចជាៈ (១)ការរៀនសូត្រពីគ្នាក្នុងថ្ងៃធម្មតា (២) ការរៀនសូត្រពីគ្នាក្នុងថ្ងៃ ព្រហស្បត៏ (៣) ការរៀនសូត្រពីការបំប៉នសមត្ថភាព នៅក្រៅសាលារៀនដូចជា ការចូលរួមវគ្គសិក្ខាសាលា និងទស្សនៈកិច្ចសិក្សាជាដើម។

**១. ការរៀនសូត្រពីគ្នាក្នុងថ្ងៃធម្មតា** ៖ គ្រូម្នាក់ចង់រៀនសូត្រពីវិធីបង្រៀនរបស់គ្រូម្នាក់ទៀតដែលមានបំណិនក្នុងការបង្រៀនភាសា គណិតវិទ្យា សិក្សាសង្គម ឬវិទ្យាសាស្ត្រ។ ដូច្នេះគ្រូបង្រៀនទាំងពីរថ្នាក់នេះអាចកំណត់ម៉ោងបង្រៀនណាមួយ ដើម្បីរៀនសូត្រពីគ្នាដោយប្រមូលសិស្សទាំងពីរថ្នាក់ដាក់ចូលគ្នាដើម្បីឱ្យគ្រូម្នាក់បង្រៀន គ្រូម្នាក់ទៀតសង្កេត ការបង្រៀនរបស់គ្រូម្នាក់ទៀត។ គ្រូបង្រៀនក៏អាចរៀនពីគ្នាផង

ដែរពីការសរសេរកិច្ចតែងការ បង្រៀន និងពីវិធីផ្សេងៗទៀតក្នុងការបង្រៀនសិស្ស ។ ការចែករំលែកកិច្ចតែងការគ្នាដើម្បីឱ្យគ្រូផ្សេងទៀតបានរៀន។

**២. ការរៀនសូត្រពីគ្នាក្នុងថ្ងៃព្រហស្បតិ៍៖** គ្រូបង្រៀនទាំងអស់នៅក្នុងសាលារៀន អាចជួបជុំគ្នាចែករំលែកបទពិសោធន៍ ដែលបានស្រាវជ្រាវជាមួយសិស្សផ្ទាល់ក្នុងថ្នាក់ ក្រោយពីបានបញ្ចប់ការបង្រៀនសិស្សរៀនយឺតថ្ងៃព្រហស្បតិ៍ ។ ក្រៅពីនោះគ្រូបង្រៀនក្រុមបច្ចេកទេស អាចធ្វើថ្នាក់និទស្សន៍ ដើម្បីចែកបទពិសោធន៍ពីគ្នាទៅវិញទៅមក។ គ្រូបង្រៀនដែលមានទេពកោសល្យក្នុងការបង្រៀន លើមេរៀន ឬមុខវិជ្ជាណាមួយ អាចគ្រូបង្រៀនផ្សេងទៀតអាចសាកសួរពីល្បិចបង្រៀនរបស់គាត់។

**៣. ការរបស់គ្រូបន្ទុក ប្រធានក្រុមបច្ចេកទេស នាយករងជំនាញ**

- **ការងាររបស់គ្រូបន្ទុកថ្នាក់** អាចមានឱកាសបានរៀនសូត្របន្ថែម លើកិច្ចតែការបង្រៀនមួយចំនួនដូចជា៖ (១)ការរៀបចំគម្រោងបង្រៀនមួយមុខវិជ្ជា និងកិច្ចតែងការបង្រៀន (២) ល្បិចបង្រៀនមេរៀន និងមុខវិជ្ជាផ្សេងៗ (៣) ការធ្វើតេស្តប្រចាំសប្តាហ៍ ( ៤) ការផ្តល់ព័ត៌មានត្រឡប់ពីលទ្ធផលសិក្សារបស់សិស្សទៅអាណាព្យាបាលសិស្ស។ល។
- **ការងាររបស់ប្រធានក្រុមបច្ចេកទេសគ្រប់កម្រិតថ្នាក់** មានឱកាសបានរៀនសូត្របន្ថែម៖(១) ការដឹកនាំប្រជុំក្រុមបច្ចេកទេស និងធ្វើថ្នាក់និទស្សន៍ក្នុងក្រុមបច្ចេកទេស (២ ) ការសរសេរវិញ្ញាសាតេស្តប្រចាំខែ សម្រាប់ផ្ញើជូននាយកឱ្យបានមួយខែមុនពេលធ្វើតេស្ត (៣) ការកត់ត្រា« ការធ្វើបច្ចុប្បន្នភាព» លទ្ធផលសិក្សា វិន័យ និងឥរិយាបថសិស្ស (៤) ការចូលរួមសកម្មភាពធ្វើតេស្តសិស្សប្រចាំខែ និងដើឆ្នាំសិក្សា។ល។
- **ការងាររបស់នាយករងគ្រប់គ្រងបច្ចេកទេស** អាចមានឱកាសបានរៀនសូត្របន្ថែម៖ (១) ការដឹកនាំប្រជុំក្រុមបច្ចេកទេស ដើម្បីពិនិត្យមើលការប្រែប្រួល លទ្ធផលសិក្សារបស់សិស្សតាមសប្តាហ៍ និងខែ( ២) ការធ្វើបច្ចុប្បន្នភាពលទ្ធផលសិក្សារបស់សិស្សក្នុងសាលារៀនទាំងមូល (៣) ការរៀបចំកម្មវិធី និងព្រឹត្តិការណ៍ នៅកម្រិតសាលារៀន និងកម្រងសាលាសម្រាប់លើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ល។

## ការធ្វើអធិការកិច្ចផ្ទៃក្នុង

ការធ្វើអធិការកិច្ចផ្ទៃក្នុងគឺជាអធិការកិច្ចដែលរៀបចំឡើងដោយអង្គភាពផ្ទាល់តែម្តង ក្នុងការត្រួតពិនិត្យការត្រួតពិនិត្យ ការបង្រៀន និងរៀន តាមរយៈ នាយកសាលា នាយករងបច្ចេកទេស ប្រធានក្រុមបច្ចេកទេស ក្នុងគោលបំណង៖

- ការពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពដើម្បីកែលម្អលទ្ធផលសិក្សា
- ការវាយតម្លៃលទ្ធផលសិក្សា និងសរសេររបាយការណ៍ អំពីវឌ្ឍនភាពនៃការបង្រៀន និងរៀន

- ការវាយតម្លៃចំណុចខ្លាំង ចំណុចខ្វះខាតដើម្បីកែលម្អវិធីសាស្ត្របង្រៀន
- ការបង្កើតបរិស្ថាន សិក្សាល្អ មានអនាម័យ សណ្តាប់ធ្នាប់ របៀបរៀបរយ និងគ្មានគ្រោះថ្នាក់
- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ប្រកបដោយ តម្លាភាព យុត្តិធម៌ ឱ្យបានទៀងទាត់
- ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃ ជាប្រយោជន៍ដល់ការកែលម្អដល់ការបង្រៀន និងរៀន។

## ២.៦.២. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការធ្វើផែនការសាលារៀន

នៅក្នុងផ្នែកការគ្រប់គ្រងហរិញ្ញវត្ថុក៏ជាផ្នែកដ៏សំខាន់ផងដែរនៅក្នុងការវាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន គឺសាលារៀនត្រូវរៀបចំឱ្យមានការចាយវាយថវិកាឱ្យបានត្រឹមត្រូវ រៀបចំផែនការសាលារៀនឱ្យបានស៊ីជម្រៅ ស្របទៅនឹងការចាយវាយ ឱ្យស្របទៅនឹងសម្មតិកម្ម។ លើសពីនេះត្រូវមានការពិនិត្យតាមដាន និងវាយតម្លៃលើលទ្ធផលផែនការអភិវឌ្ឍសាលារៀន ។ ការប្រមូល និងវិភាគទិន្នន័យ ដើម្បីរៀបចំវាយតម្លៃគម្រោងផែនការឱ្យមានប្រសិទ្ធភាព។

### ក.គោលបំណងនៃការគ្រប់គ្រងហិរញ្ញវត្ថុ

ការរៀបចំការគ្រប់គ្រងថវិកាសាលារៀន គឺមានគោលបំណងសំខាន់ៗដូចតទៅ៖

- ដើម្បីធានាអំពីតម្លាភាព និងគណនេយ្យភាព នៃការប្រើប្រាស់ថវិកានៅតាមសាលារៀន ស្របតាមគោលការណ៍ និងសេចក្តីណែនាំការគ្រប់គ្រងសាលារៀន។
- ដើម្បីចលនាធនធានពីសហគមន៍ និងប្រភពផ្សេងៗ ដើម្បីអភិវឌ្ឍសាលារៀន

### ខ.គោលការណ៍នៃការគ្រប់គ្រងថវិការបស់សាលារៀន

ការរៀបចំឱ្យសាលារៀនមានគោលការណ៍គ្រប់គ្រងថវិកា គឺជាចាំបាច់បំផុត ដើម្បីប្រមូលកម្លាំងក្នុងការគ្រប់គ្រងថវិកា ដែលបង្កើនឱ្យមានការចូលរួមទទួលខុសត្រូវ កសាងទំនុកចិត្ត និងសម្រេចផែនការអភិវឌ្ឍសាលារៀនប្រកបដោយតម្លាភាព។

ជាធម្មតានៅក្នុងសាលារៀនមួយ ការគ្រប់គ្រងថវិកាចាំបាច់ទាមទារ ឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធសំខាន់ៗ មានដូចជា គណៈកម្មការអភិវឌ្ឍសាលារៀន គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ថវិកា និងពាក់ព័ន្ធមួយចំនួនទៀតដែលចាំបាច់ចូលរួមដឹងឮពីចំណូល ការទុកដាក់ និងការចំណាយទាំងឡាយណាដែលសាលារៀនមាន ទៅតាមកាលកំណត់ណាមួយដែលបានព្រមព្រៀងគ្នា។នេះគឺជាការបង្ហាញឱ្យឃើញពីការចែករំលែកការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការជួយជ្រោមជ្រែងសាលរៀនឱ្យមានការរីមច្រើន និងបង្កើនគុណភាពនៃការអប់រំផងដែរ។

### គ. យន្តការនៃការគ្រប់គ្រងថវិកាសាលារៀន

ការរៀបចំឱ្យមានយន្តការក្នុងការគ្រប់គ្រងថវិការបស់សាលារៀន គឺជាការបង្ហាញឱ្យភាគីពាក់ព័ន្ធនានាបានចូលរួមក្នុងការទទួលខុសត្រូវតាមតួនាទី និងភារកិច្ចរៀងៗខ្លួន ។ ការគ្រប់គ្រងថវិការរបស់សាលារៀន គឺជាយន្តការមួយដ៏សំខាន់ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលខ្ពស់។

### ឃ. ការគ្រប់គ្រងថវិកាសាលារៀន

១. ប្រភពថវិកាសាលារៀន : ការកៀរគរថវិកាមកពីប្រភពផ្សេងៗដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសាលារៀន គឺជាកិច្ចការដ៏សំខាន់បំផុតរបស់គណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធមួយចំនួន

ទៀត។ បច្ចុប្បន្នសាលារៀនមានកញ្ចប់ថវិកាកម្មវិធី (PB) ថវិកាមូលនិធិកែលម្អសាលារៀន (SIG) និងពីប្រភពផ្សេងៗទៀតដូចជា ថវិការបស់ សប្បុរសជន ថវិកាជំនួយសប្បុរសធម៌ ថវិកាបុណ្យផ្កាសាមគ្គីរបស់សាលារៀន ថវិកាវិភាគទានរបស់ឳពុកម្តាយ អាណាព្យាបាលសិស្ស ថវិកានៃកញ្ចប់វិនិយោគរបស់សាលារៀនឃុំ/សង្កាត់ និងថវិកាជំនួយរបស់អង្គការជាដៃគូ ដែលជាកម្មវិធីអន្តរាគមន៍សម្រាប់លើកកម្ពស់វិស័យអប់រំតាមសាលារៀន។ ប្រភពថវិកាទាំងនេះ ពិតជាមានសារសំខាន់បំផុតក្នុងការចូលរួមជួយឱ្យសាលារៀនឱ្យមានការរីកចម្រើនតាមរយៈការអនុវត្តភាពជាម្ចាស់នៅក្នុងសហគមន៍។

២. ការទុកដាក់ថវិការបស់សាលារៀន : ការទុកដាក់ថវិកាសាលារៀន គឺជាការសំខាន់ក្នុងការរក្សាទុកថវិកាបានមកពីប្រភពផ្សេងៗឱ្យមានសុវត្ថិភាព (គណនីរបស់សាលារៀននៅធនាគារ) ដើម្បីធានាបានការជឿទុកចិត្ត តម្លាភាព និងគណនេយ្យភាព រវាងសាលារៀន និងអ្នកពាកព័ន្ធទាំងអស់។ ការត្រួតពិនិត្យការទុកដាក់លុយអាចធ្វើឡើងញឹកញាប់ពីសំណាក់ អ្នកពាក់ព័ន្ធ ដើម្បីជៀសវាងការដកលុយប្រើប្រាស់ ខុសគោលការណ៍។

៣. ការចំណាយថវិការបស់សាលារៀន : ការចំណាយរបស់សាលារៀនទាមទារឱ្យមានតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ។ សាលារៀនត្រូវប្រជុំធ្វើផែនការប្រចាំឆ្នាំ ដោយផ្អែកតាមផែនការអភិវឌ្ឍសាលារៀន ដោយមានការព្រមព្រៀងពីអ្នកពាក់ព័ន្ធដែលមានចែងនៅក្នុងរចនាសម្ព័ន្ធ។ រីឯទម្រង់ផ្សេងៗមានទំនាក់ទំនងកិច្ច បញ្ជីការគណនេយ្យមានបង្ហាញជូន។ ការចំណាយត្រូវធ្វើឡើងតាមរយៈការស្នើសុំ ពីគ្រូបង្រៀន និងអ្នកពាក់ព័ន្ធផ្អែកលើផែនការចំណាយ ដោយមានការឯកភាពពីគ្រប់អ្នកពាក់ព័ន្ធ។ រីឯការចំណាយត្រូវអនុវត្តតាមគោលការណ៍របស់សាលារៀនដោយមានការដេញថ្លៃ និងមានការជ្រើសរើសតម្លៃពីកន្លែងផ្សេងៗ ជៀសវាងការឃុបឃិតគ្នា។

៤. ការផ្សព្វផ្សាយអំពីថវិកាសាលារៀន : ផ្សព្វផ្សាយដល់ប្រជាជនតាមរយៈ (១) ផ្សព្វផ្សាយតាមរយៈមេក្រូវត្ត (២) បិទផ្សាយនៅសាលារៀន និងសាលាឃុំ (៣) មានកម្មវិធីសម្រាប់រាយការណ៍ទៅប្រជាជន និងអ្នកពាក់ព័ន្ធអំពីបញ្ជីថវិកាសាលារៀន ដែលមានចំណូល ចំណាយ និងលុយដែលមាន។

ជារួមមកយើងអាចបញ្ជាក់បានថា ចំណុចដូចដែលយើងបានរៀបខាងលើនៅក្នុងផ្នែករំឭកទ្រឹស្តីគឺជាចំណុចដែលធ្វើឱ្យការអនុវត្ត ការគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ និងឆ្លើយតបទៅនឹងគោលនយោបាយអប់រំជាតិ ឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រដ្ឋាភិបាល។

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ព័ត៌មានទូទៅស្តីពីការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានរៀបចំឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និងគុណវិស័យដែលបានយកមកវិភាគ ដើម្បីស្វែងយល់ពីការអនុវត្តការគ្រប់គ្រងតាមសាលារៀន ក្នុងខេត្តស្វាយរៀង និងបញ្ហាប្រឈមនានាដែលកើតក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង។

## ៣.២. ទីតាំងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកវិទ្យាល័យចំនួន ០៥ ដែលស្ថិតក្នុងស្រុកស្វាយទាប ស្រុកស្វាយជ្រុំ និងស្រុកកំពង់រោទិ៍ ដែលរួមមាន៖ (១) វិទ្យាល័យ ហ៊ុន សែន ហ៊ុន សែនប្រសូតិ (២) វិទ្យាល័យហ៊ុន សែន ស្វាយរំពារ (៣) វិទ្យាល័យ ហ៊ុន សែនក្រោលគោ (៤) វិទ្យា ល័យ ហ៊ុន សែន កំពង់រោទិ៍ (៥) វិទ្យាល័យ មិត្តភាពកម្ពុជា វៀតណាមព្រះពន្លា សម្រាប់ធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅ និងច្បាស់លាស់។

មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវ ជ្រើសរើសយកវិទ្យាល័យទាំងនោះសម្រាប់ធ្វើការស្រាវជ្រាវដោយសារសាលារៀនទាំងនោះ ស្ថិតនៅក្នុងតំបន់ផ្សេងៗគ្នា (វិទ្យាល័យចំនួន២ស្ថិតនៅក្នុងទីប្រជុំជន និង ៣ផ្សេងទៀតស្ថិតនៅតាមជាយស្រុក) គឺ វិទ្យាល័យ ហ៊ុន សែនប្រសូតិ ស្ថិតនៅក្នុងទីប្រជុំជននៃស្រុកស្វាយទាប វិទ្យាល័យ ហ៊ុន សែនកំពង់រោទិ៍ស្ថិតនៅទីប្រជុំជន ស្រុក កំពង់រោទិ៍ ។ វិទ្យាល័យ ហ៊ុន សែនស្វាយរំពារ ស្ថិតនៅផ្នែកជនបទនៃស្រុក ស្វាយទាប ។ រីឯសាលាវិទ្យាល័យ មិត្តភាពកម្ពុជា វៀតណាមស្ថិតនៅជនបទនៃស្រុកកំពង់រោទិ៍ ។ ចំណែកឯ វិទ្យាល័យ ហ៊ុន សែន ក្រោលគោគឺស្ថិតនៅផ្នែកខាងចុងនៃស្រុកស្វាយជ្រុំ ។ ចំពោះវិទ្យាល័យទាំងប្រាំគឺមានវិទ្យាល័យ ពីដែលស្ថិតនៅក្នុងគម្រោងស៊ីប របស់ខេត្តស្វាយរៀង គឺ វិទ្យាល័យ ហ៊ុន សែន ក្រោលគោ និងវិទ្យាល័យ ហ៊ុន សែនកំពង់រោទិ៍ ។

## ៣.៣- ការជ្រើសរើសសំណាក

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកតាមបែប គោលបំណងក្នុងការប្រមូលទិន្នន័យ ដោយដៅតែសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវទិន្នន័យបានជាក់លាក់ ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូច្នេះធាតុសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចយកជាការបានគឺ អ្នកស្រាវជ្រាវបានកំណត់ទៅលើគោលដៅសិក្សា ចំនួន៤ប្រភេទផ្សេងគ្នាគឺ នាយកសាលាចំនួន១៥នាក់ គ្រូបង្រៀនចំនួន១១៤នាក់ សិស្សនៅមធ្យមសិក្សាទុតិយភូមិចំនួន១៩៤នាក់ និងគណៈកម្មការគ្រប់គ្រងសាលាដែលជា ប្រធានចំនួន៥នាក់។

## ៣.៤- ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យមានភាពងាយស្រួល និងបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតទម្រង់កម្រងសំណួរស្រាវជ្រាវសម្រាប់សួរទៅលើលោកគ្រូ អ្នកគ្រូ លោកនាយក លោកស្រីនាយិកា លោកនាយករង លោកស្រីនាយិការង សិស្សានុសិស្ស គណៈកម្មការគ្រប់គ្រងសាលារៀនដែលចែកចេញជាពីរផ្នែកគឺៈ ព័ត៌មានទូទៅ និងកម្រងសំណួរជ្រើសរើស រួមជាមួយសំណួរបញ្ចេញគំនិតមួយសំណួរ( សំណួរគុណវិស័យ )។

**ផ្នែកទី១៖** អំពីព័ត៌មានទូទៅចែកចេញជា៦ចំណុចគឺ (១)ឈ្មោះ ស្រុក (២)ឈ្មោះ សាលា (៣) តួនាទី (៤) ភេទ (៥) អាយុ (៦) កម្រិតវប្បធម៌ (៧) បទពិសោធការងារ ។

**ផ្នែកទី(២)៖** ជាកម្រងសំណួរជ្រើសរើសដែលមានចំនួន ៤៦ហើយចែកជា៩ផ្នែក និងតម្រូវឲ្យ លោកនាយក នាយករង លោកស្រីនាយិកា នាយិការង ធ្វើការជ្រើសរើសតាមការណែនាំអំពីអ្វីដែលត្រូវនឹងសកម្មភាពប្រតិបត្តិរបស់ពួកគាត់ក្នុងការដឹកនាំគ្រប់គ្រងសាលារៀនដោយគូសសញ្ញាគ្រីស (✓)លើចំណុចណាមួយដែលគេបានធ្វើ និងមិនបានធ្វើទៅតាមកម្រិតនៃសកម្មភាពនីមួយៗពី ១ ដល់ ៥ (១ = ក្រោមមធ្យម«១ពិន្ទុ» ២ = មធ្យម«២ពិន្ទុ» ៣ = ល្អ បង្គួរ«៣ពិន្ទុ» ៤ = ល្អ«៤ពិន្ទុ» និង៥ = ល្អប្រសើរ«៥ពិន្ទុ»)

ម្យ៉ាងទៀតដើម្បីឱ្យដឹងកាន់តែច្បាស់ពីការអនុវត្តការគ្រប់គ្រងតាមសាលារៀន អ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរគុណវិស័យមួយសំណួរទៀត ដើម្បីឱ្យ លោកនាយក នាយករង លោកស្រីនាយិកា នាយិការង បញ្ចេញគំនិតចំពោះការចូលរួមធ្វើការវង្វាយតម្លៃការអនុវត្តតាមសាលារៀន។

## ៣.៥- ដំណើរការប្រមូលទិន្នន័យ

ក្រោយពីទទួលបានការណែនាំ និងឯកភាពពីគ្រូដឹកនាំ ព្រមទាំងទទួលបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំ លេខ : ១១៩ វជអ.ផក ចុះថ្ងៃ សុក្រ ១៤ កើត ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៩ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក

គ្រប់គ្រងអប់រំជំនាន់ទី ៦ នៃវិទ្យាស្ថានជាតិអប់រំឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅតាមរាជធានី ខេត្តនានា។ និងលិខិតជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ : ១៨៨៥ អយក.វជអ ចុះថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៩ ស្ដីពីការស្នើទៅប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្តនានា សុំជួយសម្រួលដល់ការចុះស្រាវជ្រាវប្រមូលទិន្នន័យ នៅតាមរាជធានី ខេត្តនានា។ មូលហេតុនៃការស្នើសុំទៅមន្ទីរអប់រំយុវជន និងកីឡាខេត្តនេះ ដោយសារតែសាលាគោលដៅយកមកធ្វើការស្រាវជ្រាវទាំងនេះ ស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំយុវជន និងកីឡារាជធានី-ខេត្ត ។ បន្ទាប់ពីទទួលបានការឆ្លើយតបពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត ស្វាយរៀង តាមរយៈលិខិតឧទ្ទេសនាម លេខ : ៦៥៨៦ទ ចុះថ្ងៃ ចន្ទ ០៩ រោច ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៩ ស្តីពីការសម្រួលដល់ការចុះប្រមូលទិន្នន័យនៅតាមក្រុង ស្រុកគោលដៅនានា ក្នុងខេត្តស្វាយរៀងមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំផែនការដោយធ្វើការទំនាក់ទំនងទៅសាលាគោលដៅ ដោយផ្ទាល់ ដើម្បីជួបពិភាក្សាជាមួយនាយកសាលាក្នុងគោលបំណងកំណត់កាលបរិច្ឆេទជួប លោកគ្រូ អ្នកគ្រូ លោកនាយក សិស្សានុសិស្ស គណៈកម្មការគ្រប់គ្រងសាលា ដើម្បីបំពេញកម្រងសំណួរដែលបានត្រៀមទុកជាមុន ធ្វើយ៉ាងណាមិនឱ្យប៉ះពាក់ដល់ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការរៀនសូត្ររបស់សិស្សានុសិស្ស។ ដំណើរការទាំងមូលបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលា អំពីគោលបំណង និងផែនការទាំងអស់នៃការសិក្សាស្រាវជ្រាវ ។ ក្រោយពីនាយកសាលាបានពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំយុវជន និងកីឡាក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយគាត់ក៏បាន អនុញ្ញាតឱ្យរៀបចំធ្វើការប្រមូលទិន្នន័យ ទៅតាមផែនការដែលឯកភាពគ្នា។

មុនការចុះប្រមូលទិន្នន័យផ្លូវការ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសាកល្បងលើកម្រងសំណួរទាំងអស់នៅសាលាមួយក្នុងខេត្តស្វាយរៀង ។ គោលបំណងនៃការសាកល្បងកម្រងសំណួរនេះគឺដើម្បីធានាអំពីប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរដើម្បីឱ្យដឹងថាអាចយកមកប្រមូលទិន្នន័យជាផ្លូវការបាន ឬមិនបាន។ ក្រោយពីការសាកល្បងលើកម្រងសំណួរទាំងនេះអ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថាការសាល្បងនេះពិតជាទទួលបានផលល្អមែនព្រោះយើងរកឃើញចំណុចខ្វះខាត មួយចំនួនរបស់កម្រង សំណួរ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវក៏យកបញ្ហាទាំងនេះទៅពិភាក្សាជាមួយ សាស្ត្រាចារ្យដឹកនាំ ដើម្បីទទួលបានយោបល់ត្រឹមត្រូវក្នុងការកែលម្អ កម្រងសំណួរឡើង វិញ។ ក្រោយពីការណែនាំ កែលម្អ និងឯកភាពពីសាស្ត្រាចារ្យ ណែនាំរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្តើមចុះប្រមូលទិន្នន័យជាផ្លូវការតែម្តង។

## ៣.៦. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបរិមាណវិស័យ គុណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាដំបូងត្រូវវិភាគដាច់ដោយឡែកទៅតាមប្រភេទសំណាកនីមួយៗ ( គណៈនាយក លោកគ្រូ អ្នកគ្រូ សិស្ស គណៈ

កម្មការគ្រប់គ្រងសាលារៀន) និងបែបគុណវិស័យត្រូវប្រមូលគំនិតដាក់ទៅ តាមក្រុមដោយធ្វើតារាងចំណាត់ថ្នាក់ទៅតាមគំនិតដែលដូចគ្នា។ម្យ៉ាងទៀតដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធី SPSS ដើម្បីវិភាគទិន្នន័យ សម្រាប់ស្វែងរកចំនួនហ្វ្រេកង់គិតជាមធ្យម គម្លាតស្តង់ដា រនិងលំដាប់ ចំណែកឯ Microsoft Excel សម្រាប់សង់ក្រាប តារាង និងបកស្រាយព័ត៌មាន។ បន្ថែមលើសពីនេះទៀតអ្នកស្រាវជ្រាវបានបង្កើតតារាងវិភាគរួមដោយប្រើកម្មវិធី Microsoft Excel ដើម្បីធ្វើការប្រៀបធៀបការវិភាគរួមចំពោះទស្សនៈរបស់ភាគសំណាកទាំងបួនដែលមានការយល់ឃើញទៅលើ ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធី Ms word សម្រាប់ធ្វើតារាងទិន្នន័យ ។

## ៣.៧- ក្រមសីលធម៌នៃការស្រាវជ្រាវ

ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌មានសារៈសំខាន់ណាស់ សម្រាប់អ្នកសិក្សាស្រាវជ្រាវក្នុងការធានាប្រសិទ្ធភាពនៃការស្រាវជ្រាវក៏ដូចជាបង្កើននូវទំនុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយ ក៏ដូចជាទិន្នន័យផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ។ ការព្រមព្រាងគ្នារវាងអ្នកផ្តល់ការចូលរួមធ្វើ កម្រងសំណួរ និងអ្នកដែលស្វែងរកប្រភពព័ត៌មានច្បាស់លាស់ និងមានប្រសិទ្ធភាព ហើយអាចយក មកប្រើការបានសម្រាប់ធ្វើការវិភាគស៊ីជម្រៅ។ អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយត្រូវបានរក្សាការសំងាត់លើកលែងតែឈ្មោះសាលារៀនដែលត្រូវបានបង្ហាញ ក៏មានការឯកភាពពីនាយកសាលាគោលដៅនីមួយៗ អ្នកសិក្សាស្រាវជ្រាវបាននាំយកនូវលិខិតអនុញ្ញាតទៅជាមួយ ហើយសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធ ដោយចាប់ផ្តើមមុនពេលបំពេញកម្រងសំណួរ។ ការចូលរួមសហការរបស់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ក្នុងការផ្តល់ឱកាសឲ្យអ្នកស្រាវជ្រាវចុះធ្វើកម្រងសំណួរតាមថ្នាក់ មានន័យថា អ្នកពាក់ព័ន្ធទាំងនោះយល់នូវគោលបំណង នៃការស្រាវជ្រាវជាមុន ហើយអ្នកស្រាវជ្រាវក៏រំពឹងផងដែរថានឹងទទួលបានចម្លើយ ឬព័ត៌មានដែលពិត។ ការធ្វើដូច្នេះ ធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យរបស់ខ្លួនតាមសាលានីមួយៗដោយស្របច្បាប់។

# ជំពូកទី ៤
# លទ្ធផលការស្រាវជ្រាវ និង ការពិភាក្សា

# ជំពូកទី៤ ៖ លទ្ធផលការស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញ បកស្រាយ និង ការវិភាគទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ និង សំណួរសំភាសន៍ទៅលើលោកគ្រូ អ្នកគ្រូ លោកនាយក លោកស្រីនាយិកា សិស្សានុសិស្ស និងគណៈកម្មការគ្រប់គ្រងសាលារៀនដើម្បីឱ្យដឹងថាគណៈនាយកលោកគ្រូអ្នកគ្រូមានការដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន ការគ្រប់គ្រងក្នុងដំណើរការបង្រៀន និងរៀន ទំនាក់ទំនងជាមួយសហគមន៍ អាណាព្យាបាលសិស្ស ការគ្រប់គ្រងបរិស្ថានសាលារៀន ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្សយ៉ាងដូចម្តេច និងជួបបញ្ហាប្រឈមទាំងឡាយដូចម្តេចខ្លះដែលរាំងស្ទះដល់ដំណើរការអនុវត្តការគ្រប់គ្រងតាមសាលារៀន។

## ៤.១- លទ្ធផលការស្រាវជ្រាវ

### ក កម្រងសំណួរសម្រាប់សួរនៅលើលោកគ្រូ អ្នកគ្រូ.

តាមអ្នកដែលបានគូស និងសម្ភាសន៍នៅក្នុងកម្រងសំណួរសម្រាប់បំពេញនៅក្នុងសំណួរផ្នែកទី១ នេះអ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រតិបត្តិការគ្រប់គ្រងតាមសាលារៀនរបស់គណៈនាយក ក៏ដូចជាលោកគ្រូ អ្នកគ្រូ នៅកម្រិតមធ្យមសិក្សាទុតិភូមិនៅខេត្ត ស្វាយរៀងបានសួរទៅលើលោកគ្រូ អ្នកគ្រូចំនួន ១១៤នាក់ ដែលស្ថិតនៅវិទ្យាល័យចំនួន៥ ក្នុងខេត្តស្វាយរៀង។

ឧបករណ៍ស្រាវជ្រាវទៅលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន អ្នកសិក្សាបានប្រើកម្រងសំណួរជ្រើសរើសដែលមានសំណួរចំនួន៤៦សំណួរ ហើយចែកចេញជា ៩ ផ្នែក៖ ផ្នែកទី១ រដ្ឋបាលសាលារៀន (មាន ៦ចំណុចចាប់ពី១.១ដល់១.៦)ផ្នែកទី២ ការបង្រៀន និងរៀន(មាន៩ចំណុចចាប់ពី២.១ ដល់២.៩) ផ្នែកទី៣ មាតាបិតា និងសហគមន៍ជួយសិស្ស (មាន ៤ ចំណុច ចាប់ពី ៣.១ ដល់ ៣.៤) ផ្នែកទី៤ (មាន ៧ចំណុច ចាប់ពី៤.១ដល់ ៤.៧) ផ្នែកទី៥ ( មាន៦ ចំណុច ចាប់ពី ៥.១ដល់ ៥.៦) ផ្នែកទី៦ (មាន៣ ចំណុច ចាប់៦.១ ដល់ ៦.៣) ផ្នែកទី៧ (មាន៤ ចំណុច ចាប់ពី៧.១ ដល់ ៧.៤) ផ្នែកទី៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន( មាន៤ ចំណុច ចាប់ពី៨.១ ដល់ ៨.៤) និងផ្នែកទី៩ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ (មាន៣ចំណុចចាប់ពី៩.១ដល់៩.៣)។ ស្ថិតិដែលប្រើវិភាគរួមមានភាគរយ(%) មធ្យមភាគ(Mean) គម្លាតស្តង់ដា (Standard deviation) ដើម្បីបង្ហាញឱ្យឃើញនូវកម្រិតប្រតិបត្តិរបស់ គណៈនាយក លោកគ្រូ អ្នកគ្រូនៅតាមសាលារៀន ។ យោងតាម ការបែងចែកកម្រិតដែលចងក្រងដោយ Oxford និងBurry-Stock (1995) កម្រិតមធ្យមត្រូវបានគេបែងចែកជា បីក្រុម គឺកម្រិតខ្ពស់ (M=3.50) ឡើង កម្រិតមធ្យម (M=2.50–3.49) និងកម្រិតទាប (M=2.49ចុះ)។

**តារាងទី១៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃរដ្ឋបាលសិក្សារបស់លោកនាយក លោកគ្រូ អ្នកគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១១៤)។

| ល.រ | ខ្លឹមសារ | រដ្ឋបាលសិក្សា | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ការរៀបចំរចនាសម្ព័ន្ធ និងបំណែងចែកការកិច្ចរបស់គណៈនាយក លោកគ្រូ អ្នកគ្រូ | ៤.០៨ | ០.៧៣ | ខ្ពស់ | ២ |
| ២ | រៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្រប | ៣.៩១ | ០.៧៦ | ខ្ពស់ | ៥ |
| ៣ | ការបែងចែក កាលវិភាគ និងម៉ោងបង្រៀន | ៤.១២ | ០.៦៧ | ខ្ពស់ | ១ |
| ៤ | ការរៀបចំឱ្យមានការប្រជុំក្រុមបច្ចេកទេសបានតាមការកំណត់ | ៤.០២ | ០.៧៤ | ខ្ពស់ | ៣ |
| ៥ | ការពិនិត្យតាមដានអវត្តបុគ្គលិកជាប្រចាំ | ៣.៩៦ | ០.៧០ | ខ្ពស់ | ៤ |
| ៦ | ការរៀបចំប្រព័ន្ធអធិការកិច្ចអចិន្ត្រៃ | ៣.៤៣ | ១.០៣ | មធ្យម | ៦ |
| **សរុប** | | **៣.៩២** | **០.៥៦** | **ខ្ពស់** | |

យោងតាមតារាងខាងលើ លទ្ធផលបានបង្ហាញថាការអនុវត្តផ្នែករដ្ឋបាលសាលារៀនគឺមានកម្រិតខ្ពស់គឺចាប់ពីកម្រិត ៤.១២ រហូតដល់ ៣.៤៣ ។ តារាងនេះគឺមានន័យថានៅចំណុច៣៖ បំណែងចែកកាលវិភាគ និងម៉ោងបង្រៀនគឺមានកម្រិតខ្ពស់៤.១២ ( M=4.12) បន្ទាប់មកគឺចំណុច១៖ ការរៀបចំរចនាសម្ព័ន្ធ ការបែងចែកតួនាទីរបស់គណៈនាយក លោកគ្រូ អ្នកគ្រូ៤.០៨( M=4.08) និងកម្រិតខ្ពស់ដែលមានតម្លៃមធ្យមទាបជាងគេគឺចំណុច៦៖ ការរៀបចំប្រព័ន្ធអធិការកិច្ចអចិន្ត្រៃ៣.៤១(M=3.41)។

ជារួមតាមរាងខាងលើបង្ហាញថា ការប្រតិបត្តិការងាររដ្ឋបាលរបស់សាលារៀននៅតាមសាលារៀននីមួយៗមានភាពល្អប្រសើរច្រើនលើការបែងចែកតួនាទីភារកិច្ច សេវាបង្រៀន និងសេវារដ្ឋបាលផ្សេងៗ ។ តែចំពោះការងារអធិការកិច្ចអចិន្ត្រៃរបស់សាលារៀននៅមានកម្រិតប្រឈមមិនទាន់អនុវត្តបានល្អនៅឡើយ។

**តារាងទី២៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃការបង្រៀន និងរៀនរបស់ លោកគ្រូ អ្នកគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១១៤)។

| ល.រ | ខ្លឹមសារ | ការបង្រៀន និងរៀន | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជានីមួយៗ | ៤.២០ | ០.៦១ | ខ្ពស់ | ២ |
| ២ | ការសរសេរកិច្ចតែងការតាមមុខវិជ្ជាគោលនីមួយៗ | ៣.៧៨ | ០.៧៥ | ខ្ពស់ | ៥ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ និងការប្រមូលលទ្ធផល | ៣.៤៥ | ០.៧២ | មធ្យម | ៧ |
| ៤ | ការបំពេញរដ្ឋបាលថ្នាក់រៀន | ៣.៧៧ | ០.៨២ | ខ្ពស់ | ៦ |
| ៥ | ការបង្កើតវិញ្ញាសាតេស្តប្រចាំខែ | ៤.០៤ | ០.៦៩ | ខ្ពស់ | ៤ |
| ៦ | ធ្វើតេស្តស្តង់ដារប្រចាំខែ | ៤.៣៣ | ០.៤៦ | ខ្ពស់ | ១ |
| ៧ | កែកិច្ចការ និងបញ្ចូលពិន្ទុ | ៤.១១ | ០.៧០ | ខ្ពស់ | ៣ |
| ៨ | ផ្សព្វផ្សាយលទ្ធផលតេស្តនៅតាមភូមិ | ២.៦៣ | ១.១៣ | មធ្យម | ៩ |
| ៩ | ជួបជាមួយមាតាបិតាសិស្សដែលកូនរៀនយឺតដើម្បីរិះរកមធ្យោបាយជួយកូន | ២.៨២ | ០.៩៦ | មធ្យម | ៨ |
| **សរុប** | | **៣.៦៨** | **០.៧២** | **ខ្ពស់** | |

តាមតារាងខាងលើបានបង្ហាញថាការគ្រប់គ្រងបច្ចេកទេស បង្រៀន និងរៀននៅមធ្យមសិក្សាទុតិយភូមិចាប់ពីកម្រិតខ្ពស់ ពី៤.៣៣ រហូតដល់កម្រិតមធ្យមកម្រិតទាប ២.៦៣ ។ គឺមានន័យថានៅចំណុចទី៦៖ ធ្វើតេស្តស្តង់ដារប្រចាំខែមានមធ្យម ៤.៣៣ ( M= 4.33) បន្ទាប់មកគឺចំណុចទី១៖ បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជានីមួយៗមានមធ្យមកម្រិតខ្ពស់បន្ទាប់គឺ ៤.២០ (M= 4.20) និងបន្ទាប់មកទៀតគឺចំណុច ៖ ការបង្កើតវិញ្ញាតេស្តប្រចាំខែ មានកម្រិតមធ្យមកម្រិតខ្ពស់ ៤.១១ (M= 4.11) ។ ចំពោះកម្រិតមធ្យមដែលមានកម្រិតទាបជាងគេគឺចំណុច៨៖ គឺការផ្សព្វផ្សាយលទ្ធផលតេស្តតាមភូមិ ២.៦៣ (M= 2.63) បន្ទាប់មកគឺចំណុចទី៩៖ ជួបជាមួយមាតាបិតាសិស្សដែលរៀនយឺតដើម្បីរិះរកមធ្យោបាយជួយកូន ដែលមានមធ្យម ២.៨២( M= 2.82 )។

ជារួមមកបង្ហាញថាក្នុងដំណើរការគ្រប់គ្រងការបង្រៀន និងរៀន គឺចំណុចដែលលោកគ្រូ អ្នកគ្រូអនុវត្តបានល្អគឺចំណុចការបង្កើតតេស្តស្តង់ដារប្រចាំខែ បំណែងចែកកម្មវិធីសិក្សា និងការបង្កើតវិញ្ញាសាតេស្តប្រចាំខែ ។ ចំណែកឯ ចំណុចដែលមិនទាន់អនុវត្តបានល្អគឺចំណុច ការផ្សព្វផ្សាយលទ្ធផលតេស្តតាមភូមិ និងចំណុច ជួបជាមួយអាណាព្យាបាលសិស្សដែលរៀនយឺតដើម្បីរិះរកវិធីជួយកូន ដែលជាចំណុចមួយដែលលោកគ្រូ អ្នកគ្រូត្រូវតែបង្កើតការយកចិត្តទុកដាក់។

**តារាងទី៣៖** មធ្យម គម្លាតស្តង់ដារអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក មាតាបិតា និងសហគមន៍ជួយសិស្ស (N= ១១៤)។

| ល.រ | ខ្លឹមសារ | បិតា និងមាតា សហគមន៍ជួយសិស្ស | អត្ថន័យ | លំដាប់ |
|---|---|---|---|---|

| | | មធ្យម | គម្លាតស្តង់ដា | | |
|---|---|---|---|---|---|
| ១ | ភាគរយថ្នាក់រៀនបានប្រជុំប្រឹក្សាយោបល់រវាង គ្រូបង្រៀន មាតាបិតា និងសិស្ស (នៅដើមឆ្នាំសិក្សា និងតាមត្រីមាស) | ២.៨៥ | ១.០២ | មធ្យម | ៤ |
| ២ | ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនតាមការណែនាំ(ពេលបើកបវេសនកាលចុងឆមាសទី១ និងទី២) | ៣.៦៧ | ១.០០ | ខ្ពស់ | ១ |
| ៣ | ភាគរយសិស្សមករៀនយឺតមានចំនួនតិចបំផុត | ៣.៦២ | ០.៨៦ | ខ្ពស់ | ២ |
| ៤ | ភាគរយសិស្សបានធ្វើកិច្ចការផ្ទះឬកិច្ចការគម្រោង | ៣.៤៦ | ០.៣៧ | ខ្ពស់ | ៣ |
| **សរុប** | | **៣.៤០** | **១.០៨** | **មធ្យម** | |

តាមតារាងខាងលើបានបង្ហាញថា នៅក្នុងផ្នែក សំណួរដែលទាក់ទងទៅនឹង មាតាបិតា និងសហគមន៍ជួយសិស្ស គឺចំណុចខ្លាំងដែលមានមធ្យមកម្រិតខ្ពស់គឺចំណុច២៖ ចំនួនប្រជុំជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន តាមការណែនាំ( នៅពេលបើកបវេសនកាល ចុងឆមាសទី១ និងទី២) ដែលមានកម្រិតមធ្យម ៣.៦៧ ( 3.67) និងចំណុច៣៖ គឺភាគរយសិស្សដែលមករៀនយឺត ដែលមានកម្រិតមធ្យមកម្រិតខ្ពស់បន្ទាប់គឺ ៣.៦៧ ( M= 3.67។ ចំពោះចំណុចដែលកម្រិតមធ្យមកម្រិតទាបគឺចំណុចទី១៖ភាគរយថ្នាក់រៀនបានប្រជុំប្រឹក្សាយោបល់រវាងគ្រូបង្រៀន មាតាបិតាសិស្ស (នៅដើមឆ្នាំសិក្សា និងតាមត្រីមាស) ដែលមានកម្រិតមធ្យម ២.៨៥ ( M= 2. 85) ។

ជារួមមកបង្ហាញថា ក្នុងផ្នែក សំណួរ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្សគឺចំណុចដែលលោកគ្រូ អ្នកគ្រូធ្វើបានល្អគឺចំណុច គឺការជួបអាណាព្យាបាលសិស្ស នៅដើមឆ្នាំសិក្សា និងចំណុចជួយសិស្សកុំឱ្យមករៀនយឺត ។ រីចំណុចដែលអនុវត្តពុំសូវបានល្អគឺចំណុច ដែលធ្វើពុំសូវបានល្អគឺចំណុចគឺចំណុចទំនាក់ទំនងជាមួយ សហគមន៍ អាណាព្យាបាលសិស្សនៅដើមឆ្នាំសិក្សា ។

**តារាងទី៤៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក សិស្ស និងសេវាជួយសិស្ស (N= ១១៤)

| ល.រ | ខ្លឹមសារ | សិស្ស និងសេវាជួយសិស្ស | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស) | ៣.០០ | ០.៧៩ | មធ្យម | ១ |
| ២ | ភាគរយសិស្សប្រើបន្ទប់ពិសោធន៍ | ២.៨៧ | ១.១៥ | មធ្យម | ៣ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ភាគរយសិស្សប្រើកុំព្យូទ័រ | ២.៥៤ | ១.២៦ | មធ្យម | ៥ |
| ៤ | ភាគរយថ្នាក់មានដំណើរការ (តាមការណែនាំរបស់ក្រសួង) ក្លឹបសិស្សាសិស្ស | ២.៦១ | ១.០៦ | មធ្យម | ៤ |
| ៥ | ភាគរយសិស្សខ្សោយគំហើញនិងខ្សោយស្តាប់ បានទទួលការគាំទ្រដើម្បីរៀនបានប្រសើរ | ២.៨៧ | ១.០៧ | មធ្យម | ២ |
| ៦ | ចំនួនទស្សនកិច្ចសិក្សារបស់គ្រូបង្រៀន | ១.៨១ | ១.០២ | ទាប | ៦ |
| **សរុប** | | **២.៥៥** | **០.៦១** | **មធ្យម** | |

យោងតាមតារាងខាងលើបង្ហាញថាក្នុងផ្នែក សិស្សនិងសេវាជួយសិស្សមិនមានចំណុចខ្លាំងគួរកត់សំគាល់នោះទេព្រោះនៅចំណុចនេះមិនមានមធ្យមកម្រិតខ្ពស់នោះទេ គឺមានតែកម្រិតមធ្យមចាប់ពី៣.០០ រហូតដល់១.៨១ ដែលជាមធ្យមកម្រិតទាប ។ មានន័យថានៅចំណុចទី១ ៖ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមជានរាល់ត្រីមាស)មានកម្រិតមធ្យម ៣.០០ ដែលជាកម្រិតមធ្យមលើគេ (M= 3.00) ចំណុចទី៦៖ ចំនួនទស្សនកិច្ចសិក្សារបស់ គ្រូបង្រៀនដែលមាន មធ្យមកម្រិតទាប១.៨១(M= 1.81 ) ។

ជារួមមកបង្ហាញថានៅក្នុងចំណុច សិស្សនិងសេវាជួយសិស្ស កម្រិតប្រតិបត្តិ និងការជួយដល់ការសិក្សារបស់សិស្សនៅមានកម្រិតមធ្យម និងមានកម្រិតទាបនៅឡើយ ដែលជាបញ្ហាប្រឈមនៅតាមវិទ្យាល័យនានា។

**តារាងទី៥៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ការដឹកនាំ និងការគ្រប់គ្រងសាលារៀន (N= ១១៤)

| ល.រ | ខ្លឹមសារ | ការដឹកនាំ និងការគ្រប់គ្រងសាលារៀន | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ការអនុវត្តផែនការអធិការកិច្ចរបស់នាយកឬនាយិកាឬនាយករងឬនាយិការង | ៣.៤៣ | ១.០៥ | មធ្យម | ៥ |
| ២ | ចំនួនការប្រជុំបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំ) | ៣.៩៦ | ០.៨៨ | ខ្ពស់ | ១ |
| ៣ | ចំនួនដងបំប៉ន និងដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក និងគណៈកម្មការគ្រង់គ្រងសាលារៀនដោយមន្ត្រីក្រសួង ដើម្បីកែលម្អសូចនាករគ្រប់គ្រងសាលារៀន | ៣.៥៥ | ៣.៨៧ | ខ្ពស់ | ៤ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាង<br>មុនតាមរយៈការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | ៣.៧២ | ០.៧២ | ខ្ពស់ | ២ |
| ៥ | ការបន្ថយភាពមិនប្រក្រតីនៅសាលារៀន | ៣.៥៩ | ០.៩០ | ខ្ពស់ | ៣ |
| ៦ | ចំនួនដងពិនិត្យតាមដាននិងគាំទ្រពីថ្នាក់ស្រុក<br>មន្ទីរ និងក្រសួង | ៣.១៦ | ០.៩៥ | មធ្យម | ៦ |
| **សរុប** | | **៣.៥៧** | **០.៩០** | **ខ្ពស់** | |

តាមតារាងខាងលើបាបង្ហាញថាក្នុងផ្នែកការដឹកនាំ និងការគ្រប់គ្រងសាលារៀន មានមធ្យមចាប់ពី ៣.៩៦ដែលជាមធ្យមកម្រិតខ្ពស់ រហូតដល់៣.១៦ ដែលជាមធ្យមកម្រិតក្នុងលំដាប់ចុងក្រោយគេ។ មានន័យថាចំណុចទី២៖ ចំនួនប្រជុំក្រុមបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំសិក្សា) មានមធ្យមកម្រិតខ្ពស់ ៣.៩៦ (M=3.96) បន្ទាប់មកគឺចំណុច ទី៤៖ ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុនតាមរយៈការវាយតម្លៃការអនុវត្ត ការងារជាប្រចាំដែលមានមធ្យមកម្រិតខ្ពស់ ៣.៧២ ( M= 3.77) និងបន្ទាប់មកទៀតគឺចំណុចទី៥៖ ការកាត់បន្ថយភាពមិនប្រក្រតីនៅសាលារៀនដែលមានមធ្យមកម្រិតខ្ពស់៣.៥៩ (M=3.59)។ ចំពោះចំណុចដែលមានមធ្យមកម្រិតក្រោមគេគឺចំណុចទី៦ ចំនួនពិនិត្យតាមដាន និងគាំទ្រពីថ្នាក់ស្រុក មន្ទីរ និងក្រសួងដែលមានមធ្យម៣.១៦ ( M= 3.16) ជាលំដាប់ក្រោមគេនៅក្នុងចំណុចការដឹកនាំ និងគ្រប់គ្រងសាលារៀន។

ជារួមមកបង្ហាញថានៅក្នុងផ្នែកការដឹកនាំ និងគ្រប់គ្រងសាលារៀននេះគឺមាន លក្ខណៈល្អច្រើន ហើយនៅលើផ្នែកគ្រប់គ្រងបច្ចេកទេស និងដំណើរការគ្រប់គ្រងក្នុងសាលារៀន តែចំណុចដែលខ្វះខាតគឺការចូលរួមរបស់ថ្នាក់ ស្រុក មន្ទីរ និងថ្នាក់ក្រសួង។

**តារាងទី៦៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ធនធានមនុស្ស (N= ១១៤)

| ល.រ | ខ្លឹមសារ | ធនធានមនុស្ស | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន | ៣.៤៤ | ០.៧៨ | មធ្យម | ២ |

| | | | | | |
|---|---|---|---|---|---|
| ២ | ចំនួនគ្រូខ្វះមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា)ចុះថយធៀបជាមួយបទដ្ឋាន | ៣.០៧ | ១.០៣ | មធ្យម | ៣ |
| ៣ | គុណវុឌ្ឍិនាយក ឬនាយិកាសាលារៀនធៀបជាមួយផែនការក្រសួង | ៣.៧០ | ០.៨២ | ខ្ពស់ | ១ |
| **សរុប** | | **៣.៤០** | **០.៦៥** | **មធ្យម** | |

តាមតារាងខាងលើបានបង្ហាញថានៅក្នុងផ្នែកធនធានមនុស្សមានកម្រិតមធ្យមចាប់ពី ៣.៧០ រហូតដល់ ៣.០៧។ មានន័យថាចំណុចទី៣៖គុណវុឌ្ឍិនាយក ឬនាយិកាសាលារៀនធៀបជាមួយផែនការក្រសួងមានកម្រិតមធ្យមកម្រិតខ្ពស់៣.៧០ (M=3.70) បន្ទាប់មកគឺចំណុចទី១៖គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនមានមធ្យមកម្រិតខ្ពស់ដែរគឺ៣.៤៤ ( M= 3.44) និងចំណុច ទី២៖ចំនួនគ្រូខ្វះមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា)ចុះថយធៀបជាមួយបទដ្ឋានដែលមានមធ្យម៣.០៧(M=3.07) ជាលំដាប់ចុងក្រោយគេនៅក្នុងផ្នែក ធនធានមនុស្ស។

ជារួមមកការពិនិត្យទៅលើធនធានមនុស្សយើងសង្កេតឃើញថាគុណវុឌ្ឍិគ្រូ ក៏ដូចជាគុណវុឌ្ឍិនាយកមានកម្រិតល្អច្រើនស្របទៅតាមគោលការណ៍ ការពង្រឹងសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ឯចំណុចប្រឈមគឺរបាយគ្រូបង្រៀនតាមមុខវិជ្ជានៅមិនទាន់បានគ្រប់គ្រាន់តាមតម្រូវការ។

**តារាងទី៧៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃផ្នែក សៀវភៅសិក្សាគោលសម្ភារៈបង្រៀន និងបង្រៀន(N= ១១៤)

| ល.រ | ខ្លឹមសារ | សៀវភៅសិក្សាគោល សម្ភារៈរៀន និងបង្រៀន | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ភាគរយសិស្សមានសៀវភៅគោលតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់តាមបទដ្ឋាន | ៣.៣៩ | ០.៨៦ | មធ្យម | ១ |
| ២ | ចំនួនគ្រូបង្រៀនមុខវិជ្ជាគោលបានបំប៉នពីការ ប្រើប្រាស់សៀវភៅលំហាត់ | ២.៩០ | ១.០១ | មធ្យម | ៤ |
| ៣ | បណ្ណាល័យបានបង្កើត និងមានស្តង់ដា | ៣.២១ | ១.១៧ | មធ្យម | ២ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ការបង្កើតសម្ភារៈឧទ្ទេស សម្រាប់ដំណើរការបង្រៀន និងរៀន | ៣.១៨ | ០.៨៥ | មធ្យម | ៣ |
| **សរុប** | | **៣.១៧** | **០.៧៣** | **មធ្យម** | |

យោងតាមតារាងខាងលើបង្ហាញថាក្នុងផ្នែក សៀវភៅសិក្សាគោល សម្ភារៈរៀន និងបង្រៀន មានកម្រិតមធ្យមចាប់ពី៣.៣៩លំដាប់ទីមួយ រហូតដល់ចំណុចកម្រិត មធ្យម ២.២៩លំដាប់ចុងក្រោយ ។ មានន័យថានៅចំណុចទី៖ ភាគរយសិស្សមានសៀវភៅគោលតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់តាមបទដ្ឋានមានកម្រិតមធ្យម៣.៣៩ ( M=3.39) បន្ទាប់មកគឺចំណុច ទី៣៖បណ្ណាល័យបានបង្កើត និងមានស្តង់ដា មានកម្រិតមធ្យម ៣.២១ (M= 3.21) បន្ទាប់មកទៀតគឺចំណុចមធ្យម ៣.១៨គឺ( M= 3.21) ចុងក្រោយគឺចំណុច២៖ ចំនួនគ្រូបង្រៀនមុខវិជ្ជាគោលបានបំប៉នពីការ ប្រើប្រាស់សៀវភៅលំហាត់មានកម្រិតមធ្យម ២.៩០ ( M= 2...90) ដែលជាចំណុចដែលមានលំដាប់ទាបជាងគេ។

ជារួមមកនៅក្នុងផ្នែកសៀវភៅសិក្សាគោល សម្ភារៈរៀន និងបង្រៀន មិនមានមធ្យមកម្រិតខ្ពស់ទេ ហើយក៏មិនមានមធ្យមកម្រិតទាបដែរ មានតែមធ្យមកម្រិតមធ្យម ដែលមានលំដាប់ពីថ្នាក់ពីលេខ១ដល់លេខ៤ នេះសរបញ្ជាក់ឱ្យឃើញថាសៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀននៅមានការខ្វះខាតនៅឡើយ។

**តារាងទី៨៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ហេដ្ឋារចនាសម្ព័ន្ធ និង បរិស្ថានសាលារៀន (N= ១១៤)

| ល.រ | ខ្លឹមសារ | ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | កង្វះបន្ទប់រៀនថយចុះរហូតមានចំនួនសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន | ២.៩៧ | ១.២៥ | មធ្យម | ៣ |
| ២ | បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាងសង់ តាមតម្រូវការ | ២.៨៦ | ១.៤៩ | មធ្យម | ៤ |
| ៣ | បន្ទប់រដ្ឋបាលសាលារៀន និងសង្ហារឹមបានផ្តល់ តាមតម្រូវការ | ៣.១៣ | ១.១៦ | មធ្យម | ២ |

| | | | | | |
|---|---|---|---|---|---|
| ៤ | បន្ទប់ទឹកបានសាងសង់តាមស្តង់ដា និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្សទាំងស្រីទាំងប្រុស | ៣.៣១ | ១.០១ | មធ្យម | ១ |
| **សរុប** | | **៣.០៧** | **០.៨៩** | **មធ្យម** | |

យោងតាមតារាងខាងលើបង្ហាញថា នៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន គឺមានមធ្យមចាប់ពី ៣.៣១ រហូតដល់ ២.៨៨ ។ មានន័យថានៅចំណុច ទី៤ៈបន្ទប់ទឹកបានសាងសង់តាមស្តង់ដា និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្សទាំងស្រីទាំងប្រុសមានកម្រិតមធ្យម ៣.៣១ ( M= 3.31) ជាលំដាប់ទី១ បន្ទាប់មកចំណុច ទី៣ៈបន្ទប់រដ្ឋបាលសាលារៀន និងសង្ហារឹមបានផ្តល់ តាមតម្រូវការ មានកម្រិតមធ្យម ៣.១៣ (M=3.13)ឯចំណុចទី២ៈបន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាងសង់ តាមតម្រូវការមានកម្រិតមធ្យម២.៨៨(M=2.88) ដែលជាកម្រិតមធ្យមមានកម្រិតលំដាប់ក្រោមគេ។

រួមមកអាចបញ្ជាក់បានថាផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន នៅមានកម្រិតមធ្យមនៅឡើយ និងនៅមានចំណុចខ្វះខាតដូចបន្ទប់ស្នាក់នៅរបស់គ្រូមិនទាន់មានសម្រាប់គ្រូដែលមកពីឆ្ងាយសម្រាប់ស្នាក់នៅដែលជាតម្រូវការចាំបាច់សម្រាប់លើកទឹកចិត្តគ្រូក្នុងការបង្ហាត់បង្រៀនសិស្សដោយភាពកក់ក្តៅផងដែរ។

**តារាងទី៩ៈ** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ (N= ១១៤)

| ល.រ | ខ្លឹមសារ | ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ថវិកាសាលារៀន ពីប្រភពផ្សេងៗ បានទទួល ដាក់ស្តែងតាមត្រឹមាស មានភាពប្រសើរឡើង | ៣.៣៣ | ១.០៤ | មធ្យម | ៣ |
| ២ | ការចាត់ចែង ការប្រើប្រាស់និងតម្លាភាពថវិកា សាលារៀនបានប្រសើរ | ៣.៥៤ | ០.៩៩ | ខ្ពស់ | ២ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ការរាយការណ៍ការចំណាយតាមខ្ទង់ចំណាយ ធំៗ (រដ្ឋបាល ការបង្រៀន និងរៀននិងបរិស្ថាន) បានប្រសើរដោយផ្ដោតការចំណាយលើការបង្រៀននិងរៀន | ៣.៥៨ | ០.៨៧ | ខ្ពស់ | ១ |
| | **សរុប** | **៣.៤៨** | **០.៨៩** | **មធ្យម** | |

យោងតាមតារាងខាងលើផ្នែកហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ បានបង្ហាញពីកម្រិតមធ្យមពី ៣.៥៨ ដល់៣.៣៣ ដែលមានន័យថានៅចំណុចទី៣៖ការរាយការណ៍ការចំណាយតាមខ្ទង់ចំណាយ ធំៗ (រដ្ឋបាល ការបង្រៀន និងរៀននិងបរិស្ថាន) បានប្រសើរដោយផ្ដោតការចំណាយលើការបង្រៀននិងរៀន មានកម្រិតមធ្យម៣.៥៤ (M=3.54) ដែលជាមធ្យមកម្រិតខ្ពស់ បន្ទាប់មកគឺចំណុចទី២៖ការចាត់ចែងការប្រើប្រាស់និងតម្លាភាពថវិកា សាលារៀនបានប្រសើរដែលមានកម្រិតមធ្យម ៣.៥៤( M=3.54) ជាមធ្យមកម្រិតខ្ពស់ និងចំណុចទី១៖ថវិកាសាលារៀន ពីប្រភពផ្សេងៗ បានទទួល ជាក់ ស្ដែងតាមត្រីមាសមានភាពប្រសើរឡើងមានមធ្យម ៣.៣៣ ( M= 3.33) ដែលជាកម្រិតមធ្យមដែលមានលំដាប់ចុងក្រោយគេ។

ជារួមមកបង្ហាញថាផ្នែកហិរញ្ញប្បទាន ការគ្រប់គ្រងហិរញ្ញវត្ថុ គឺលោកគ្រូ អ្នកគ្រូទាំងអស់យល់ថាការរាយការណ៍ពីការចំណាយថវិកាចំណាយតាមខ្ទង់ចំណាយ ធំៗ (រដ្ឋបាល ការបង្រៀន និងរៀននិងបរិស្ថាន) បានប្រសើរដោយផ្ដោតការចំណាយលើការបង្រៀននិងរៀនបានល្អប្រសើរហើយ ចំណែកឯថវិកាសាលារៀន ពីប្រភពផ្សេងៗ បានទទួល ជាក់ស្ដែងតាមត្រីមាសគឺពុំទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេ។

**តារាងទី១០៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់តាមផ្នែកនីមួយៗរបស់លោកគ្រូ អ្នកគ្រូទៅលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន (N= ១១៤)

| ល.រ | ខ្លឹមសារ | សរុបទិន្នន័យគ្រូ | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ការគ្រប់គ្រងរដ្ឋបាលសាលារៀន | ៣.៩២ | ០.៥៦ | ខ្ពស់ | ១ |
| ២ | ការគ្រប់គ្រងការរៀននិងបង្រៀន | ៣.៦៨ | ០.៧២ | ខ្ពស់ | ២ |
| ៣ | មាតបិតា និងសហគមន៍ជួយការសិក្សាសិស្ស | ៣.៤០ | ១.០៨ | មធ្យម | ៦ |
| ៤ | សិស្ស និងសេវាជួយសិស្ស | ២.៥៥ | ០.៦១ | មធ្យម | ៩ |

| | | | | | |
|---|---|---|---|---|---|
| ៥ | ការដឹកនាំ និងការគ្រប់គ្រងសាលារៀន | ៣.៥៥ | ០.៩០ | ខ្ពស់ | ៣ |
| ៦ | ធនធានមនុស្ស | ៣.៤០ | ០.៦៥ | មធ្យម | ៥ |
| ៧ | សៀវភៅសិក្សាគោលនិងសម្ភារៈរៀន និងបង្រៀន | ៣.១៧ | ០.៧៣ | មធ្យម | ៧ |
| ៨ | ហេដ្ឋារចនាសម្ព័ន្ធសាលារៀន | ៣.០៧ | ០.៨៨ | មធ្យម | ៨ |
| ៩ | ការគ្រប់គ្រងហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ | ៣.៤៨ | ០.៨៩ | មធ្យម | ៤ |

យោងតាមតារាងស្ថិតិរួមរបស់លោកគ្រូ អ្នកគ្រូលើវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនបានបង្ហាញថាមានកម្រិតមធ្យមចាប់ពី៣.៩២ រហូតដល់២.៥៥។ មានន័យថានៅចំណុចទី១៖ ការគ្រប់គ្រងរដ្ឋបាលសាលារៀនមានមធ្យម៣.៩២(M=3.92) ដែលជាមធ្យមកម្រិតខ្ពស់។ ចំណុចទី២៖ ការគ្រប់គ្រងការបង្រៀន និងរៀនមានកម្រិតមធ្យម៣.៦៨(M=3.68) ដែលជាមធ្យមកម្រិតខ្ពស់។ ចំណាទី៣៖ ការដឹកនាំនិងការគ្រប់គ្រងសាលារៀនមានមធ្យម៣.៥៥( M=3.55)ដែលជាមធ្យមកម្រិតខ្ពស់ដែរ។ ចំណុចទី៤៖ សិស្ស និងសេវាជួយសិស្សមានមធ្យម២.៥៥( M=2.55) ដែលមធ្យមដែលមានមធ្យមនៅលំដាប់ទាបជាងគេបំផុត។ បន្ទាប់មកគឺចំណុចទី៨៖ ហេដ្ឋរចនាសម្ព័ន្ធសាលារៀនមានមធ្យម៣.០៧ (M=3.07 ) ដែលជាមធ្យមកម្រិតទាបបន្ទាប់។ ចំណែកឯចំណុចទី៧៖ ផ្នែកសៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀនមានមធ្យម៣.១៧
(M=3.17 ) ជាមធ្យមកម្រិតនៅលំដាប់ទាបដែរ។

ជារួមមបង្ហាញថាទស្សនះរបស់លោកគ្រូ អ្នកគ្រូលើវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនបានបង្ហាញថាចំណុចដែលល្អស្របតាមស្តងដានៃការអនុវត្តការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាពគឺចំណុចទី១(ការគ្រប់គ្រងរដ្ឋបាលសាលារៀន) ចំណុចទី២( ការគ្រប់គ្រងការបង្រៀន និងរៀន) និងចំណុចទី( ការដឹកនាំ និងការគ្រប់គ្រងសាលារៀន) ដែលមានមធ្យមកម្រិតខ្ពស់។ ចំណែកចំណុចដែលនៅមានកង្វះខាតគឺចំណុចទី៤(សិស្ស និងសេវាជួយសិស្ស) ចំណុចទី៨( ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងបរិស្ថានសាលារៀន) និងចំណុចទី៧( សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន)។

## ខ.កម្រងសំណួរសម្រាប់សួរនៅលើសិស្សានុសិស្សនៅមធ្យមសិក្សាទុតិយភូមិ

នៅក្នុងសំណួរផ្នែកទី២នេះ អ្នកស្រាវជ្រាវចង់ដឹងពីការយល់ឃើញរបស់សិស្សានុសិស្សទៅលើកម្រិតនៃការប្រតិបត្តិការងាររដ្ឋបាលរបស់គណៈនាយក ក៏ដូចជាលោកគ្រូ អ្នកគ្រូ នៅកម្រិតមធ្យមសិក្សាទុតិភូមិក្នុងការលើកកម្ពស់ការបង្រៀន និងរៀននៅខេត្ត ស្វាយរៀងបានសួរទៅលើសិស្ស ចំនួន ១៩៤នាក់ ដែលស្ថិតនៅវិទ្យាល័យចំនួន៥ ក្នុងខេត្តស្វាយរៀង។

ឧបករណ៍ស្រាវជ្រាវក្នុងផ្នែករដ្ឋបាលសិក្សា អ្នកសិក្សាបានប្រើកម្រងសំណួរជ្រើសរើសដែលមានសំណួរចំនួន២៥សំណួរ ហើយចែកចេញជា ៤ ផ្នែកទី១៖ ការគ្រប់គ្រង និងការបង្រៀន របស់លោក លោកនាយក លោកគ្រូអ្នកគ្រូ(មាន ៦ ចំណុច ចាប់ពី ១.១ ដល់១. ៦) ផ្នែកទី២៖ ការបង្រៀន និងរៀនរបស់លោក

គ្រូ អ្នកគ្រូ (មាន ៩ ចំណុច ចាប់ពី ២.១ ដល់២. ៩) ផ្នែកទី៣៖ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស (មាន ៤ ចំណុច ចាប់ពី ៣.១ ដល់ ៣.៤) ផ្នែកទី៤៖ (មាន៥ចំណុច ចាប់ពី៤.១ ដល់ ៤.៥) ។

ស្ថិតិដែលប្រើរួមមាន ភាគរយ(%) មធ្យមភាគ(Mean) គម្លាតស្តង់ដា(Standard deviation) ដើម្បីបង្ហាញឲ្យឃើញនូវកម្រិតប្រតិបត្តិរបស់ គណៈនាយក លោកគ្រូ អ្នកគ្រូនៅតាមសាលារៀន ។ យោងតាម ការបែងចែកកម្រិតដែលចងក្រងដោយ Oxford និងBurry-Stock (1995) កម្រិតមធ្យមត្រូវបានគេបែងចែកជា បីក្រុម គឺកម្រិតខ្ពស់ (M=3.50 ឡើង) កម្រិតមធ្យម (M=2.50 – 3.49) និងកម្រិតទាប (M=2.49 ចុះ)។

**តារាងទី១៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃការងារគ្រប់គ្រង និងត្រួតពិនិត្យលើការបង្រៀន របស់ លោកគ្រូ អ្នកគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៩៤)។

| ល.រ | ខ្លឹមសារ | ការគ្រប់គ្រង និងត្រួតពិនិត្យលើការបង្រៀន របស់លោកគ្រូ អ្នកគ្រូ | | កម្រិត | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | មានការរៀបចំរចនាសម្ព័ន្ធ និងបំណែងចែកភារកិច្ចរបស់គណៈនាយក គ្រូបង្រៀន និងបានផ្សព្វផ្សាយពីតួនាទីនីមួយៗឱ្យសិស្សបានដឹង | ៣.៥៦ | ០.៨៦ | ខ្ពស់ | ៤ |
| ២ | ការត្រួតពិនិត្យ បរិស្ថាន អនាម័យជាប្រចាំ | ៣.៥៣ | ០.៩៣ | ខ្ពស់ | ៥ |
| ៣ | ការបែងចែកកាលវិភាគ និងម៉ោងបង្រៀនរបស់លោកគ្រូ អ្នកគ្រូ | ៣.៩៩ | ០.៨១ | ខ្ពស់ | ២ |
| ៤ | ការប្រជុំជាមួយសិស្សតាមកាលកំណត់ដើម្បីពង្រឹងវិន័យ និងផ្សព្វផ្សាយពីព័ត៌មានថ្មីៗដែលទាក់ទងទៅនឹងការបង្រៀន និងរៀន | ៤.២៦ | ០.៣៧ | ខ្ពស់ | ១ |
| ៥ | ការពិនិត្យអវត្តមានសិស្សានុសិស្សជាប្រចាំ | ៣.៨០ | ០.៩៨ | ខ្ពស់ | ៣ |

| | | | | | |
|---|---|---|---|---|---|
| ៦ | ការចូលមើលការបង្រៀន និងរៀនរបស់លោកគ្រូ អ្នកគ្រូ | ២.៨៩ | ១.0៦ | មធ្យម | ៦ |
| **សរុប** | | **៣.៦៧** | **0.៨៨** | **ខ្ពស់** | |

យោងតាមតារាងទី១មួយបង្ហាញថាការគ្រប់គ្រង និងការត្រួតពិនិត្យលើការបង្រៀនរបស់លោកគ្រូ អ្នកគ្រូមានចំណុចមធ្យមចាប់ពី៤.២៦ រហូតដល់២.២៩។ មានន័យថានៅចំណុចទី៤៖ ការប្រជុំជាមួយសិស្សតាមកាលកំណត់ដើម្បីពង្រឹងវិន័យ និងផ្សព្វផ្សាយពីព័ត៌មានថ្មីៗដែលទាក់ទងទៅនឹងការបង្រៀន និងរៀនមានកម្រិតមធ្យម៤.២៦ (M=4.26) ដែលជាកម្រិតខ្ពស់ បន្ទាប់មកទៀតគឺចំណុចទី៣៖ ការបែងចែកកាលវិភាគ និងម៉ោងបង្រៀនរបស់លោកគ្រូ អ្នកគ្រូ មានកម្រិត៣.៩៩ (M=3.99) រីឯចំណុច ទី៥៖ ការពិនិត្យអវត្តមានសិស្សានុសិស្សជាប្រចាំមានកម្រិតមធ្យម ៣.៨0( M=3.80)ដែលជាកម្រិតខ្ពស់ផងដែរ។ ចំណែកឯកម្រិតមធ្យមដែលលំដាប់ថ្នាក់ក្រោមគេគឺចំណុចទី៦៖ ការចូលមើលការបង្រៀន និងរៀនរបស់លោកគ្រូ អ្នកគ្រូដែលមានកម្រិតមធ្យម ២. ៨៩ (M= 2.89) ។

ជារួមមកយើងអាចបញ្ជាក់បានថានៅក្នុងផ្នែកការគ្រប់គ្រងការបង្រៀន និងរៀនមិនសូវជាមានបញ្ហាចោទប៉ុន្មានទេ តាមតារាងបង្ហាញពីចម្លើយរបស់ប្អូនសិស្សានុសិស្ស។ តែនៅមានចំណុចខ្វះខាតតិចតួចនៅផ្នែកការត្រួតពិនិត្យការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ( អធិការកិច្ចផ្ទៃក្នុង និងក្រៅ)។

តារាងទី២៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៩៤)។

| ល.រ | ខ្លឹមសារ | ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ការគោរពពេលវេលាបង្រៀនរបស់លោកគ្រូ អ្នកគ្រូ | ៣.៦៥ | 0.៨១ | ខ្ពស់ | ៣ |
| ២ | ការប្រើប្រាស់វិធីសាស្ត្របង្រៀនរបស់លោកគ្រូ អ្នកគ្រូបានប្រសើរ ងាយយល់ ងាយស្តាប់ ងាយទទួលបានចំណេះដឹង | ៣.៥១ | 0.៨៦ | ខ្ពស់ | ៥ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ការដាក់កិច្ចការផ្ទះ និងការប្រមូលលទ្ធផល និងការកែកិច្ចការឱ្យសិស្ស ដើម្បីបង្ហាញចំណុចខ្វះខាតរបស់សិស្ស | ៣.២២ | ២.៣៤ | មធ្យម | ៨ |
| ៤ | ការបំពេញរដ្ឋបាលថ្នាក់រៀន(ការពិនិត្យអវត្តមាន សណ្តាប់ធ្នាប់ របៀបរៀបរយ) | ៣.៤៩ | ០.៩៨ | មធ្យម | ៦ |
| ៥ | ការបង្កើតវិញ្ញាសាតេស្តប្រចាំខែ ស្របតាមសមត្ថភាពរបស់សិស្ស | ៣.៧៨ | ០.៩៩ | ខ្ពស់ | ១ |
| ៦ | កែកិច្ចការ និងបញ្ចូលពិន្ទុ | ៣.៧២ | ០.៩០ | ខ្ពស់ | ២ |
| ៧ | ធ្វើអត្រាកំណែលើក្តារខៀន និងបង្ហាញពីចំណុចខ្វះខាតរបស់សិស្ស | ៣.៤៩ | ១.០៣ | មធ្យម | ៧ |
| ៨ | ផ្សព្វផ្សាយលទ្ធផលតេស្ត | ៣.៦៥ | ១.០៣ | ខ្ពស់ | ៤ |
| ៩ | ជួបជាមួយមាតាបិតាសិស្សដែលកូនរៀនយឺតដើម្បីរិះរកមធ្យោបាយជួយកូន | ៣.០០ | ១.១០ | មធ្យម | ៩ |
| **សរុប** | | **៣.៥០** | **០.៦១** | **ខ្ពស់** | |

យោងតាមតារាងទី២ខាងលើបង្ហាញថាការបង្រៀនរបស់លោកគ្រូ អ្នកគ្រូមានកម្រិតមធ្យមចាប់ពី ៣.៧៨ ដល់២.៣៤ ។ មានន័យថានៅចំណុចទី៥៖ ការបង្កើតវិញ្ញាសាតេស្តប្រចាំខែ ស្របតាមសមត្ថភាពរបស់សិស្ស មានកម្រិតមធ្យម៣.៧៨ (M=3.78) ចំណុចទី៦៖ កែកិច្ចការ និងបញ្ចូលពិន្ទុមានកម្រិតមធ្យម៣.៧២ (M=3.72) និងចំណុចទី១៖ការគោរពពេលវេលាបង្រៀនរបស់លោកគ្រូ អ្នកគ្រូ មានមធ្យម ៣.៦៥ (M=3.65) ទាំងបីចំណុចនេះសុទ្ធតែមានកម្រិតមធ្យមកម្រិតខ្ពស់ ។ ចំណែកឯចំណុច ទី៣៖ ជួបជាមួយមាតាបិតាសិស្សដែលកូនរៀនយឺតដើម្បីរិះរកមធ្យោបាយជួយកូនមានមធ្យម៣.០០ (M=3.00) ជាកម្រិតមធ្យមដែលមានលំដាប់ទាបជាងគេនៅក្នុងផ្នែកនេះ។

ជារួមមកតាមរយៈតារាងទី២ខាងលើបង្ហាញថា ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូមានលក្ខណៈល្អច្រើន ចំណុចដែលនៅខ្វះខាតគឺស្ថិតនៅត្រង់ការទាក់ទងជាមួយអាណាព្យាបាលសិស្ស។

**តារាងទី៣៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃមាតបិតា និងសហគមន៍ជួយការសិក្សាសិស្ស កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៩៤)។

| ល.រ | ខ្លឹមសារ | មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | មាតាបិតាសិស្សតែងចូលរួមប្រជុំជាមួយគណៈនាយក និងលោកគ្រូអ្នកគ្រូដើម្បីដោះស្រាយបញ្ហាការសិក្សារៀនសូត្ររបស់សិស្ស | ២.៥២ | ១.០៨ | មធ្យម | ៥ |
| ២ | មាតាបិតាសិស្សមានទំនាក់ទំនងល្អជាមួយសាលារៀន | ២.៩៥ | ១.០៥ | មធ្យម | ៤ |
| ៣ | សេវាផ្តល់ព័ត៌មានពីសាលាសហគមន៍ មាតាបិតាសិស្ស | ៣.១៩ | ១.០៩ | មធ្យម | ២ |
| ៤ | ភាគរយសិស្សមករៀនយឺតមានចំនួនតិចបំផុត | ៣.៣៧ | ០.៨៧ | មធ្យម | ១ |
| ៥ | ភាគរយសិស្សបានធ្វើកិច្ចការផ្ទះឬកិច្ចការតាមគម្រោង | ៣.១១ | ០.៨២ | មធ្យម | ៣ |
| សរុប | | ៣.០២ | ០.៦៩ | មធ្យម | |

យោងតាមតារាងទី៣បានបង្ហាញថាក្នុងផ្នែកមាតាបិតា និងសហគមន៍ជួយដល់ការសិក្សាសិស្សគឺមានកម្រិតមធ្យមចាប់ពី៣.៣៧ រហូតដល់២. ៥២ ។ មានន័យថានៅចំណុចទី៤៖ ភាគរយសិស្សមករៀនយឺតគឺមានកម្រិតមធ្យម៣.២៧ ( M= 3.37) បន្ទាប់គឺចំណុច គឺ៣៖សេវាផ្តល់ព័ត៌មានពីសាលាសហគមន៍ មាតាបិតាសិស្ស មានកម្រិតមធ្យម៣.១៩ (M=3.19) បន្ទាប់មកទៀតគឺចំណុចទី៥មានកម្រិតមធ្យម៣.១១ ( M=3.11) ទាំងបីនេះគឺជាកម្រិតមធ្យមដែលមានលេខលំដាប់លើគេ។ ចំណែកឯ ចំណុចដែលមានកម្រិតមធ្យមនៅលំដាប់ក្រោមគេគឺចំណុចទី១៖ មាតាបិតាសិស្សតែងចូលរួមប្រជុំជាមួយគណៈនាយក និងលោកគ្រូអ្នកគ្រូដើម្បីដោះស្រាយបញ្ហាការសិក្សារៀនសូត្ររបស់សិស្ស មានកម្រិតមធ្យម ២.៥២ (M=2.52)។

ជារួមមកតាមតារាងទី៣ ចង់បង្ហាញថាក្នុងផ្នែកមាតាបិតា និង សហគមន៍ជួយការសិក្សារបស់សិស្សគឺស្ថិតនៅក្នុងលំដាប់កម្រិតមធ្យមពុំទាន់មាន លក្ខណៈខ្ពស់នៅឡើយទេ។

**តារាងទី៤៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃ សិស្ស និងសេវាជួយសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៩៤)

| ល.រ | ខ្លឹមសារ | សិស្ស និងសេវាជួយសិស្ស | [illegible] | [illegible] |
|---|---|---|---|---|

| | | មធ្យម | គម្លាតស្តង់ដា | | |
|---|---|---|---|---|---|
| ១ | សិស្សប្រើបណ្ណាល័យ | ២.៧៩ | ១.០៧ | មធ្យម | ១ |
| ២ | សិស្សប្រើបន្ទប់ពិសោធន៍ | ២.៦០ | ១.២៧ | មធ្យម | ៣ |
| ៣ | សិស្សដែលអាចប្រើកុំព្យូទ័រ | ២.៦៣ | ១.២៧ | មធ្យម | ២ |
| ៤ | សិស្សបង្កើតក្លឹបសិក្សា | ២.២០ | ១.១០ | ទាប | ៤ |
| **សរុប** | | **២.៥៦** | **០.៩២** | **មធ្យម** | |

យោងតាមតារាងទី៤ក្នុងផ្នែកសិស្ស និងសេវាជួយសិស្ស គឺការយល់ឃើញរបស់សិស្សទៅលើផ្នែកនេះគឺមានកម្រិតមធ្យមចាប់ពី ២.៧៩ រហូតដល់២.២០។ មានន័យថានៅចំណុចទី១៖ សិស្សប្រើ បណ្ណាល័យ មានកម្រិតមធ្យម ២.៧៩ ( M=2.79) ជាកម្រិតមធ្យមដែលមានលំដាប់លើគេ បន្ទាប់មកទៀតគឺចំណុចទី៖៤សិស្សបង្កើតក្លឹបសិក្សា គឺមានកម្រិតមធ្យម ២.២០ ( M=2.20) ដែលជាមធ្យមកម្រិតទាប។

ជារួមមកអាចបញ្ជាក់បានថានៅចំណុចសិស្ស និងសេវាជួយសិស្សគឺមិនមានកម្រិតមធ្យមខ្ពស់នោះទេ គឺផ្នែកនេះនៅជួបបញ្ហាប្រឈមជាច្រើនតាំងពីការប្រើប្រាស់ បណ្ណាល័យ របស់សិស្សនៅមានកម្រិតមធ្យម បន្ទប់ពិសោធន៍ក៏ពុំទាន់មាននៅតាមសាលាមួយចំនួន ចំណែកការបង្កើតឱ្យមានក្លឹបសិក្សាគឺនៅមានកម្រិតទាបបំផុត។

**តារាងទី៥៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់តាមផ្នែកនីមួយៗរបស់សិស្សានុសិស្សទៅលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន (N= ១៩៤)

| ល.រ | ខ្លឹមសារ | សរុបការវិភាគទិន្នន័យសិស្ស | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ការគ្រប់គ្រង របស់លោកនាយក លោកគ្រូ អ្នកគ្រូ | ៣.៦៧ | ០.៨៨ | ខ្ពស់ | ១ |

| | | | | | |
|---|---|---|---|---|---|
| ២ | ការបង្រៀន របស់លោកគ្រូ អ្នកគ្រូ | ៣.៥០ | ០.៦១ | ខ្ពស់ | ២ |
| ៣ | មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស | ៣.០២ | ០.៦៨ | មធ្យម | ៣ |
| ៤ | សិស្ស និងសេវាជួយសិស្ស | ២.៥៦ | ០.៩២ | មធ្យម | ៤ |

យោងតាមតារាងខាងលើបង្ហាញឱ្យឃើញថាការវាយតម្លៃរបស់សិស្សានុសិស្សទៅលើការអនុវត្តការគ្រប់គ្រងតាមសាលារៀបរបស់លោកគ្រូ អ្នកគ្រូមានកម្រិតមធ្យមចាប់ពី៣.៦៧ រហូតដល់២.៥៦ គឺមានន័យថានៅផ្នែកៈ ការគ្រប់រដ្ឋបាលសាលារៀនរបស់លោកគ្រូ អ្នកគ្រូមានកម្រិតមធ្យម៣.៦៧ ( M=3.76) ជាមធ្យមកម្រិតខ្ពស់។ នៅផ្នែកៈ ការបង្រៀន និងរៀន មានមធ្យម៣.៥០( M=3.50) ជាមធ្យមកម្រិតខ្ពស់ដែរ។ រីឯផ្នែក មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស មានមធ្យម៣.០២(M=3.2)ជាកម្រិតមធ្យម ។ ចំណែកឯផ្នែកៈ សិស្ស និងសេវាជួយសិស្ស មានមធ្យម២.៥៦ (M=2.56) ជាកម្រិតមធ្យមដែលមានលំដាប់ទាបជាងគេ។ នេះបញ្ជាក់ឱ្យឃើញថានៅផ្នែក សិស្ស និងសេវាជួយសិស្សនៅមិនទាន់សម្រេចបានតាមលក្ខណៈស្តង់ដាគុណភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅឡើយទេ។

## គ.កម្រងសំណួរសម្រាប់លើគណៈនាយក

នៅក្នុងសំណួរផ្នែកទី៣នេះ អ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃការប្រតិបត្តិការងាររដ្ឋបាលរបស់គណៈនាយក ក៏ដូចជាលោកគ្រូ អ្នកគ្រូ នៅកម្រិតមធ្យមសិក្សាទុតិភូមិក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន នៅខេត្ត ស្វាយរៀងបានសួរទៅលើនាយក នាយករង ចំនួន ១៥នាក់ ដែលស្ថិតនៅវិទ្យាល័យចំនួន៥ ក្នុងខេត្តស្វាយរៀង។

ឧបករណ៍ស្រាវជ្រាវក្នុងផ្នែករដ្ឋបាលសិក្សា អ្នកសិក្សាបានប្រើកម្រងសំណួរជ្រើសរើសដែលមានសំណួរចំនួន៤៦សំណួរ ហើយចែកចេញជា ៩ផ្នែកៈ ផ្នែកទី១ រដ្ឋបាលសិក្សា(មាន ៦ ចំណុច ចាប់ពី ១.១ដល់ ១.៦)ផ្នែកទី២ ការបង្រៀន និងរៀន(មាន ៩ ចំណុច ចាប់ពី ២.១ ដល់២. ៩) ផ្នែកទី៣ មាតាបិតា និងសហគមន៍ជួយសិស្ស (មាន ៤ ចំណុច ចាប់ពី ៣.១ ដល់ ៣.៤) ផ្នែកទី៤ (មាន ៧ចំណុច ចាប់ពី៤.១ ដល់ ៤.៧) ផ្នែកទី៥ ( មាន៦ ចំណុច ចាប់ពី ៥.១ ដល់ ៥.៦) ផ្នែកទី៦(មាន ៣ចំណុច ចាប់៦.១ ដល់ ៦.៣) ផ្នែកទី៧ (មាន៤ ចំណុច ចាប់ពី៧.១ ដល់ ៧.៤) ផ្នែកទី៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន( មាន៤ ចំណុច ចាប់ពី៨.១ ដល់ ៨.៤) និងផ្នែកទី៩ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ( មាន៣ចំណុច ចាប់ពី៩.១ ដល់៩.៣)។

ស្ថិតិដែលប្រើវិភាគរួមមាន ភាគរយ(%) មធ្យមភាគ(Mean) គម្លាតស្តង់ដា (Standard deviation) ដើម្បីបង្ហាញឲ្យឃើញនូវកម្រិតប្រតិបត្តិរបស់ គណៈនាយក លោកគ្រូ អ្នកគ្រូនៅតាមសាលារៀន ។ យោងតាម ការបែងចែកកម្រិតដែលចងក្រងដោយ Oxford និងBurry-Stock (1995)កម្រិតមធ្យមត្រូវបានគេបែងចែកជា បីក្រុម គឺកម្រិតខ្ពស់ (M=3.50 ឡើង)កម្រិតមធ្យម (M=2.50–3.49) និងកម្រិតទាម (M=2.49 ចុះ)។

**តារាងទី១៖** មធ្យម គម្លាតស្តង់ដា អរអត្ថន័យ និង លំដាប់កម្រិតនៃរដ្ឋបាលសិក្សារបស់លោកនាយក លោកគ្រូ អ្នកគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | រដ្ឋបាលសិក្សា | | កម្រិត | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | បានអនុវត្តតាមការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងបំណែងចែកភារកិច្ចរបស់គណៈនាយក លោកគ្រូ អ្នកគ្រូ | ៤.២៧ | ០.៧០ | ខ្ពស់ | ៣ |
| ២ | រៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្រប | ៤.៤០ | ០.៥១ | ខ្ពស់ | ២ |
| ៣ | ការបែងចែក កាលវិភាគ និងម៉ោងបង្រៀន | ៤.៤៧ | ០.៥២ | ខ្ពស់ | ១ |
| ៤ | ការរៀបចំឱ្យមានការប្រជុំក្រុមបច្ចេកទេសបានតាមការកំណត់ | ៤.២០ | ០.៥៦ | ខ្ពស់ | ៤ |
| ៥ | ការពិនិត្យតាមដានអវត្តបុគ្គលិកជាប្រចាំ | ៤.០៧ | ០.៧០ | ខ្ពស់ | ៥ |
| ៦ | ការរៀបចំប្រព័ន្ធអធិការកិច្ចអចិន្ត្រៃ | ៣.៦០ | ០.៩១ | ខ្ពស់ | ៦ |
| សរុប | | ៤.១៧ | ០.៥៨ | ខ្ពស់ | |

យោងតាមតារាងទី១ដែលនិយាយពី រដ្ឋបាលសិក្សាបានបង្ហាញពីកម្រិតមធ្យមចាប់ពី៤.៤៧ដល់ ៣.៦០ ។ មានន័យថានៅចំណុចទី៣៖ ការបែងចែក កាលវិភាគ និងម៉ោងបង្រៀនមានកម្រិតមធ្យម៤.៤៧ ( M= 4.47) បន្ទាប់មកគឺចំណុចទី២៖ រៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្របមានកម្រិតមធ្យម ៤.៤០ ( M=4.40) និងបន្ទាប់មកទៀតគឺចំណុចទី១៖ បានអនុវត្តតាមការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងបំណែងចែកភារកិច្ចរបស់គណៈនាយក លោកគ្រូ អ្នកគ្រូ មានកម្រិតមធ្យម៤.៣១( M=4.31) ចំណុចទាំងបីនេះគឺជាចំណុចដែលមានកម្រិតមធ្យមកម្រិតខ្ពស់។ ចំណែកឯចំណុច ទី៦៖ ការរៀបចំប្រព័ន្ធអធិការកិច្ចអចិន្ត្រៃ មានកម្រិតមធ្យម៣.៦០( M=3.60) ដែលជាកម្រិតមធ្យមកម្រិត
ខ្ពស់ស្ថិតនៅក្នុងលំដាប់ក្រោមគេនៅក្នុងផ្នែករដ្ឋបាលនេះ។

**តារាងទី២៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃការបង្រៀន និងរៀន របស់លោក អ្នកគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | ការរៀន និងបង្រៀន | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជានីមួយៗ | ៤.៤០ | ០.៥១ | ខ្ពស់ | ១ |
| ២ | ការសរសេរកិច្ចតែងការតាមមុខវិជ្ជាគោលនីមួយៗ | ៣.៦៧ | ០.៧២ | ខ្ពស់ | ៦ |
| ៣ | ការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ និងការប្រមូលលទ្ធផល | ៣.៣៣ | ០.៤៩ | មធ្យម | ៧ |
| ៤ | ការបំពេញរដ្ឋបាលថ្នាក់រៀន | ៤.០៧ | ០.៨៨ | ខ្ពស់ | ៥ |
| ៥ | ការបង្កើតវិញ្ញាសាតេស្តប្រចាំខែ | ៤.២០ | ០.៧៧ | ខ្ពស់ | ៤ |
| ៦ | ធ្វើតេស្តស្តង់ដារប្រចាំខែ | ៤.៤០ | ០.៥១ | ខ្ពស់ | ២ |
| ៧ | កែកិច្ចការ និងបញ្ចូលពិន្ទុ | ៤.២៧ | ០.៤៦ | ខ្ពស់ | ៣ |
| ៨ | ផ្សព្វផ្សាយលទ្ធផលតេស្តនៅតាមភូមិ | ៣.២០ | ១.៣២ | មធ្យម | ៨ |
| ៩ | ជួបជាមួយមាតាបិតាសិស្សដែលកូនរៀនយឺតដើម្បីរិះរកមធ្យោបាយជួយកូន | ៣.១៣ | ០.៦៤ | មធ្យម | ៩ |
| **សរុប** | | **៣.៨៥** | **.៨៦០** | **ខ្ពស់** | |

យោងតាមតារាងទី២ខាងលើបានបង្ហាញថា ការបង្រៀន និងរៀន មានកម្រិតមធ្យមចាប់ពី៤.៣៨ រហូត ៣.២៣ ។ មានន័យថាចំណុចទី៦៖ ធ្វើតេស្តស្តង់ដារប្រចាំខែ មានកម្រិតមធ្យម៤.៣៨ (M=38) បន្ទាប់មកគឺចំណុចទី៧៖ កែកិច្ចការ និងបញ្ចូលពិន្ទុ មានកម្រិតមធ្យម ៤.៣១ ( M=4.31) និងបន្ទាប់មកទៀតគឺចំណុចទី១៖ បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជានីមួយៗ មានកម្រិតមធ្យម ៤.៣៨ (M=4.38)

ចំណុចទាំងបីនេះចំណុចដែលមានកម្រិតមធ្យមខ្ពស់ជាងគេនៅក្នុងផ្នែក ការបង្រៀន និងរៀន ។ចំណែកឯចំណុចទី៩៖ ជួបជាមួយមាតាបិតាសិស្សដែលកូនរៀនយឺតដើម្បីរិះរកមធ្យោបាយជួយកូនមានកម្រិតមធ្យម ៣.២៣( M= 3.23 )ដែលជាកម្រិតមធ្យមស្ថិតនៅលំដាប់ក្រោមគេ ។

ជារួមមកយើងអាចបញ្ជាក់បានថានៅក្នុងផ្នែកការបង្រៀនរបស់ លោកគ្រូ អ្នកគ្រូ និងការងារបច្ចេកទេសផ្សេងគឺពួកគាត់ធ្វើបានល្អហើយ តែនៅមានបញ្ហាប្រឈមមួយចំនួនដែលមិនទាន់ធ្វើបានល្អគឺចំណុចទំនាក់ទំនងជាមួយមាតាបិតាសិស្សដែលរៀនយឺតដើម្បីរកមធ្យោបាយជួយកូនដែលខ្សោយ។

**តារាងទី៣៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃ មាតាបិតា និងសហគមន៍ជួយសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | មាតាបិតា និងសហគមន៍ជួយសិស្ស | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ភាគរយថ្នាក់រៀនបានប្រជុំប្រឹក្សាយោបល់រវាង គ្រូបង្រៀន មាតាបិតា និងសិស្ស (នៅដើមឆ្នាំសិក្សានិងតាមត្រីមាស) | ៣.៦៧ | 0.៩0 | ខ្ពស់ | ១ |
| ២ | ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀន តាមការណែនាំ (ពេលបើកបវេសនកាល ចុងឆមាសទី១ និងទី២) | ៣.៤៧ | 0.៦៤ | ខ្ពស់ | ២ |
| ៣ | ភាគរយសិស្សដែលមករៀនយឺតមានចំនួនតិចតួចតួចបំផុត | ៣.0៧ | 0.៥៩ | មធ្យម | ៣ |
| ៤ | ភាគរយសិស្សបានធ្វើកិច្ចការផ្ទះឬកិច្ចការគម្រោង | ២.៩៣ | 0.៧0 | មធ្យម | ៤ |
| សរុប | | ៣.២៨ | 0.៦0 | មធ្យម | |

យោងតាមតារាងទី៣ខាងលើបង្ហាញថានៅក្នុងផ្នែក មាតាបិតា និងសហគមន៍ជួយសិស្សមានកម្រិតមធ្យមចាប់ពី៣.៧៧ រហូតដល់ ៣.00។ មានន័យថាចំណុចទី ២៖ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនតាមការណែនាំ(ពេលបើកបវេសនកាល ចុងឆមាសទី១ និងទី២) មានកម្រិតមធ្យម ៣. ៧៧ (M=3.77) បន្ទាប់មកគឺចំណុច ទី៣៖ ភាគរយសិស្សដែលមករៀនយឺត ដែលមានកម្រិតមធ្យម ៣.៦២ ( M= 3.62) ដែលកម្រិតមធ្យមកម្រិតខ្ពស់ ។ រីចំណុចទី៤៖ ភាគរយសិស្សបានធ្វើកិច្ចការផ្ទះឬកិច្ចការគម្រោង មានកម្រិតមធ្យម ៣.00 ( M=3.00) ដែលជាកម្រិតមធ្យមដែលមានលំដាប់ទាបជាងគេ។

ជារួមមកតាមតារាងទី៣ខាងលើបានបង្ហាញថានៅផ្នែកមាតាបិតា និងសហគមន៍ជួយសិស្សមានចំណុចល្អនៅលើផ្នែក ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀន តាមការណែនាំ (ពេលបើកបវេសនកាល ចុងឆមាសទី១ និងទី២) និងផ្នែក ភាគរយសិស្សដែលមករៀនយឺត និងនៅមានចំណុចប្រឈមគឺ ភាគរយសិស្សបានធ្វើកិច្ចការផ្ទះឬកិច្ចការគម្រោង គឺមិនទាន់សម្រេចបានលទ្ធផលល្អនៅឡើយ។

តារាងទី៤៖ មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក សិស្ស និងសេវាជួយសិស្ស កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | សិស្ស និងសេវាជួយសិស្ស | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស) | ៣.៥៣ | ០.៩២ | ខ្ពស់ | ១ |
| ២ | ភាគរយសិស្សប្រើបន្ទប់ពិសោធន៍ | ២.៧៣ | ១.២៨ | មធ្យម | ៤ |
| ៣ | ភាគរយសិស្សប្រើកុំព្យូទ័រ | ២.៧៣ | ១.៤៤ | មធ្យម | ៥ |
| ៤ | ភាគរយថ្នាក់មានដំណើរការ (តាមការណែនាំរបស់ក្រសួង) ក្លឹបសិស្សាសិស្ស | ២.៣៣ | ១.១១ | ទាប | ៦ |
| ៥ | ភាគរយសិស្សខ្សោយគំហើញនិងខ្សោយស្តាប់ បានទទួលការគាំទ្រដើម្បីរៀនបានប្រសើរ | ២.៨៧ | ១.៤១ | មធ្យម | ៣ |
| ៦ | ភាគរយសិស្សអាហារូបករណ៍បោះបង់ការសិក្សា | ៣.០០ | ១.៦៥ | មធ្យម | ២ |
| ៧ | ចំនួនទស្សនកិច្ចសិក្សារបស់គ្រូបង្រៀន | ១.៦៧ | ១.២៩ | ទាប | ៧ |
| សរុប | | ២.៧០ | ០.៩២ | មធ្យម | |

យោងតាមតារាងទី៤ខាងលើបង្ហាញថានៅក្នុងផ្នែក សិស្ស និងសេវាជួយសិស្ស មានកម្រិតមធ្យមចាប់ពី ៣.៥៣ រហូតដល់ ១.៦៧។ បានន័យថានៅចំណុចទី១៖ ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស) មានកម្រិតមធ្យម ៣.៥៣( M=3.53)។ជាមធ្យមកម្រិតខ្ពស់។ ចំណែកឯចំណុចទី៧៖ ចំនួនទស្សនកិច្ចសិក្សារបស់គ្រូបង្រៀនមានកម្រិតមធ្យមកម្រិតទាប ១.៩២ ( M=1.92)។

ជារួមមកនៅផ្នែកយើងឃើញនៅផ្នែក សិស្សនិងសេវាជួយសិស្ស មានចំណុចមួយចំនួន នៅតែក៏នៅមានបញ្ហាប្រឈមមួយចំនួនទៀតដូចជា ការបើកក្លឹបសិក្សា និងផ្នែកការធ្វើទស្សនកិច្ចសិក្សារបស់គ្រូដើម្បីស្វែងរកបទពិសោធ ក៏ដូចជាចំណេះដឹងថ្មីៗក្នុងបង្ហាត់បង្រៀនសិស្ស។

**តារាងទី៥៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ការដឹកនាំ និងការគ្រប់គ្រងសាលារៀន កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | ការដឹកនាំ និងការគ្រប់គ្រងសាលារៀន | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ការអនុវត្តផែនការអធិការកិច្ចរបស់នាយកឬនាយិកាឬនាយករងឬនាយិការង | ៣.៣៣ | 0.៩0 | មធ្យម | ៥ |
| ២ | ចំនួនការប្រជុំបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំ) | ៤.២0 | 0.៥៦ | ខ្ពស់ | ១ |
| ៣ | ចំនួនដងបំប៉ន និងដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក និងគណៈកម្មការគ្រង់គ្រងសាលារៀនដោយមន្ត្រីក្រសួង ដើម្បីកែលម្អសូចនាករគ្រប់គ្រងសាលារៀន | ២.៨៧ | ១.២៥ | មធ្យម | ៦ |
| ៤ | ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាង មុនតាមរយៈការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | ៣.៥៣ | 0.៧៤ | ខ្ពស់ | ៣ |
| ៥ | ការបន្ថយភាពមិនប្រក្រតីនៅសាលារៀន | ៣.៧៣ | 0.៨0 | ខ្ពស់ | ២ |
| ៦ | ចំនួនដងពិនិត្យតាមដាននិងគាំទ្រពីថ្នាក់ស្រុក មន្ទីរ និងក្រសួង | ៣.៤0 | 0.៩៩ | មធ្យម | ៤ |
| **សរុប** | | **៣.៥១** | **0.៧៤** | **ខ្ពស់** | |

យោងតាមតារាងទី៥ខាងលើបានបង្ហាញថានៅក្នុងផ្នែក ការដឹកនាំ និងការគ្រប់គ្រងសាលារៀន មានកម្រិតមធ្យមចាប់ពី៤.២0 ដល់ ២.៨៧ ។ មានន័យថានៅចំណុចទី២៖ ចំនួនការប្រជុំបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំ) មានកម្រិតមធ្យម ៤.២0 ( M=4.20) បន្ទាប់គឺចំណុចទី៖ ការបន្ថយភាពមិនប្រក្រតីនៅសាលារៀន មានកម្រិតមធ្យម៣.៧៣ (M=3.73) បន្ទាប់មកគឺចំណុចទី៤៖ ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាង មុនតាមរយៈការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ មានកម្រិតមធ្យម៣.៥៣(M=3.53) ដែលចំណុចទាំងបីនេះជាចំណុចដែលមានកម្រិតមធ្យម

កម្រិតខ្ពស់ ។ ចំណែកចំណុចទី៣៖ ចំនួនដងបំប៉ន និងដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក និងគណៈកម្មការគ្រង់គ្រងសាលារៀនដោយមន្ត្រីក្រសួង ដើម្បីកែលម្អសូចនាករគ្រប់គ្រងសាលារៀន មានកម្រិតមធ្យម ២.៨៧( M=2.87) ជាចំណុចដែលស្ថិតនៅក្នុងលំដាប់មធ្យមចុងក្រោយគេ។

ជារួមមកយើងអាចបញ្ជាក់បានថានៅផ្នែក ការដឹកនាំ និងគ្រប់គ្រងសាលារៀន មានចំណុចល្អមួយចំនួនហើយ តែអ្វីដែលជាចំណុចខ្វះខាតគឺការពិនិត្យតាមដានពីថ្នាក់ស្រុក មន្ទីរ ក្រសួង នៅមានកម្រិតទាបនៅឡើយ។

**តារាងទី៦៖** មធ្យម គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ធនធានមនុស្ស កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | ធនធានមនុស្ស | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន | ៣.៦០ | ១.១២ | ខ្ពស់ | ១ |
| ២ | ចំនួនខ្វះគ្រូមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ( ប្រវត្តិវិទ្យា) ចុះថយធៀបជាមួយបទដ្ឋាន | ២.៧៣ | ១.០៣ | មធ្យម | ៣ |
| ៣ | គុណវុឌ្ឍិនាយក ឬនាយិកាសាលារៀនធៀបជាមួយផែនការក្រសួង | ៣.៤៧ | ០.៧៤ | មធ្យម | ២ |
| សរុប | | ១.៦៣ | ០.៣៦ | ទាប | |

យោងតាមតារាងទី៦ខាងលើបានបង្ហាញថានៅក្នុងផ្នែក ធនធានមនុស្ស មានកម្រិតមធ្យមចាប់ពី ៣.៦០ ដល់ ២.៧៣ ។ មានន័យថានៅចំណុចទី១៖ គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន មានកម្រិតមធ្យម៣.៦០ ( M=3.60) បន្ទាប់គឺចំណុចទី៣៖ គុណវុឌ្ឍិនាយក ឬនាយិកាសាលារៀនធៀបជាមួយផែនការក្រសួងមានកម្រិតមធ្យម៣.៤៧ (M=3.47) ដែលចំណុចទាំងពីរនេះជាចំណុចដែលមានកម្រិតមធ្យមកម្រិតខ្ពស់ ។ ចំណែកចំណុចទី២៖ មានកម្រិតមធ្យម២.៧៣( M=2.73) ជាចំណុចដែលស្ថិតនៅក្នុងលំដាប់មធ្យមចុងក្រោយគេ។

ជារួមមកយើងអាចបញ្ជាក់បានថានៅផ្នែក ការដឹកនាំ និងគ្រប់គ្រងសាលារៀន មានចំណុចល្អមួយចំនួនហើយ តែអ្វីដែលជាចំណុចខ្វះខាតគឺការពិនិត្យតាមដានពីថ្នាក់ស្រុក មន្ទីរ ក្រសួង នៅមានកម្រិតទាបនៅឡើយ។

**តារាងទី៧៖** មធ្យម  គម្លាតស្តង់ដាអត្ថន័យ និង លំដាប់កម្រិតនៃផ្នែក សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ភាគរយសិស្សមានសៀវភៅសិក្សាគោលតាមមុខវិជ្ជា | ៣.៦០ | ០.៨៣ | ខ្ពស់ | ១ |
| ២ | ចំនួនគ្រូមុខវិជ្ជាគោលបានបំប៉នពីការប្រើប្រាស់សៀវភៅលំហាត់ | ២.៩៣ | ១.១០ | មធ្យម | ៣ |
| ៣ | បណ្ណាល័យបានបង្កើត និងមានស្តង់ដា | ២.៦៧ | ១.៣៥ | មធ្យម | ៤ |
| ៤ | ការបង្កើតសម្ភារៈឧបទ្ទេសសម្រាប់ដំណើរការបង្រៀន និងរៀន | ៣.០០ | ០.៧៦ | មធ្យម | ២ |
| **សរុប** | | **៣.០៧** | **០.៨៧** | **មធ្យម** | |

យោងតាមតារាងទី៧ខាងលើបានបង្ហាញថានៅក្នុងផ្នែក សៀវភៅសិក្សាគោលនិង សម្ភារៈរៀននិងបង្រៀន មានកម្រិតមធ្យមចាប់ពី៣.៦០ ដល់ ២.៦៧។ មានន័យថាចំណុចទី១៖ភាគរយសិស្សមានសៀវភៅសិក្សាគោលតាមមុខវិជ្ជា មានកម្រិតមធ្យម ៣.៦០ (M=3.60) ជាចំណុចដែលមានកម្រិតមធ្យមខ្ពស់ និចំណុចទី៣៖ បណ្ណាល័យបានបង្កើត និងមានស្តង់ដាជាចណុចដែលមានកម្រិតមធ្យមកម្រិតទាបនៅក្នុងផ្នែកនេះ។

ជារួមមកតាមតារាងខាងលើបង្ហាញថានៅផ្នែកសៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀនក៏ជាផ្នែកមួយដែលបានជួយដល់ការលើកកម្ពស់ការរៀននិងបង្រៀន តែចំណុចប្រឈមនៅក្នុងផ្នែកនេះគឺបណ្ណាល័យមានការរៀបចំមិនត្រូវតាមស្តង់ដានៅឡើយ។

តារាងទី៨៖ មធ្យម  គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | កង្វះបន្ទប់រៀនថយចុះរហូតមានសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន | ៣.០៧ | ១.២២ | មធ្យម | ២ |

| | | | | | |
|---|---|---|---|---|---|
| ២ | បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាងសង់តាមតម្រូវការ | ២.៤៧ | ១.៨៨ | មធ្យម | ៤ |
| ៣ | បន្ទប់រដ្ឋបាលសាលារៀន និងសង្ហារឹមបានផ្តល់តាមតម្រូវការ | ២.៨៧ | ១.៣៦ | មធ្យម | ៣ |
| ៤ | បន្ទប់ទឹកបានសាងសង់តាមស្តង់ និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្សទាំងប្រុសទាំងស្រី | ៣.៣៣ | ០.៩៨ | មធ្យម | ១ |
| សរុប | | ២.៩៣ | ១.០៦ | មធ្យម | |

យោងតាមតារាងទី៨ខាងលើបានបង្ហាញថានៅក្នុងហេដ្ឋារចនាសម្ព័ន្ធ និង បរិស្ថានសាលារៀន មានកម្រិតមធ្យមចាប់ពី៣.៣៣ ដល់ ២.៤៧។ មានន័យថាចំណុចទី៤៖ បន្ទប់ទឹកបានសាងសង់តាមស្តង់ដារ និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្សទាំងប្រុស ទាំងស្រី មានកម្រិតមធ្យម៣.៣៣ ( M=33) បន្ទាប់គឺចំណុច ទី១៖ កង្វះបន្ទប់រៀនថយចុះរហូតមានសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន មានកម្រិតមធ្យម ៣.០៧ (M=3.07) ដែលជាចំណុចមធ្យមដែលមានកម្រិតលំដាប់ទី១ និងទី២ ។ ចំណែកចំណុចទី២៖ បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាងសង់តាមស្តង់ដា២.៤៧ (M=2.47) ជាចំណុចដែលមានមធ្យមលំដាប់ចុងក្រោយគេ។

ជារួមមកនៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ បរិស្ថានសាលារៀនគឺមិនមានមធ្យមកម្រិតខ្ពស់នោះទេ គឺនៅមានបញ្ហាប្រឈមជាច្រើនចាប់តាំងពីបន្ទប់រៀន បន្ទប់រដ្ឋបាលសិក្សា បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនជាដើម។

**តារាងទី៩៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃផ្នែក ហរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ កម្រិតមធ្យមសិក្សាទុតិយភូមិ (N= ១៥)។

| ល.រ | ខ្លឹមសារ | ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | ថវិកាសាលារៀនបានពីប្រភពផ្សេងៗបានទទួលដាក់ស្តែងតាមត្រីមាសមានប្រភពល្អប្រសើរឡើង | ៣.៥៣ | ១.១៣ | ខ្ពស់ | ៣ |

| | | | | | |
|---|---|---|---|---|---|
| ២ | ការចាត់ចែង ការប្រើប្រាស់តម្លាភាព ថវិកាសាលារៀនបានប្រសើរ | ៤.២០ | ០.៥៦ | ខ្ពស់ | ២ |
| ៣ | ការរាយការណ៍ការចំណាយតាមខ្ទង់ចំណាយ ធំៗ( រដ្ឋបាល ការបង្រៀន និងរៀន បរិស្ថាន) បានប្រសើរដោយផ្តោតការចំណាយលើការបង្រៀន និងរៀន | ៤.៣៣ | ០.៤៩ | ខ្ពស់ | ១ |
| **សរុប** | | **៣.០២** | **០.៥០** | **ខ្ពស់** | |

យោងតាមតារាងខាងលើបង្ហាញថាក្នុងផ្នែកហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ មានមធ្យមចាប់ពី ៤.៣៣ រហូតដល់៣.៥៣ ។ មានន័យថាចំណុចទី៣៖ថវិកាសាលារៀនបានពីប្រភពផ្សេងៗ បានទទួលដាក់ស្តែងតាមត្រីមាសមានប្រភពល្អប្រសើរឡើងមានកម្រិតមធ្យម៤.៣៣ (M=4.33) និងចំណុចទី២៖ការចាត់ចែង ការប្រើប្រាស់តម្លាភាពថវិកាសាលារៀនបានប្រសើរមានមធ្យម៤.២០ (M=4.20) និងចំណុចទី១៖ ថវិកាសាលារៀនបានពីប្រភពផ្សេងៗ បានទទួលដាក់ស្តែងតាមត្រីមាសមានប្រភពល្អប្រសើរឡើងមានមធ្យម៣.៥៣(M=3.53) ជាលំដាប់ខ្ពស់ចុងក្រោយនៅក្នុងផ្នែកហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ។

ជារួមមកយើងអាចបញ្ជាក់បានថានៅក្នុងផ្នែកនេះគឺមធ្យមមានកម្រិតខ្ពស់ទាំងអស់ដូចនេះហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ មិនមានបញ្ហាដែលត្រូវមានបញ្ហាប្រឈមនោះទេ។

**តារាងទី១០**៖បង្ហាញពីតម្លៃ មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតតាមផ្នែកនីមួយៗរបស់គណៈនាយកលើការគ្រប់គ្រងការបង្រៀន និងរៀន (N= ១៥)។

| លរ | ខ្លឹមសារ | ការវិភាគសរុបទិន្នន័យនាយក | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | រដ្ឋបាលសាលារៀន | ៤.១៧ | ០.៥៨ | ខ្ពស់ | ១ |
| ២ | ការគ្រប់គ្រងការបង្រៀន និងរៀន | ៣.៨៥ | ០.៤៦ | ខ្ពស់ | ៣ |

| | | | | | |
|---|---|---|---|---|---|
| ៣ | មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស | ៣.២៨ | ០.៦០ | មធ្យម | ៥ |
| ៤ | សិស្ស និងសេវាជួយសិស្ស | ២.៧០ | ០.៩២ | មធ្យម | ៩ |
| ៥ | ការដឹកនាំ និងការគ្រប់គ្រងសាលារៀន | ៣.៥១ | ០.៧៤ | ខ្ពស់ | ៤ |
| ៦ | ធនធានមនុស្ស | ៣.២៧ | ០.៧៣ | មធ្យម | ៦ |
| ៧ | សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន | ៣.០៧ | ០.៨៧ | មធ្យម | ៧ |
| ៨ | ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន | ២.៩៣ | ១.០៦ | មធ្យម | ៨ |
| ៩ | ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ | ៤.០២ | ០.៦៦ | ខ្ពស់ | ២ |

យោងតាមតារាងខាងលើយើងឃើញថាទស្សនៈ របស់គណៈនាយកលើវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនគឺមានកម្រិតមធ្យមចាប ពី៤.១៧ដល់២.៧០។ មានន័យថា ចំណុចរដ្ឋបាលសាលារៀនគឺមានមធ្យម៤.១៧(M=4.17) ជាមធ្យមកម្រិតខ្ពស់។ ចំណុចទី៩៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុមានមធ្យមកម្រិតខ្ពស់បន្ទាប់៤.០២ (M=៤.០២) ។ ចំណុចទី២៖ ការគ្រប់គ្រងការបង្រៀន និងរៀនមានមធ្យមកម្រិតខ្ពស់បន្ទាប់ទៀត៣.៨៥(M=3.85)។ ចំណែកឯចំណុចដែលមានកម្រិតមធ្យមទាបជាងគេបំផុតគឺចំណុចទី៤៖សិស្ស និងសេវាជួយសិស្សដែលមានកម្រិតមធ្យម២.៧០។ ចំណុចដែលមានកម្រិតមធ្យមទាបបន្ទាប់គឺចំណុចទី៨៖ហេដ្ឋារចនាសម្ព័ន្ធសាលារៀនដែលមានកម្រិតមធ្យម២.៩៣(M=2.93) និងចំណុចទី៧៖ សៀវភៅសិក្សាគោល និង សម្ភារៈរៀន និងបង្រៀន។

ជារួមមកយើងឃើញថាចំណុចដែលមានមធ្យមកម្រិតខ្ពស់ចំពោះការយល់ឃើញរបស់គណៈនាយកលើការអនុវត្តការគ្រប់គ្រងការបង្រៀន និងរៀនគឺចំណុច (១)ការគ្រប់គ្រងរដ្ឋបាលសាលារៀន (២)ការគ្រប់គ្រងការដឹកនាំការបង្រៀន និងរៀន (៣) ផ្នែកហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ ។ ចំណែកឯចំណុចដែលមានមធ្យមកម្រិតទាបគឺ(១) ផ្នែកសិស្ស និងសេវាជួយសិស្ស (២) ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀននិងទី(៣)គឺសៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន។

**ឃ .តារាងបង្ហាញពី៖** តម្លៃមធ្យម គម្លាតស្តង់ដា លំដាប់តាមផ្នែកនីមួយៗរបស់គណៈកម្មការគ្រប់គ្រងសាលារៀនលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន(N=05)

| លរ | ខ្លឹមសារ | ទស្សនៈគណៈគ្រប់គ្រងសាលារៀន | | កម្រិត | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តងដា | | |

| | | | | | |
|---|---|---|---|---|---|
| ១ | រដ្ឋបាលសាលារៀន | ៤.១៣ | ០.៤៩ | ខ្ពស់ | ១ |
| ២ | ការគ្រប់គ្រងការបង្រៀន និងរៀន | ៣.៤០ | ០.៣៧ | មធ្យម | ៦ |
| ៣ | មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស | ៣.៦៥ | ០.២៩ | ខ្ពស់ | ៣ |
| ៤ | សិស្ស និងសេវាជួយសិស្ស | ២.៤៣ | ០.៣៦ | មធ្យម | ៩ |
| ៥ | ការដឹកនាំ និងការគ្រប់គ្រងសាលារៀន | ៣.៥៧ | ០.២៨ | ខ្ពស់ | ៤ |
| ៦ | ធនធានមនុស្ស | ៣.៥៣ | ០.៣៨ | ខ្ពស់ | ៥ |
| ៧ | សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន | ២.៦៥ | ០.៤២ | មធ្យម | ៨ |
| ៨ | ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន | ៣.២០ | ០.៥៧ | មធ្យម | ៧ |
| ៩ | ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ | ៣.៨៣ | ០.៣៣ | ខ្ពស់ | ២ |

យោងតាមតារាងខាងលើបង្ហាញថាទស្សនៈរបស់គណៈគ្រប់គ្រងទៅលើវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនមានកម្រិតមធ្យមសរុបចាប់ពី៤.១៣ រហូតដល់២.៤២ ។ មានន័យថានៅចំណុចទី១៖ រដ្ឋបាលសាលារៀនមានកម្រិតមធ្យមខ្ពស់៤.១៣ ។ចំណុចទី៩៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុមានមធ្យមកម្រិតខ្ពស់ដែរគឺ៣.៨៣ (M=3.83) និងចំណុចទី៣៖ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្សមានមធ្យមកម្រិតខ្ពស់បន្ទាប់គឺ៣.៦៥(M=3.65) បន្តមកទៀតគឺចំណុចទី៥៖ ការដឹកនាំ និងការគ្រប់គ្រងសាលារៀនដែលមានមធ្យម៣.៥៧( M=3.57) ។ រីឯចំណុចដែលមានកម្រិតមធ្យមកម្រិតទាបជាងគេចំណុចទី៤៖ សិស្ស និងសេវាជួយសិស្ស ដែលមានមធ្យម២.៤៣( M=2.43) ចំណុចដែលមានមធ្យមទាបបន្ទាប់មកទៀតគឺចំណុចទី៧៖ សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀនដែលមានមធ្យម ២.៦៥ ( M=2.65) និងចំណុចទាបបន្ទាប់មកទៀតគឺចំណុចទី៨៖ ហេដ្ឋារចនាសម្ព័ន្ធសាលារៀនដែលមានមធ្យម៣.២០ ( M=3.20)។

ជារួមមកបង្ហាញទស្សនៈរបស់គណៈកម្មការគ្រប់គ្រងសាលារៀន ក៏មិនខុសពីទស្សនៈរបស់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងគណៈនាយកដែរគឺយល់ឃើញថាការអនុវត្តការគ្រប់គ្រងសាលារៀនបានល្អទៅលើផ្នែករដ្ឋបាលសាលារៀន ការបង្រៀន និងរៀន ការដឹកនាំ និងការគ្រប់គ្រងសាលារៀន ។ ចំណែកឯចំណុចនៅមានបញ្ហាប្រឈមខ្លាំងនៅផ្នែកសិស្ស និងសេវាជួយសិស្ស ផ្នែកហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងផ្នែកសៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន។

## ៤.២. ស្ថានភាពជាក់ស្តែង តាមរយៈការបញ្ចេញគំនិត

ជាសំណួរដែលបានសួរទៅលើភាគសំណាកទាំងបួនគឺ គណៈនាយក គណៈកម្មការគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដើម្បីរកឱ្យឃើញពីបញ្ហាប្រឈមនានានៅក្នុងដំណើរការការអនុវត្តការគ្រប់គ្រងតាមសាលារៀន។

| ការបញ្ចេញមតិរបស់លោកនាយក នាយករងការធ្វើវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន | |
|---|---|
| ១ | មន្ត្រីអប់រំទាំងអស់ត្រូវមានមនសិការវិជ្ជាជីវៈ |
| ២ | គ្រូបង្រៀនត្រូវខិតខំស្រាវជ្រាវចំណេះដឹងថ្មីៗ ចំណេះខាងព័ត៌មានវិទ្យា |
| ៣ | ត្រូវមានវិធានការម៉ឺងម៉ាត់ចំពោះបុគ្គលិកអសកម្មក្នុងការងារ |
| ៤ | ការដឹកនាំគ្រប់គ្រប់ត្រូវមានអភិបាលកិច្ចល្អ |
| ៥ | ការចុះធ្វើអធិការកិច្ចតាមជំនាញឱ្យបានញឹកញាប់ |
| ៦ | គ្រូបង្រៀនត្រូវមានកិច្ចតែងការបង្រៀន |
| ៧ | មានបើកវគ្គបំប៉នសមត្ថភាពគ្រូ តាមឯកទេសនីមួយៗ និងជំនាញក្នុងការពិសោធន៍តាមមុខវិជ្ជាវិទ្យាសាស្ត្រ |
| ៨ | គ្រូបង្រៀនត្រូវយល់ដឹងពីគោលនយោបាយកំណែទម្រង់ការអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| ៩ | ការរិតបន្តឹងលើការងារប្រឡង |
| ១០ | ទំនាក់ទំនងជាមួយសហគមន៍ |
| ១១ | ការបែងចែកបុគ្គលិកបង្រៀនឱ្យត្រូវតាមឯកទេស(ការគ្រប់គ្រងបុគ្គលិក) |
| ១២ | ការពិនិត្យតាមដានអវត្តមានបុគ្គិលិកជាប្រចាំ |
| ១៣ | កត្តាគ្រូបង្រៀនដែលខ្វះមនសិការវិជ្ជាជីវៈ |
| ១៤ | ការលើកទឹកចិត្តគ្រូបង្រៀន |
| ១៥ | ត្រូវមានបន្ទប់ពិសោធន៍ និងបណ្ណាល័យឱ្យបានសមស្រប |
| ១៦ | បណ្ណាល័យប្រកបដោយស្តង់ដា និងមានបណ្ណារក្សដែលមានជំនាញក្នុងការរៀបចំឯកសារ |

| យោបល់ និងសំណូមពររបស់លោកគ្រូ អ្នកគ្រូក្នុងការចូលរួមការអនុវត្តការគ្រប់គ្រងតាមសាលារៀន | |
|---|---|
| ១ | ក្រសួងត្រូវផ្តល់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់សម្រាប់សិស្សានុសិស្សប្រើប្រាស់ និងបង្កើតសម្ភារៈឧបទេសឱ្យបានគ្រប់គ្រាន់ក្នុងការបង្រៀននិងរៀន |

| | |
|---|---|
| ២ | រៀបចំឱ្យមានដំណើរទស្សនកិច្ចសិក្សា និងបើកវគ្គបំប៉នសមត្ថភាពគ្រូ( វិធីសាស្ត្របង្រៀនថ្មីៗ) |
| ៣ | គុណវុឌ្ឍិគ្រូបង្រៀន |
| ៤ | ដាក់កិច្ចការផ្ទះ និងពិនិត្យតាមដានលទ្ធផល |
| ៥ | លើកទឹកចិត្តសិស្សពូកែ ការលើកទឹកចិត្តគ្រូបង្រៀនដែលមានស្នាដៃ |
| ៦ | គ្រូត្រូវខិតខំសិក្សាស្រាវជ្រាវពង្រឹងចំណេះដឹងបន្ថែម |
| ៧ | រកវិធីសាស្ត្របង្រៀនថ្មីៗ ត្រូវចេះផ្លាស់ប្តូរវិធីសាស្ត្របង្រៀនជាប្រចាំ |
| ៨ | ការពង្រឹងសមត្ថភាពគ្រូ នាយកតាមរយៈការធ្វើសិក្ខាសាលា |
| ៩ | គ្រូបង្រៀនត្រូវយល់ដឹងពីគោលនយោបាយកំណែទម្រង់ការអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| ១០ | គ្រូបង្រៀនត្រូវមានសៀវភៅរដ្ឋបាល និងកិច្ចតែងការបង្រៀន |
| ១១ | ការចូលរួមពីសហគមន៍ អាជ្ញាធរដែន ការបំបាត់ការជួញដូរគ្រឿងញៀន |
| ១២ | ការចូលរួមពីសិស្សានុសិស្ស ក្នុងការខិតខំរៀនសូត្រ ជៀសឆ្ងាយពីការសេពគ្រឿងញៀន |
| ១៣ | ថ្នាក់រៀនត្រូវមានស្តង់ដា |
| ១៤ | ការគិតគូរពីប្រាក់បៀវត្សរបស់លោកគ្រូ អ្នកគ្រូឱ្យបានសមរម្យ |
| ១៥ | ការគោរពពេលវេលារបស់លោកគ្រូ អ្នកគ្រូ និងការពិនិត្យតាមដាន វត្តមានគ្រូជាប្រចាំ |
| ១៦ | ការផ្តល់ថវិកាគ្រប់គ្រាន់ក្នុងការបង្កើតសម្ភារៈឧបទេស និងសម្ភារៈផ្សេងទៀតក្នុងដំណើរការបង្រៀន និងរៀន |
| ១៧ | ការបែងចែកបុគ្គលិកបង្រៀនឱ្យត្រូវតាមឯកទេស( ការគ្រប់គ្រងបុគ្គលិក )ប្រកបដោយតម្លាភាព ដោយគ្មានប្រកាន់បក្សពួក |
| ១៨ | ផ្តល់ថវិកាសម្រាប់បំប៉នដល់សិស្សខ្សោយ |
| ១៩ | បន្ទប់រៀនត្រូវមានគ្រប់គ្រាន់ដើម្បីរៀបចំសិស្សឱ្យត្រូវតាមស្តង់ដា |
| ២០ | លុបបំបាត់ថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់សង្គម |
| ២១ | ផ្តល់ថវិកាបន្ថែមសម្រាប់គ្រូដើម្បីកុំឱ្យគ្រូបង្រៀនមានមុខរបរទី២ |
| ២២ | ការធ្វើតេស្តសមត្ថភាពគ្រូរៀងរាល់ឆ្នាំ |
| ២៣ | ពង្រាយគ្រូតាមសាលាឱ្យបានសមស្រប |
| ២៤ | ការប្រើប្រាស់ថវិកាឱ្យបានត្រឹមត្រូវ និងមានតម្លាភាព |
| ២៥ | បើកវគ្គបំប៉នសមត្ថភាពគ្រូតាមមុខវិជ្ជាទូទៅ និង ជាពិសេសមុខវិជ្ជាត្រូវ ពិសោធន៍ និងមុខវិជ្ជាភាសាអង់គ្លេស |
| ២៦ | ការគោរពពេលវេលារបស់លោកគ្រូ អ្នកគ្រូ |
| ២៧ | ការធ្វើអធិការកិច្ចផ្ទៃក្នុង (អធិការកិច្ចអចិន្ត្រៃ) ការចុះពិនិត្យតាមដានពីថ្នាក់ ស្រុក មន្ទីរ និងថ្នាក់ក្រសួង |
| ២៨ | គ្រូបង្រៀនត្រូវមានចំណេះដឹង ភាសាបរទេស និងផ្នែកព័ត៌មានវិជ្ជា( ICT) |

យោបល់ និងសំណូមពររបស់សិស្សានុសិស្សក្នុងចូលរួមវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលា

| | |
|---|---|
| រៀន | |
| ១ | សូមឱ្យគ្រូបង្កើតក្លឹបសិក្សាឱ្យបានគ្រប់កម្រិត និងឱ្យបានច្រើនមុខវិជ្ជា |
| ២ | សូមឱ្យគ្រូមកបង្រៀនឱ្យបានទៀងទាត់ និងគោរពពេលវេលាបង្រៀន |
| ៣ | ទំនាក់ទំនងជាមួយសហគមន៍ |
| ៤ | វិធីសាស្ត្រក្នុងការរៀនឱ្យបានច្បាស់លាស់ សូមឱ្យគ្រូមានភាពច្បាស់លាសក្នុងការបង្ហាត់បង្រៀនមុខវិជ្ជានីមួយៗ |
| ៥ | ដាក់ពិន័យសិស្សដែលមិនធ្វើកិច្ចការផ្ទះ |
| ៦ | វិន័យសាលាត្រូវកំណត់ឱ្យបានច្បាស់លាស់ និងតឹងរ៉ឹងបំផុត |
| ៧ | សូមឱ្យសាលាមានបន្ទប់ពិសោធន៍ និងបន្ទប់សម្រាប់រៀនកុំព្យូទ័រ និងសូមបន្ថែមម៉ោងមុខវិជ្ជាទាំងនេះ |
| ៨ | សុំឱ្យមានកន្លែងហាត់កីឡា( តារាងបាល់ទះ) |
| ៩ | សូមមានឱ្យមានបន្ទប់ទឹកគ្រប់គ្រាន់ សម្រាប់តម្រូវការរបស់សិស្សានុសិស្ស |
| ១០ | សូមឱ្យមានការទាក់ទងទៅអាណាព្យាបាលសិស្ស(មានទំនាក់ទំនងល្អរវាងគ្រូ បង្រៀន និងអាណាព្យាបាលសិស្ស |
| ១១ | សូមឱ្យមានបណ្ណាល័យដែលឯកសារគ្រប់គ្រាន់សម្រាប់ស្រាវជ្រាវ ទាំងគ្រូ ទាំងសិស្ស |
| ១២ | បញ្ហាបរិស្ថាននៅមិនទាន់បានស្អាត អនាម័យ បន្ទប់ទឹក សំរាមជាដើម |
| ១៣ | ការមិនគោរពពេលវេលា បង្រៀន និងការផ្លាស់ប្តូរកាលវិភាគបង្រៀនឱ្យបានត្រឹមត្រូវតាមកាលវិភាគ |
| ១៤ | សូមឱ្យគ្រូបង្រៀនដោយយកចិត្តទុកដាក់ |
| ១៥ | ពង្រឹងសមត្ថភាពរបស់លោកគ្រូ អ្នកគ្រូ ព្រោះមុខវិជ្ជាខ្លះទៅបង្រៀនសិស្សមិនយល់ព្រោះគ្រូមិនច្បាស់ |
| ១៦ | ចង់ឱ្យមានការចុះត្រួត ពិនិត្យការបង្រៀន និងរៀនរបស់លោកគ្រូ អ្នកគ្រូ |
| ១៧ | ចង់បានគ្រូដែលមានគុណភាព |
| ១៨ | សូមឱ្យលោកគ្រូប្រកាន់ភាពយុត្តិធម៌ និងមនសិការវិជ្ជាជីវៈខ្ពស់ |
| ១៩ | រឹតបន្តឹងការធ្វើតេស្តសមត្ថភាពប្រចាំខែ ដូចការប្រឡងផ្សេងៗ |
| ២០ | ការពិនិត្យតាមដានអវត្តមានសិស្សជាប្រចាំ |

| | |
|---|---|
| យោបល់ និងសំណូមពររបស់គណៈគ្រប់គ្រងសាលារៀនក្នុងការចូលរួមវាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន | |
| ១ | សូមគ្រូជួយបំពេញតួនាទី មនសិការវិជ្ជាជីវឱ្យបានត្រឹមត្រូវ |
| ២ | សុំបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ |
| ៣ | សូមឱ្យគ្រូជួយតាមដានពីការសិក្សារបស់សិស្សឱ្យបានច្បាស់លាស់ |
| ៤ | ទំនាក់ទំនងជាមួយសហគមន៍ មាតាបិតាសិស្ស |
| ៥ | សូមក្រសួង មន្ទីរជួយផ្តល់គ្រូឱ្យបានគ្រប់គ្រាន់ និងតាមកម្រិតជំនាញ |

| | |
|---|---|
| ៦ | សូមឱ្យគ្រូសិស្សមានការគោរពពេលវេលា គោរពវិន័យរបស់សាលា |
| ៧ | សូមឱ្យមានសម្ភារៈសិក្សាគ្រប់គ្រាន់ |
| ៨ | គ្រូត្រូវចេះជំនាញព័ត៌មានវិទ្យា ( ICT) |
| ៩ | ចង់ឱ្យគ្រូពង្រឹងសមត្ថភាពក្នុងការបង្រៀនដើម្បីឱ្យសិស្សជាប់និទ្ទេសAឱ្យបានច្រើន |

## ៤.៣. បញ្ហាប្រឈម

តាមរយៈការវិភាគទៅសំណួរបំពេញ និងសំណួរបែបគុណវិស័យ រួចមក អ្នកសិក្សាស្រាវជ្រាវបានរកឃើញពីបញ្ហាប្រឈមមួយចំនួនក្នុងដំណើរ ការបង្រៀនមានដូចជា៖

- ផ្នែកការបង្រៀន និងរៀន ៖(១) ភាពខ្វះមនសិការវិជ្ជាពីគ្រូបង្រៀនមួយចំនួន សមត្ថភាពចំណេះដឹងគ្រូបង្រៀននៅមានកម្រិត គ្រូមិនសូវបានពង្រឹងចំណេះដឹងរបស់ខ្លួន (២) ការពង្រាយគ្រូ មិនស្មើគ្នា និងមិនសមស្របតាមតម្រូវការ( ការផ្តល់គ្រូមិនត្រូវតាមឯកទេសដែលត្រូវការ) ។
- ផ្នែកមាតាបិតានិងសហគមន៍ជួយសិស្ស៖ ការសហការ រវាងមាតាបិតា និងសហគមន៍ ជាមួយគ្រូបង្រៀនគឺមិនសូវមានទំនាក់គ្នាល្អ។
- ផ្នែកសៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន ៖ នៅមានការខ្វះខាតសៀវភៅសិក្សាគោល បណ្ណាល័យមិនទាន់រៀបតាមស្តង់ដា ។
- ផ្នែកសិស្ស និងសេវាជួយសិស្ស ៖ (១)នៅខ្វះខាតបន្ទប់ពិសោធន៍ (២)បន្ទប់សម្រាប់រៀនកុំព្យូទ័រ (៣) ការបង្កើតក្លឹបសិក្សាពុំទាន់បានគ្រប់កម្រិត (៤)បន្ទប់រៀនពុំទាន់មានស្តង់ដា ខ្វះថវិកាក្នុងការបង្កើតសម្ភារៈឧបទេស។
- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន៖បន្ទប់ទឹកពុំទាន់មាន លក្ខណៈ ស្តង់ដា  នៅមិនទាន់មានបន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនស្របតាមតម្រូវការនៅឡើយ។

# ជំពូកទី ៥
# សន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥៖ សន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសង្ខេបលទ្ធផលស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះក្នុងគោលបំណងចង់ស្វែងយល់ពីវង្វាយតម្លៃ ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្ត ស្វាយរៀង ។ នៅក្នុងនេះផងដែរអ្នកស្រាវជ្រាវ បានជ្រើសរើសភាគសំណាកជាសិស្សចំនួនសរុប ១៩៤ នាក់ គ្រូចំនួន ១១៤នាក់ នាយក នាយករងចំនួន ១៥ នាក់ និងគណៈកម្មការគ្រប់គ្រងសាលារៀនចំនួន ០៥នាក់ ដែលបានមកពីវិទ្យាល័យចំនួន០៥ គឺវិទ្យាល័យ ហ៊ុន សែន ប្រសូតិ វិទ្យាល័យ ស្វាយរំពារ វិទ្យាល័យហ៊ុន សែន ក្រោលគោ វិទ្យាល័យ កំពង់ពោធិ៍ និង វិទ្យាល័យ មិត្តភាព កម្ពុជា វៀតណាម ដែលវិទ្យាល័យទាំង០៥ស្ថិតនៅក្នុងស្រុក ស្វាយទាប (វិទ្យាល័យ ហ៊ុន សែន ប្រសូតិ និងវិទ្យាល័យ ហ៊ុន សែន ស្វាយរំពារ) ស្រុក ស្វាយជ្រំ ( វិទ្យាល័យ ហ៊ុន សែនក្រោល) ស្រុកំពង់រោទិ៍ ( យកសាលាពីរគឺ វិទ្យាល័យ ហ៊ុន សែនកំពង់រោទិ៍ និងវិទ្យាល័យ មិត្តភាពកម្ពុជា វៀតណាម) ឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាបានប្រើកម្រងសំណួរជ្រើសរើសដែលមានចំនួន ៤៦ ចំណុច បែងចែកជា៩ សម្រាប់សួរទៅលើគណៈនាយក និងលោកគ្រូ អ្នកគ្រូ ផ្នែកទី១៖ ផ្នែកទី១ការគ្រប់គ្រងរដ្ឋបាលសិក្សា (មាន ៦ ចំណុច ចាប់ពី ១ ដល់ ៦)ផ្នែកទី២៖ បច្ចេកទេស ការបង្រៀន និងរៀន(មាន ០៩ ចំណុច ចាប់ពី ១ ដល់ ៩) ផ្នែកទី៣៖ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស (មាន ៤ចំណុច ចាប់ពី ១ ដល់ ៤) ផ្នែកទី៤៖ សិស្ស និងសេវាជួយសិស្ស (មាន៤ ចំណុច ចាប់ពី ១ ដល់ ៤) ផ្នែកទី៥៖ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន(មាន៦ ចំណុច ចាប់ពី១ដល់ ៦) ផ្នែកទី៦៖ ធនធានមនុស្ស (មាន៣ចំណុច ចាប់ពី ១ដល់៣) ផ្នែកទី៧៖ សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន( មាន៦ចំណុច ចាប់ពី១ដល់ ៦) ផ្នែកទី៨៖ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន (មាន៤ ចំណុច ចាប់ពី១ដល់ ៤) និងផ្នែកទី៩៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ ។ ចំពោះផ្នែកសំណួរសួរទៅលើសិស្សមាន២៤សំណួរចែកចេញជា ៤ផ្នែកគឺផ្នែកទី១៖ ការគ្រប់គ្រង និងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ (មាន៦ ចំណុច ចាប់ពី១ដល់៦) ផ្នែកទី២៖ ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ(មាន៩ចំណុច ចាប់ពី ១ដល់៩) ផ្នែកទី៣៖ មាតាបិតា និង សហគមន៍ជួយការសិក្សាសិស្ស (មាន៥ចំណុច) និងផ្នែកទី៤៖ សិស្ស និងសេវាជួយសិស្ស( មាន៤ចំណុច ចាប់ពីចំណុច១ដល់៤) ។ រីឯសំណួរសម្រាប់បំពេញចម្លើយ និងសម្ភាសន៍គឺមានតែមួយសំណួរទេសម្រាប់សួរទៅលើលោកគ្រូ អ្នកគ្រូ គណៈនាយក សិស្សានុសិស្ស និងគណៈគ្រប់គ្រងសាលារៀន (១) សួរនាយកសាលា៖ ដើម្បីរួមចំណែកក្នុងការអនុវត្តការគ្រប់គ្រងសាលារៀនឱ្យបានល្អ តើលោកនាយក នាយករង មានយោបល់ និងសំណូមពរយ៉ាងណាខ្លះ? (២)សួរលោកគ្រូ អ្នកគ្រូ៖ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀនបានល្អ តើលោកគ្រូ អ្នកគ្រូ មានយោបល់ និងសំណូមពរយ៉ាងណាខ្លះ? (៣) សំណួរសម្រាប់សួរសិស្សានុសិស្ស៖ ដើម្បីរួមចំណែកក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀនបានល្អ តើប្អូនសិស្សានុសិស្ស មានយោបល់ និងសំណូមពរយ៉ាងណាខ្លះ? សំណួរសម្រាប់ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើសំណួរបែបបរិមាណវិស័យ និងបែបគុណវិស័យ។ ចំពោះសំណួរបែបបរិមាណវិស័យ អ្នកស្រាវជ្រាវបាន ប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ និងកត់ត្រាចម្លើយរបស់សំណួរគុណវិស័យ របស់គណៈនាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងគណៈគ្រប់គ្រងសាលារៀន ដោយរើសយកចម្លើយណាដែលដូចគ្នា ឬស្រដៀងគ្នាដាក់បញ្ចូលគ្នា ដើម្បីរកឱ្យឃើញពីចំណុចប្រឈម

ទាំងឡាយទាក់ទងទៅនឹងការអនុវត្តការគ្រប់គ្រងតាមសាលារៀន ។ បន្ទាប់មកទៀតអ្នកសិក្សាស្រាវជ្រាវសំយោគបញ្ចូលគ្នា នូវសំណាកនីមួយៗ ( លោកនាយក នាយករង នាយិកា នាយិការង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងគណៈគ្រប់គ្រងសាលារៀន ) ។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធី SPSS សម្រាប់ស្វែងរកចំនួនហ្វ្រេកង់គិតជាភាគរយ និង Microsoft Excel តារាង និងបកស្រាយព័ត៌មានទិន្នន័យដែលទទួលបាន។

## ៥.២សេចក្តីសន្និដ្ឋាន

ការសិក្សាពីរង្វាយតម្លៃការអនុវត្តការគ្រប់គ្រង តាមសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀងបានបង្ហាញលទ្ធផលជារួម ការពិនិត្យមើលទៅលើកការគ្រប់គ្រងរដ្ឋបាលសាលារៀនសម្រាប់ទិន្នន័យរបស់នាយក ៤.១៨ (M=4.18) មានមធ្យមកម្រិខ្ពស់ ចំណែកឯទិន្នន័យរបស់លោកគ្រូ អ្នកគ្រូ ៣.៩២ ( M= 3.92)មានមធ្យមខ្ពស់ ទិន្នន័យ សិស្ស៣.៦៧ ( M=3.67) មានមធ្យមកម្រិតខ្ពស់ និងទិន្នន័យរបស់គណៈគ្រប់គ្រងសាលារៀនមានមធ្យម៤.១៣(M=4.13)។ ត្រង់ចំណុចនេះចង់បញ្ជាក់ថា ការគ្រប់គ្រងរដ្ឋបាលសាលារៀននៅសាលាមធ្យមសិក្សាទុតិភូមិមានការរៀបចំបានល្អ ទាំងការរៀបចំចាត់ចែងរបស់គណៈនាយក និងលោកគ្រូ អ្នកគ្រូ ។ រីឯផ្នែកការដឹកនាំគ្រប់គ្រងសាលារៀនគឺទិន្នន័យរបស់នាយកមានមធ្យម៣.៥១(M=3.51)ទិន្នន័យរបស់គ្រូមានមធ្យម៣.៥៥(M=3.55) និងទិន្នន័យរបស់គណៈគ្រប់គ្រងសាលារៀនមានមធ្យម៣.៥៧ (M=3.57)ទាំបីទិន្នន័យនេះសុទ្ធតែមានកម្រិតមធ្យមកម្រិតខ្ពស់ទាំងអស់។ ត្រង់ចំណុចនេះក៏អាចបញ្ជាក់បានថា ការដឹកនាំ និងការគ្រប់សាលារៀនគឺអាចឆ្លើយតបទៅតាមស្តង់ដាសាលារៀនដែលមានប្រសិទ្ធភាព។ ផ្នែក បច្ចេកទេស ការបង្រៀន និងរៀន ទិន្នន័យរបស់គ្រូ ៣.៦៨( M=3.68) មានមធ្យមកម្រិតខ្ពស់ ទិន្នន័យរបស់នាយក មានមធ្យម ៣.៤៣ ( M=3.43 )ដែលមានមធ្យមកម្រិតមធ្យម និងទិន្នន័យរបស់សិស្ស៣.៥០ (M=3.50) ជាមធ្យមកម្រិតខ្ពស់ ទិន្នន័យរបស់គណៈគ្រប់គ្រងមានមធ្យម៣.៤០(M=3.40) បង្ហាញថាការគ្រប់គ្រងបច្ចេកក្នុងការបង្រៀន និងរៀនរបស់លោកគ្រូអ្នកគ្រូមានដំណើរការល្អ ។ ផ្នែកមាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្សៈ ទិន្នន័យសរុបទាំងបួនផ្នែក នាយក គ្រូ សិស្ស និងគណៈកម្មការគ្រប់គ្រងសាលារៀនមានមធ្យម ៣.៣២ (M=3.32) ដែលជាមធ្យមកម្រិត មធ្យម នេះបញ្ជាក់ឱ្យឃើញថា ការទាក់ទងជាមួយ សហគមន៍ និងអាណាព្យាបាលសិស្សទាក់នឹងការសិក្សារបស់សិស្សនៅមានកម្រិត ជាបញ្ហាប្រឈមដល់ដំណើរការអភិវឌ្ឍសមត្ថភាពសិស្សដែលរៀនយឺត។ ផ្នែកការគ្រប់គ្រងធនធានមនុស្ស ដែលទិន្នន័យសរុបបានមកពីគ្រូ នាយក និងគណៈគ្រប់គ្រងសាលារៀន មានមធ្យម ៣.៤១ ( M=3.41) ជាមធ្យមកម្រិតមធ្យម នេះបានបង្ហាញការគ្រប់គ្រងធនធានមនុស្សក្នុងដំណើរការបង្រៀន និងរៀននៅមានការខ្វះដូចជា ធនធានគ្រូបង្រៀនដូចជាមិនទាន់មានគ្រូសមស្របតាមតម្រូវការ និងមិនស្របតាមជំនាញឯកទេស។ ផ្នែកសិស្ស និងសេវាជួយសិស្សដែលទិន្នន័យរួមបានមកពី គ្រូ សិស្ស នាយក និងគណៈគ្រប់គ្រងសាលារៀន មានមធ្យម២.៩៧( M=2.97) ជាមធ្យមកម្រិតមធ្យមក្នុងលំដាប់ទាបដែលបង្ហាញថាក្នុងសិស្ស និងសេវាជួយសិស្សនេះ នៅមាន

ការខ្វះខាត និងបញ្ហាប្រឈមជាច្រើនដូចជាការខ្វះខាត បន្ទប់ពិសោធន៍ ឬមានបន្ទប់ពិសោធន៍ហើយប៉ុន្តែសម្ភារៈពិសោធន៍មិនគ្រប់គ្រាន់ មិនមានបន្ទប់សម្រាប់រៀនកុំព្យូទ័រ ក្លឹបសិក្សាមិនបានជំរុញឱ្យមានដំណើរការ ឬដំណើរការមិនគ្រប់កម្រិតថ្នាក់ គ្រូមិនបានធ្វើទស្សនកិច្ចសិក្សាដើម្បីស្វែងរកបទពិសោធន៍ថ្មីមកជួយសិស្ស ។ ផ្នែកសៀវភៅសិក្សាគោលសម្ភារៈរៀន និងបង្រៀន សរុបទិន្នន័យ ទាំងគ្រូ ទាំងនាយកមានមធ្យម ៣.១៩ (M=3.19) ជាមធ្យមកម្រិតមធ្យមដោយសារការរកឃើញថានៅតាមសាលានីមួយៗ នៅមានការខ្វះ សម្ភារៈសិក្សា ដូចជាសៀវភៅសិក្សាគោល ការបង្កើតបណ្ណាល័យដែលមិនសមស្របតាមស្តង់ដា មិនមានសម្ភារៈឧបទេសគ្រប់គ្រាន់ក្នុងដំណើរការបង្រៀន ។ ផ្នែកហេដ្ឋារចនាសម្ព័ន្ធ សរុបទិន្នន័យទាំងគ្រូ ទាំងនាយក និងគណៈគ្រប់គ្រងសាលារៀនមានមធ្យម ៣.១៤( M=3.14) ដែលជាមធ្យមកម្រិតមធ្យម យើងក៏អាចសន្និដ្ឋានបានដែរថាផ្នែកនេះក៏នៅមានការខ្វះខាត និងជួបបញ្ហាប្រឈមផងដែរដូចជា ការខ្វះខាតបន្ទប់ ឬបន្ទប់រៀនពុំទាន់រៀបតម្រូវតាមស្តង់ដានៅឡើយ បន្ទប់រដ្ឋបាលសាលារៀន និងសង្ហារឹមដែលផ្តល់ឱ្យតាមតម្រូវការ ពុំទាន់គ្រប់គ្រាន់ បន្ទប់ទឹកដែលសាងសង់ឡើងមិនត្រូវតាមបទដ្ឋានសិស្សទាំងស្រីទាំងប្រុស និងផ្នែកចុងក្រោយគឺផ្នែក ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ សរុបទិន្នន័យទាំងគ្រូ ទាំងសិស្សមានមធ្យម ៣.៧៩ (M=3.79) ដែលជាមធ្យមកម្រិតខ្ពស់ តាមរយៈផ្នែកនេះយើងអាចសន្និដ្ឋានបានថា ផ្នែហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ មានលក្ខណៈល្អប្រសើរ មានការចាយវាយត្រឹមត្រូវតាមសម្មតិកម្ម តាមខ្ទង់ចំណាយត្រឹមត្រូវ និងបែងចែកទៅតាមតម្រូវការ និងទៅតាមប្រាក់ចំណូលដែលបានមកពីប្រភពផ្សេងៗ និងបានមកថវិកាគាំទ្រឱ្យដំណើរការបង្រៀន និងរៀន ។

## ៥.៣. ការពិភាក្សាលទ្ធផល

### ក. គោលបំណងទី១

តាមរយៈលទ្ធផលនៃសំណួរស្រាវជ្រាវផ្នែកបំពេញ( សំណួរបរិមាណវិស័យ ) ខាងលើយើងសង្កេតឃើញថាវាបានឆ្លើយតបទៅ នឹងគោលបំណងស្រាវជ្រាវទីមួយដែលផ្តោតទៅលើស្ថានភាពទូទៅនៃការគ្រប់គ្រងតាមសាលារៀន នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តស្វាយរៀង ។ លទ្ធផលជារួម បានបង្ហាញឱ្យឃើញថា នាយក លោកគ្រូ អ្នកគ្រូ នៅតាមវិទ្យាល័យនានាក្នុងខេត្តស្វាយរៀងមានការអនុវត្តការគ្រប់គ្រងតាមសាលារៀនបានល្អទៅលើផ្នែករដ្ឋបាលសាលារៀន ការគ្រប់គ្រងការបង្រៀន និងរៀន ការដឹកនាំការគ្រប់គ្រងសាលារៀន និងផ្នែកហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ ដោយមានមធ្យមកម្រិតខ្ពស់នៅផ្នែកនេះ ។ លើសពីនេះទៅទៀតបើយើងមើលទៅលើផ្នែកធំៗ ទាំងបួនឃើញថា លោកនាយក ក៏ដូចជាលោកគ្រូ អ្នកគ្រូបានអនុវត្តទៅលើការគ្រប់គ្រងតាមសាលារៀន កម្រិតខ្ពស់ទាំងអស់ ទោះបីជា ការគ្រប់គ្រងរដ្ឋបាលសាលារៀន ការគ្រប់គ្រងបច្ចេកទេសរៀន និងបង្រៀន ការគ្រប់គ្រងថវិកានិងការគ្រប់គ្រងដឹកនាំសាលារៀន ។

ជាការពិតណាស់ដូចអ្វីដែលយើងបានរៀបរាប់ បរិយាយខាងលើរួចមកហើយឃើញថាការអនុវត្តការគ្រប់គ្រងតាមសាលារៀន គឺមានសារៈសំខាន់បំផុត សម្រាប់ដំណើរការសាលារៀន ប្រកបដោយប្រសិទ្ធផលខ្ពស់ តួយ៉ាងការដឹកនាំគ្រប់គ្រងរដ្ឋបាល ដូចជាៈការគ្រប់គ្រងលិខិតរដ្ឋបាលផ្សេងៗ ការគ្រប់គ្រងវិន័យសណ្តាប់ធ្នាប់សាលារៀន ការបែងចែកតួនាទី របស់បុគ្គលិក ការបែងចែកសេវាបង្រៀន កាលបែងចែកកាលវិភាគ និងម៉ោងបង្រៀនរបស់បុគ្គលិក ឱ្យបានសមស្រប និងស្របតាមនិយាម ការគ្រប់គ្រង បរិស្ថានសាលារៀន ការគ្រប់គ្រងត្រួតពិនិត្យសាលារៀន ការបែងចែកសិស្សតាមថ្នាក់ការគ្រប់គ្រងបណ្ណាល័យនិងសៀវភៅសិក្សាគោល ដែលវាជាផ្នែកមួយនៃការងារដឹកនាំគ្រប់របស់នាយក(ក្រសួងអប់រំ យុវជន និងកីឡាសៀវភៅការគ្រប់គ្រងរដ្ឋបាលឆ្នាំ២០០២)។ករណីនេះបើយើងទៅមើលទស្សនៈរបស់ គ្រូនៅក្នុងខេត្តស្វាយរៀងចំពោះការងារដឹកនាំគ្រប់គ្រងរដ្ឋបាលនេះឃើញថា លទ្ធផលបានបង្ហាញយ៉ាងច្បាស់ថានាយកសាលាបានបំពេញកិច្ចការផ្នែកការងាររដ្ឋបាលនេះបានល្អ ដែលវាស្របគ្នាទៅនឹងការសិក្សាពីមុនរបស់លោក Sakulsumpaopol (2010) គាត់បានសរសេរថាៈនាយកសាលារៀនតោងតែចៀសមិនរួចពីការចំណាយពេលវេលាច្រើន ដើម្បីរៀបចំចាត់ចែង និងបំពេញកិច្ចការរដ្ឋបាលរបស់សាលា ។

ប្រសើរជាងនេះទៅទៀតចំពោះការដឹកនាំគ្រប់គ្រង ស្ថានភាពដំណើរការ នៃការគ្រប់គ្រងតាមសាលារៀន របស់នាយក លោកគ្រូ អ្នកគ្រូ លើផ្នែកបច្ចេកទេសក៏មានការចាំបាច់សម្រាប់ដំណើរការវាយតម្លៃការគ្រប់គ្រប់នៅក្នុងសាលារៀនមួយ។ ការដឹកនាំការងារបច្ចេកទេសក្នុងការបង្រៀននិងរៀនរបស់គ្រូ និងសិស្សដែលជាអាទិ៍យើងសំដៅទៅលើ ការរៀបចំកម្មវិធិសិក្សា តាមមុខវិជ្ជានីមួយៗ ការរៀបចំធ្វើកិច្ចតែងការបង្រៀន ការដាក់កិច្ចការផ្ទះឱ្យសិស្ស ការបំពេញរដ្ឋបាលថ្នាក់រៀន ការបង្កើតវិញ្ញាសាតេស្ត ប្រចាំខែ ការកែកិច្ចការ និង ការបញ្ចូលពិន្ទុ ការផ្លាស់ប្តូរចំណេះដឹងនិងបទពិសោធ ការប្រជុំក្រុមបច្ចេកទេសនានា តាមការកំណត់ជារៀងរាល់ខែ (៧ដងក្នុងមួយឆ្នាំសិក្សា)វាស្របទៅនឹងការសិក្សារបស់លោក Spillance,Halverson,&Diamond (2004) ដែលគាត់បានសរសេររៀបរាប់ថាៈប្រសិទ្ធភាពរបស់វាមានឥទ្ធិពលដោយប្រយោល និងមិនប្រយោលទៅលើកិច្ចការបង្រៀនរបស់គ្រូនិង លទ្ធផលសិក្សារៀនសូត្ររបស់សិស្ស។ ហើយបើយើង ក្រឡេកមកមើលទស្សនៈរបស់លោកនាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សក្នុងខេត្តស្វាយរៀងវិញ នៅផ្នែកការដឹកនាំគ្រប់គ្រងបច្ចេកទេសលើការបង្រៀន និងរៀននេះបង្ហាញឱ្យឃើញថានាយកវិទ្យាល័យនានា និងលោកគ្រូអ្នកគ្រូដឹកនាំគ្រប់គ្រងការងារបច្ចេកទេសលើការបង្រៀន និងរៀនបានល្អលើសពីនេះទៅទៀតវាមិនខុសពីអ្វីដែលគេបានសិក្សាពីមុនៗនៅប្រទេសផ្សេងៗអំពីការវិវត្តនៃការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាទេដូចជាប្រទេសថៃ ក្នុងបរិបទកំណែទម្រង់អប់រំគឺថា តួនាទីនាយកសាលាក្នុងកិច្ចការបច្ចេកទេសបង្រៀននិងរៀនត្រូវបានយកចិត្តទុកដាក់និងរីកចម្រើន ដែលវាជាបច្ច័យធ្វើឱ្យលទ្ធផលអប់រំទទួលបានកាន់តែល្អប្រសើរជាងមុនដែលនេះជា ការសិក្សារបស់លោក Nenyod (2002)។ ទោះបីជាយ៉ាងណាក្នុងក្របខណ្ឌ ការកែទម្រង់ការអប់រំនៅកម្ពុជានៅតែបន្ត នាយកសាលា លោកគ្រូ អ្នកគ្រូ ទាំងអស់ត្រូវពង្រឹងកិច្ចការដឹកនាំនិងគ្រប់គ្រងបច្ចេកទេសឲ្យបានល្អជាងនេះថែមទៀតដើម្បីធានាការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព និងគុណភាពខ្ពស់។

ចំណែកឯការដឹកនាំគ្រប់គ្រងលើធនធានមនុស្ស និង ការគ្រប់គ្រងបុគ្គលិកវិញ លទ្ធផលជារួមរួមបានបង្ហាញថានៅតាមវិទ្យាល័យនានា ក្នុងខេត្តស្វាយរៀង បានបង្ហាញថាមានលក្ខណៈល្អបង្គួរ ។ តាមលទ្ធផលនេះ បានបង្ហាញយ៉ាងច្បាស់ថា នាយកសាលាទាំងអស់ នៅខេត្តស្វាយរៀង មានការយកចិត្តទុកដាក់

ចំពោះបុគ្គលិករបស់ខ្លួន ទាក់ទងនឹងការលើកទឹកចិត្ត ការផ្តល់ឱកាសដល់គ្រូដូចៗគ្នា ក្នុងការបញ្ចេញមតិយោបល់និងការរិះគន់ក្នុងន័យស្ថាបនា ការផ្តល់ការអភិវឌ្ឍសមត្ថភាពអប់រំដល់គ្រូ និងការណែនាំឱ្យមានការទទួលខុសត្រូវក្នុងវិជ្ជាជីវៈរបស់ខ្លួន ជំរុញឱ្យមានការពង្រឹងសមត្ថភាព តាមរយៈការបន្តការសិក្សាថ្នាក់ឧត្តមសិក្សា ក្រោយឧត្តមសិក្សា (បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់) ការប្រឡងពន្លឿនដើម្បីប្តូរក្របខណ្ឌពីគ្រូកម្រិតមូលដ្ឋានទៅគ្រូកម្រិតឧត្តម ។

ចំណែកឯនៃការអនុវត្តការគ្រប់គ្រងសាលារៀន កម្រិតមធ្យមសិក្សាទុតិយភូមិលើផ្នែកហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធផលស្រាវជ្រាវបានបង្ហាញថា នាយកដឹកនាំគ្រប់គ្រងផ្នែកថវិកានេះបានល្អ ទោះបីជានៅចំណុចតូចៗ មួយចំនួននាយកដឹកនាំគ្រប់គ្រង បានកម្រិតមធ្យម ក៏ដោយ។ យើងសង្កេតឃើញថាជារួម លទ្ធផលក្នុងការដឹកនាំគ្រប់គ្រងថវិកា របស់នាយកវិទ្យាល័យនានាក្នុងខេត្តស្វាយរៀងបានល្អ ដែលជាសញ្ញាវិជ្ជមានមួយបញ្ជាក់ថា នាយកវិទ្យាល័យនានា ក្នុងខេត្តស្វាយរៀងដឹកនាំគ្រប់គ្រងការងារថវិកាបានត្រឹមត្រូវ មានតម្លាភាពក្នុងការចាត់ចែងថវិកា ពិសេស នាយកវិទ្យា ល័យដឹកនាំគ្រប់គ្រងថវិកាមានប្រសិទ្ធភាពនិងតម្លាភាព ធ្វើឱ្យការងារគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈល្អនិងរលូន។ ហើយវាក៏ជាចំណុចវិជ្ជមានមួយ ដើម្បីឲ្យនាយកសាលាវិទ្យាល័យនានា រៀនសូត្រពីវាព្រោះថាការដឹកនាំនិងគ្រប់គ្រងថវិកានិងហិរញ្ញវត្ថុសាលារៀនមួយមានប្រសិទ្ធភាព ជាកត្តាគន្លឹះនៃគោលដៅអប់រំរបស់សិស្ស ក្នុងដំណើការដឹកនាំនិងគ្រប់គ្រងការបង្រៀននិងរៀន។ ចំណុចនេះស្របទៅនិងដំណើរការ នៃការសិក្សាពីមុនមក នៅប្រទេសអាហ្វ្រិកខាងត្បូង ដែលលោក Hansraj (2007) បានសរសេររៀបរាប់ថា ការដឹកនាំនិងគ្រប់គ្រងថវិកាជាចំណុចមួយយ៉ាងសំខាន់ដែលត្រូវតែមានតម្លាភាព ស្មោះត្រង់ សុចរិតបំផុតដើម្បីជានាប្រសិទ្ធភាពដំណើរការសាលារៀនទាំងមូល។

## ខ.គោលបំណងទី២

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវពីវង្វាយតម្លៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន នៅមធ្យមសិក្សាទុតិយភូមិនៅខេត្តស្វាយរៀង លើផ្នែក សិស្ស និងសេវាជួយសិស្ស ផ្នែកការគ្រប់គ្រងធនធានមនុស្ស ផ្នែក ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន ក៏បានរកឃើញពីបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យការសិក្សារៀនសូត្ររបស់សិស្សានុសិស្សមិនទទួលបានលទ្ធផល ដែលឆ្លើយតបទៅនឹង លទ្ធផលនៃសំណួរស្រាវជ្រាវទី២ដែលបង្ហាញឱ្យឃើញពីបញ្ហាប្រឈមដែលរាំងស្ទះដល់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន ។ បញ្ហាប្រឈមទាំងអស់នោះរួមមាន៖

- ផ្នែកការបង្រៀន និងរៀន ៖ ភាពខ្វះមនសិការវិជ្ជាពីគ្រូបង្រៀនមួយចំនួន សមត្ថភាពចំណេះដឹងគ្រូបង្រៀននៅមានកម្រិត គ្រូមិនសូវបានពង្រឹងចំណេះដឹងរបស់ខ្លួន ។
